# អធិប្បាយអំពី ចេតិយ



ធម្មបណ្ណាការ ប្រគេនព្រះធម្ម

ម៉ុនធឿន

www.elibraryofcambodia.org



ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ អធិបតី ពុទ្ធមណ្ឌល
និងជាអគ្គនាយក វិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា
អនិច្ចធម្មថ្ងៃទី ០៨ ខែ កុម្ភៈ គ.ស ២០០៣ ព.ស ២៥៤៧
ក្នុងព្រះជន្មាយុ ៤៧ ព្រះវស្សា

www.elibraryofcambodia.org

017043

Le
294
SAM

# អធិប្បាយ អំពី ចេតិយ

រៀបរៀងដោយ

ព្រះភិក្ខុ ធម្មាចារ្យ **ជិន មាស** (សុវណ្ណវណ្ណោ)

ជាធម្មបណ្ណាការប្រគេន

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ

ផ្សាយចេញពី

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

ភ្នំអដ្ឋវស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

National Library of Cambodia
00017043

ព្រះរាជាណាចក្រកម្ពុជា
5914/07
3/5
បណ្ណាល័យជាតិ

ព.ស ២៥៥០ គ.ស ២០០៦

www.elibraryofcambodia.org

ដូច្នេះខ្ញុំសូមខន្តីអភ័យទោសនូវរាល់កំហុសឆ្គង ដែលកើតមាននៅក្នុងសៀវភៅនេះ ។ យ៉ាងណាសូមលោកអ្នកប្រាជ្ញ ជួយស្ថាបនាកែលំអផង ។

ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឧបាសិកា **សុខ អ៊ឹម** ដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ និងសូមថ្លែងអំណរគុណដោយផ្ទាល់ចំពោះគណៈកម្មាធិការដែលខំខ្នះខ្នែងរហូតដល់បានសំរេច ។

សូមឱ្យកុសលផ្នែកធម្មទាន ពេលនេះកើតមានចំពោះលោកអ្នកដ៏មានគុណទាំងឡាយមានព្រះវិបាកញ្ញាណ ព្រះអង្គគ្រូ ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ អធិបតីពុទ្ធមណ្ឌល លោកគ្រូ **សេ ឈុន** . លោកព្រឹទ្ធាចារ្យ **ម៉ី យ៉ុរ** នឹងលោកអ្នកដ៏មានគុណជាច្រើនទៀត ទៅក្នុងអនាគតសូមឱ្យលោកទាំងអស់សំរេចបានសមាបត្តិ៨ អភិញ្ញា៦ បដិសម្ភិទា៤ កុំបីឃ្លៀងឃ្លាតឡើយ ។

**" ពិភពលោកនឹងល្អ ប្រសិនបើមានចិត្តល្អ "**

វត្តពាមមង្គល ១ កើត ខែបុស្ស ឆ្នាំច អដ្ឋស័ក ព.ស ២៥៥០

ត្រូវនឹងថ្ងៃទី ២០ ខែធ្នូ គ.ស ២០០៦

ព្រះធម្មាចារ្យ ជិន មាស ( សុវណ្ណោ វណ្ណោ)

www.elibraryofcambodia.org

## មាតិកា

ទំព័រ

## ១-ចេតិយ


លក្ខណៈរបស់ចេតិយ ........................................ ២

ប្រភពដើមរបស់ចេតិយ ........................................ ៥

សារៈសំខាន់របស់ចេតិយ ........................................ ១០

បុគ្គលគួរដាក់នៅក្នុងចេតិយ ........................................ ១១

កន្លែងដែលគួរធ្វើចេតិយ ........................................ ១២

គុណនៃការបូជាចេតិយ ........................................ ១២


## ២-កំណើតនៃពុទ្ធចេតិយ


ប្រភេទនៃពុទ្ធចេតិយ ........................................ ២៣

មូលហេតុនៃធាតុចេតិយ ........................................ ២៤

មូលហេតុនៃបរិភោគចេតិយ ........................................ ៣១

មូលហេតុនៃធម្មចេតិយ ........................................ ៣៥

មូលហេតុនៃឧទ្ទេសិកចេតិយ ........................................ ៣៧

ប្រយោជន៍នៃពុទ្ធចេតិយ ........................................ ៤១

អានិសង្សបូជាពុទ្ធចេតិយ ........................................ ៤៣


www.elibraryofcambodia.org

ការបូជាដោយបដិបត្តិ របស់បព្វជិត ............................ ៤៤

ការបូជាដោយអាមិសរបស់គ្រហស្ថ............................ ៤៥

អានិសង្ស ការសាងពុទ្ធចេតិយ ............................ ៤៨

## ៣.បកិណ្ណកពុទ្ធចេតិយ

កន្លែងសាងរ៉ាលុកចេតិយ............................ ៥៦

មូលហេតុនៃរ៉ាលុកចេតិយ ............................ ៥៧

អានិសង្ស រ៉ាលុកចេតិយ............................ ៦៣

## ៤.ការប្រែក្លាយនៃពុទ្ធចេតិយ

អធិប្បាយអំពីការប្រែក្លាយ ............................ ៧៨

## ៥.សាមញ្ញជនចេតិយ

ចេតិយ និង ប្រាសាទនៅប្រទេសខ្មែរ............................ ៨៤

ការធ្វើសាមញ្ញជន ចេតិយបច្ចុប្បន្ន............................ ៩៤

កិច្ចខ្លះៗក្នុងចេតិយ............................ ៩៨

មឈូស និង កោដ្ឋ ............................១០៤

មូលហេតុនៃមឈូស និង កោដ្ឋ............................១០៥

ប្រវត្តិ មឈូស និង កោដ្ឋ ............................១០៧

ពិធីតម្កល់សពក្នុងមឈូស............................១១០

www.elibraryofcambodia.org

អត្ថន័យនៃការតម្កល់សព..........................................១១២
ពិធីរើសអដ្ឋិធាតុ ដាក់កោដ្ឋ.......................................១១៤
អត្ថន័យនៃការរើសអដ្ឋិធាតុដាក់កោដ្ឋ.........................១១៦

## ៦_ការគោរពបូជាចំពោះអដ្ឋិធាតុ

អង្គរបស់កតញ្ញូមាន ២យ៉ាង........................................១១៨
ប្រភេទនៃគុណ...........................................................១១៩
កិច្ចនៃការសងគុណ.....................................................១២៤
វិធីគោរពមានពាយ៉ាង..................................................១២៨
លំដាប់ថ្នាក់នៃអដ្ឋិធាតុ.................................................១២៩
អត្ថន័យនៃការគោរព...................................................១៣០

www.elibraryofcambodia.org

www.elibraryofcambodia.org

ធម្មទានដោយឧបាសិកា

**សុខ អ៊ីម** និងបុត្រ **តូ ឆែគឿង**

ដោយគុណានុភាពនៃបុញ្ញកម្មនេះសូមឱ្យបុព្វការីជន

និងក្រុមញាតិព្រមទាំងសត្វលោកទាំងអស់ បានទទួលសេចក្ដីសុខ

សន្តិភាព និងសុភមង្គលគ្រប់ប្រការ

សូមឱ្យព្រះពុទ្ធសាសនា មានការអភិវឌ្ឍន៍គ្រប់វិស័យ

ស្ថិតនៅក្នុងលោកអស់កាលជាយូរអង្វែង ។

www.elibraryofcambodia.org

www.elibraryofcambodia.org

# អ្នកមាននិស្ស័យនឹងព្រះ
# នៅត្រង់ការធ្វើតាមព្រះ

www.elibraryofcambodia.org

www.elibraryofcambodia.org

## ក្រុមអ្នករៀបចំសៀវភៅ

១- អ្នករៀបរៀង ព្រះធម្មាចារ្យ ធម្មវិន័យ ( ត្រី -ទោ- ឯក)

ភិក្ខុ **ខឹន** **មាស**( សុវណ្ណវណ្ណោ)

២- អ្នកពិនិត្យ អក្ខរាវិរុទ្ធ តាមបែបវចនានុក្រម-ខ្មែរ (ជ.ណ)

សាមណេរ **គុឈ** **ណនាត់**

www.elibraryofcambodia.org

www.elibraryofcambodia.org

## ១.ចេតិយ

ចេតិយគឺជា ថាវរវត្ថុ មួយបែបដែលគេស្ថាបនាឡើង សម្រាប់ធ្វើជាទីសំវេជនីយដ្ឋានរលឹកចំពោះបុគ្គលដែលមានគុណធម៌ខ្ពស់ៗមក លើគេ ។ បើតាមគម្ពីរជាច្រើនជាពិសេសក្នុងគម្ពីរ សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន និង អដ្ឋកថា លើកជាបទ បញ្ជាក់ក្នុងពាក្យថា ចេតិយនេះដោយអត្ថន័យច្បាស់ៗថា **ចេតព្វំ បូជេតព្វន្តិ > ចេតិយំ** ទីដែលបុគ្គលគប្បីបូជាឈ្មោះថា ចេតិយ។ នៅក្នុង អភិធានប្បទីបិកាសូចិ ក៏មានបទបញ្ជាក់ក្នុងពាក្យថា ចេតិយនេះដែរថា **យំ ឋានំ ជនេន ឥដ្ឋការីហិ ចយិតព្វំ តស្មា តំ ឋានំ ចេតិយំ** ទីឯណាដែលជនគប្បីសន្សំ ដោយវត្ថុទាំងឡាយមានឥដ្ឋជាដើម ព្រោះហេតុនោះ ទីនោះឈ្មោះថា ចេតិយ ។

តាមឯកសារបកិណ្ណកជាច្រើន ដែលពួកលោកអ្នកប្រាជ្ញ លោកចងក្រងឡើង ជាបែបពុទ្ធចក្រខ្លះ ជាបែបអាណាចក្រខ្លះៗ បានបញ្ជាក់បន្ថែមថា ចេតិយ មិនមែនជាកម្មសិទ្ធសម្រាប់សាសនាណាមួយ ឬជនជាតិណាមួយទេ។ នៅក្នុងសាសនាដទៃ កាលបើសាស្ត្រាចារ្យរបស់គេដល់នូវមរណកាល ហើយពេលនោះ គេធ្វើជាចេតិយឡើងសម្រាប់ដាក់នូវសព ឬអដ្ឋិធាតុរបស់



www.elibraryofcambodia.org

សាស្ត្រាចារ្យគេដែរ ដើម្បីជាទីគោរពបូជាទៅថ្ងៃក្រោយ ។ សព្វថ្ងៃពួកបុរាណវត្ថុក្នុងពិភពលោកបានស្រាវជ្រាវ នៅប្រទេសឥណ្ឌា បានឃើញបុរាណចេតិយជាច្រើន ដែលគេបានធ្វើឡើងដើម្បីដាក់អដ្ឋិធាតុសាស្ត្រាចារ្យ អ្នកប្រដៅសាសនាដទៃៗ ដូចជាសាសនាជេន របស់និគ្រន្ថត្ថិយជាដើម។ នៅក្នុងប្រទេសឥណ្ឌានោះផងដែរ គេក៏ស្រាវជ្រាវឃើញចេតិយដាក់អដ្ឋិធាតុ បុគ្គលមានគុណធមិខ្ពស់ៗដូចជាព្រះអរហន្ត អគ្គសាវ័កពុទ្ធជាដើមដែរ ។ នៅរដ្ឋនេប៉ាល់ប្រទេសឥណ្ឌាមានចេតិយគេធ្វើឡើង តម្កល់ទុកអដ្ឋិធាតុព្រះសារីបុត្រ និងព្រះមោគ្គល្លាន។ ក្នុងគម្ពីរអដ្ឋកថាធម្មបទថា ព្រះពាហិយៈ ដែលរាប់បញ្ចូលក្នុងសាវ័ក (អតីតសាវ័ក) ត្រូវគោជល់ឱ្យបរិនិញ្វាន ព្រះពុទ្ធជាម្ចាស់នៃយើងទ្រង់ឱ្យគេធ្វើព្រះចេតិយ បញ្ចុះអដ្ឋិធាតុរបស់លោក ។

## លក្ខណៈរបស់ចេតិយ

ចេតិយ (ព្រះស្តូប) ដែលគេសាងឡើង ជាដំបូងក្នុងគ្រាបុរាណកាល គឺគេគ្រាន់តែពូនដីឱ្យទៅជាពំនូកឡើង (នេះជាលក្ខណៈរបស់ចេតិយដំបូង)។ ខាងចុងគេរៀបជាខឿនព័ទ្ធជុំវិញ ការពារកុំឱ្យដីបាក់នៅលើពំនូកដីនោះមានដោតឆត្រសម្រាប់សម្គាល់ ធ្វើកិត្តិយសដល់បុគ្គលដែលបានបញ្ចុះក្នុងចេតិយនោះផង ។ ចំពោះទំហំចេតិយនៅពេលនោះ



www.elibraryofcambodia.org

តូចក្តី ធំក្តី ផ្ចិតផ្ចង់ក្តី មិនសូវផ្ចិតផ្ចង់ក្តី នៅលើសមត្ថភាពអ្នកធ្វើដែលអាចធ្វើទៅកើត ។

លុះកាលជាខាងក្រោយមកទៀត ពេលដែលព្រះពុទ្ធ លោកបរិនិព្វានទៅហើយ ជាពិសេស ក្នុងរាជ្យព្រះបាទធម្មាសោក ក៏បែកគំនិតនាំគ្នារចនារូបចេតិយ ឱ្យខុសពីទម្លាប់ដែលធ្លាប់ធ្វើពីមុនៗ (ពីបុរាណ)។ នៅក្នុងពេលនោះ គេកែរូបរាងចេតិយដូចជា ពំនូកខ្សាច់ អោយមានទ្រង់ទ្រាយល្អ ធ្វើខឿនមានថានរង និងធ្វើទីលានជុំវិញខឿន សម្រាប់ដើរប្រទក្សិណ។ ចេតិយដែលធ្វើនៅពេលនោះទៀតសោត គឺធ្វើអំពីឥដ្ឋ ឬថ្មដែលជារបស់ជាប់បានយូរ ។ លក្ខណៈរបស់ចេតិយទាំងនោះ ច្រើនធ្វើរូបរាងមូលៗ មានសណ្ឋានដូចសៀវខ្លះ ឬដូចផ្តិលផ្កាប់ខ្លះ នៅខាងលើគេធ្វើជាអាសនៈបួនជ្រុង ឬពុទ្ធាសនៈប្រតិស្ឋានទុកមានឆត្រ គេដោតនៅលើអាសនៈ នោះជាកំពូលគេរោយខ្សាច់ព័ទ្ធជុំវិញចេតិយ រួចធ្វើជារបងរាំង ។

លក្ខណៈចេតិយមួយប្រភេទទៀត ក្នុងសម័យព្រះបាទធម្មាសោកនោះដែរគឺគេរចនាជាបែបផ្សេងទៀតជាច្រើនដូចជា ធ្វើជាក្បាច់នៅលើខឿនជុំវិញ និងផ្ទៃជុំវិញព្រះចេតិយ។ ចំពោះ រូបភាព ដែលគេឆ្លាក់នោះ



www.elibraryofcambodia.org

ភាគច្រើនដូចជារឿង ជាតយខ្លះ រឿងពុទ្ធប្បវត្តិខ្លះ ក៏ប៉ុន្តែចំពោះរូបភាព ដែលគេឆ្លាក់ដាក់នោះ គឺគេមិនធ្វើជាពុទ្ធរូប ដោយផ្ទាល់ទេ គេធ្វើជាវត្ថុជាតំណាង ឬជាគ្រឿងសម្គាល់វិញ ។ ជាការដាក់ស្តែង ដូចជាត្រង់មុនព្រះពុទ្ធលោកត្រាស់ដឹង គេច្រើនតែធ្វើជារូបស្នាមព្រះពុទ្ធបាទ ឬ អាសនៈទទេ (គ្មានព្រះពុទ្ធរូប) ត្រង់ព្រះពុទ្ធលោកចេញបួស គេធ្វើរូប សេះចងរូបកែបទទេ (គ្មានទ្រង់គង់លើ) ត្រង់ព្រះពុទ្ធត្រាស់ដឹង គេធ្វើពុទ្ធាសនៈទទេនៅក្រោមដើមពោធិព្រឹក្ស (គ្មានរូបទ្រង់គង់លើបល្ល័ង្ក) ត្រង់ទីដែលលោកសម្តែងបឋមទេសនាធម្មចក្កប្បវត្តនសូត្រ គេធ្វើជារូបកងចក្រ (សម្គាល់សេចក្តីថាធម៌ចក្រ) និងមានម្រឹគក្តាន់ផង (ជាគ្រឿងសម្គាល់ថានៅក្នុងព្រៃ) និងត្រង់ទីទ្រង់ចូលបរិនិព្វាន គេធ្វើជារូបចេតិយទីបញ្ចុះព្រះបរមធាតុ ជំរូបអង្គព្រះសម្មាសម្ពុទ្ធ ។ល ។

ក្នុងសៀវភៅឈ្មោះ ពុទ្ធសាសនា២៥០០ បានបញ្ជាក់នូវ លក្ខណៈចេតិយបន្ថែមថា ជួនកាលគេរចនាធ្វើកំពូលរាងស្រួចក៏មានដាក់ឆត្រវត្តធ្វើអំពីស្ពាន់ ឬដែកនៅលើកំពូលក៏មាន កំពូលគេធ្វើមុខបួន (មុខព្រហ្ម) ក៏មាន ។ ចំពោះរូបព្រហ្មមុខបួននេះ បើចេតិយពួកព្រហ្មញ្ញសាសនាគេតំណាងឱ្យព្រះព្រហ្មនៅឋានព្រហ្មលោកដែលមានព្រហ្មវិហារធម៌៤ប្រការ



www.elibraryofcambodia.org

គឺ មេត្តា១ ករុណា១ មុទិតា១ ឧបេក្ខា១ ។ បើខាងព្រះពុទ្ធសាសនាបែបមហាយានរូបមុខ៤នោះ គេតំណាងឱ្យរូបព្រះពោធិសត្វអវលោកេតិស្វរៈ ដែលគេហៅនាមមួយបែបទៀតថា សមន្តមុខ ប្រែថា មានមុខជុំវិញ សម្លឹងចុះក្រោមដើម្បីប្រមើលមើលសុខទុក្ខសត្វលោក ។

ចេតិយនៅមានលក្ខណៈផ្សេងៗទៀត ដែលគេរចនា ឡើងតាមបែបវប្បធម៌នីមួយៗ ។ តួយ៉ាងដូចជា ប្រទេសកម្ពុជា យើងដោយផ្ទាល់ រូបភាពចេតិយមានច្រើនបែបណាស់ ឥតដូចគ្នាទេ ប្លែកទៅតាមស្នាដៃរបស់ពួកសិល្បករដែលអាចធ្វើទៅបាន និងជាពិសេសដើម្បីឱ្យសមគួរដល់កិត្តិយសរបស់អ្នកមាន គុណសម្បត្តិ ឬឱ្យសមគួរដល់គុណធម៌ជាដើម ។ ដូច្នេះ លក្ខណៈរបស់ចេតិយ មានការអភិវឌ្ឍន៍ទៅតាមសម័យកាលនីមួយៗ ឬទៅតាមវប្បធម៌ប្រទេសនីមួយៗ ។

## ប្រភពដើមរបស់ចេតិយ

នៅក្នុងសៀវភៅឈ្មោះ ពុទ្ធសាសនា ២៥០០ និងនៅក្នុងសៀវភៅឈ្មោះ ដំណាលពុទ្ធចេតិយ មិនឃើញមានប្រភព ណាមួយបញ្ជាក់ថា ចេតិយកើតមានឡើងក្នុងសម័យនេះ ឬ សម័យនោះដោយលក្ខខ័ណ្ឌច្បាស់លាស់ឡើយ ។ បើតាមប្រវត្តិការណ៍ ក្នុងគម្ពីរព្រះពុទ្ធសាសនា ជាច្រើនទៀតបញ្ជាក់



www.elibraryofcambodia.org

ថា ចេតិយ ជាវត្ថុដ៏ស័ក្តិសិទ្ធមួយដែលសាងទុកធ្វើជាទីគោរពបូជា មានតាំងពីព្រេងព្រឹទ្ធមុនសម័យពុទ្ធកាល ដ៏យូរលង់មកម្ល៉េះ ដូចមានចារទុកតាមគម្ពីរត១គ្នាមកថា បាវ៉ាឡចេតិយ និង សារន្ទទចេតិយ ជាដើម ។

ក្រៅអំពីនេះ នៅមានគម្ពីរជាច្រើនទៀតដែលនិយាយអំពីប្រភពរបស់ចេតិយដែរ ដូចជាក្នុងសៀវភៅទសជាតកសង្ខេប កណ្ឌទី២ បានសម្តែងពីរឿងព្រះសម្មាសម្ពុទ្ធនៃយើងកាលលោក នៅជាព្រះពោធិសត្វ សោយរាជ្យជាស្តេចនៅនគរមិថិលា ដែនវិទេហរាស្ត្រ ថាក្នុងកាលនោះទ្រង់មាន ព្រះនាមប្រាកដថា ព្រះមហាជនកមានអគ្គមហេសីព្រះនាមព្រះនាងសីវលី មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមថា ទីឃាវុរាជកុមារ ។ ពេលមួយ ទ្រង់បណ្តេញហាមឃាត់នូវពួកមនុស្សដទៃ១មកនៅ ឬចេញចូលក្នុងទីនោះ លែងឱ្យមានលើកលែងតែអ្នកបម្រើព្រះអង្គដោយផ្ទាល់ម្នាក់ចេញ ។ ក្នុងគ្រានោះឯងទ្រង់ធ្វើសមណធម៌អស់រយៈពេល៤ខែ ឥតឱ្យអ្នកណាដឹងសោះ ។ ទីបំផុតព្រះអង្គបានរត់ចេញទៅបួស ព្រះនាងសីវលី និងអស់ប្រជានុរាស្ត្រជាច្រើនតាមអង្វរកុំឱ្យព្រះអង្គចេញបួស ។ ការតាមអង្វរនេះអស់ចម្ងាយផ្លូវ ៦០យោជន៍ និងថេរៈវេលាជាច្រើនថ្ងៃចុងបញ្ចប់ទ្រង់ក៏រត់គេច ផុតពួកជនទាំងនោះចូលទៅក្នុងព្រៃជ្រៅបាត់ទៅ ។ ព្រះនាងសីវលី អស់សង្ឃឹមនឹងបានជួបព្រះស្វាមីទៀត



www.elibraryofcambodia.org

ក៏ចាត់ការកសាងនូវចេតិយអនុស្សាវរីយ៍ជាច្រើនដែលជាកន្លែងសំខាន់ៗ គឺ :

ក-កន្លែងដែលព្រះស្វាមីសន្ទនាជាមួយជាងពត់ព្រួញឱ្យត្រង់ល្អ

ខ-កន្លែងដែលព្រះស្វាមីសន្ទនាជាមួយនាងកុមារិកាកំពុងរែងដីខ្សាច់

គ-កន្លែងដែលព្រះស្វាមី បង្សុកូលជុំសាច់ដែលឆ្កែពាំធ្លាក់ដី

ឃ-កន្លែងដែលព្រះស្វាមីសន្ទនាជាមួយតាបសឈ្មោះមិគាជិនតាបស

ង-កន្លែងដែលព្រះស្វាមីសន្ទនា ជាមួយតាបសឈ្មោះនារទតាបស ។

បន្ទាប់ពីព្រះនាងឱ្យគេសាងចេតិយអនុស្សាវរីយ៍ ត្រង់កន្លែងសំខាន់ៗ ដូចខាងលើរួចមក ព្រះនាងបានធ្វើនូវពិធីបូជាព្រះចេតិយទាំងនោះ ប្រកបដោយភាពអធិកអធមជាទីបំផុត។ ក្នុងនោះដែរ ព្រះនាងបានយកផ្កាភ្ញី គ្រឿងក្រអូប ព្រមទាំងគ្រឿងសក្ការបូជាជាច្រើនទៀត បូជាដល់ព្រះចេតិយទាំងនោះ ។

មានប្រភពផ្សេងទៀត ដែលមានចារនៅក្នុងសៀវភៅពុទ្ធប្បវត្តិកថា ច្បាប់ដើមឈ្មោះបឋមសម្ពោធិ តែងនៅសិរីលង្កាបញ្ជាក់ថា ក្នុងពេលព្រះសិទ្ធត្ថបរមពោធិសត្វលោកចេញទៅបួស ពេលនោះឯង លោកគង់លើផ្នូកខ្សាច់ក្បែរស្ទឹងនេរញ្ជរា ទ្រង់យករតនខគ្គាវុធជាទិព្វមកកាត់ព្រះកេសាទុកសល់ពីរធ្នាប់រួចទ្រង់អធិដ្ឋាននូវសក់នោះហើយ ក៏បោះទៅឰដ៏អាកាស ។



www.elibraryofcambodia.org

ចំណែកព្រះឥន្ទក៏យកនូវប្រអប់កែវមកដាក់ព្រះកេសានោះ យកទៅបញ្ចុះទុកក្នុងព្រះចេតិយឈ្មោះចូឡាមណីចេតិយ នាឋានតាវតឹង្ស ។

ក្នុងព្រះមាល័យសូត្របានបញ្ជាក់ថា ព្រះចូឡាមណីចេតិយនេះ ជាទីគោរពបូជានៃពួកទេវបុត្រទេវធីតាទាំងឡាយ ។ នៅថ្ងៃ ៨កើត. ៨រោច. ១៥កើត. ១៥រោច ពួកទេវបុត្រទេវធីតាតែងតែមកប្រជុំក្នុងទីលានព្រះចេតិយនេះ ដើម្បីបូជាដល់ព្រះចេតិយផង ដើម្បីសាកច្ឆាចមិត្តាទៅវិញទៅមកផង ។ ព្រះចេតិយមានទំហំ ៥០០យោជន៍ ព្រះឥន្ទជាអ្នកកសាងឡើង ដើម្បីដាក់ព្រះមោលី ដែលទ្រង់កាត់ចេញពេលបួសនោះ ។

ស្របគ្នានឹងពេលព្រះពោធិសត្វចេញបួសនោះដែរ បន្ទាប់ពីកាត់ព្រះកេសារួច ទ្រង់រិតក្តរកស្បង់ចីវរប្រដាប់ព្រះកាយ ពេលនោះឯង ឃដីការ-មហាព្រហ្ម ជាសំឡាញ់ចាស់របស់ព្រះបរមពោធិសត្វក្នុងសាសនាព្រះពុទ្ធកស្សបៈ ក៏យកនូវគ្រឿងបរិក្ខារទាំងនោះមកថ្វាយ ។ ព្រះពោធិសត្វទ្រទ្រង់នូវគ្រឿងបរិក្ខារស្រេចហើយ ទ្រង់បោះនូវសំពត់ទាំងគូទៅឰដ៏អាកាស ។ ខណៈនោះឯង ឃដីការមហាព្រហ្ម ក៏យកនូវសំពត់នោះទៅតម្កល់ទុកក្នុងទុស្សចេតិយកំពស់ ១២យោជន៍នាឋានព្រហ្មលោក ។



www.elibraryofcambodia.org

ពេលព្រះពោធិសត្វ លោកបានត្រាស់ដឹងជាដំបូង កាលនោះឯងទ្រង់គង់នៅក្រោមដើមកែស មានពាណិជពីរនាក់ជាបងប្អូននឹងគ្នាបង្កើត បងឈ្មោះតបុស្សៈ ប្អូនឈ្មោះភល្លិកៈ បានថ្វាយនូវសដូវដុំសដូវផង់ ចំពោះព្រះពុទ្ធជាម្ចាស់ ។ លំដាប់នោះ ពាណិជទាំងពីរនាក់ទូលសូមនូវវត្ថុជាសក្ការបូជា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទាននូវសក់៨សរសៃដល់ពាណិជនោះ ពាណិជទាំងពីរនាក់នោះ ក៏រៀបចំទីទួលសិង្គុត្តរៈ ធ្វើចេតិយបញ្ចុះទុក ដើម្បីធ្វើសក្ការបូជា ។

បើតាមគម្ពីរបានបញ្ជាក់បន្ថែមទៀតថា ពេលដែលពាណិជបញ្ចុះនោះព្រះបាទឧបលាបរាជ ជាឧបត្ថម្ភកៈ ប្រកបដោយសេចក្តីអស្ចារ្យ ចំណែកពួកទេវតាមានសក្កទេវរាជជាដើម ក៏មកជួយរៀបចំពួកមនុស្សមាន ព្រះបាទឧបលាបរាជជាដើម ទ្រង់មកជួយខ្វល់ខ្វាយ ។ ឯព្រះកេសធាតុសោត ក៏សម្តែងនូវបាដិហារិយ៍ដោយប្រការផ្សេងៗ ។ ពួកទេវតានិងមនុស្ស ក៏នាំគ្នាធ្វើសក្ការបូជាដោយវត្ថុផ្សេងៗមានមាសប្រាក់ជាដើម ដោយចិត្តជ្រះថ្លារៀងៗខ្លួន ។

ចំពោះព្រះចេតិយនោះ មានឈ្មោះប្រាកដថា សិង្គុត្តរចេតិយ ។ បើតាមការសិក្សាស្រាវជ្រាវសាវតារត១មកឃើញថា ទីទួលដែលធ្វើព្រះចេតិយបញ្ចុះព្រះកេសធាតុព្រះពុទ្ធគោតមនេះ គឺជាទីដាក់ទុកនូវគ្រឿងបរិក្ខារ



www.elibraryofcambodia.org

ព្រះពុទ្ធ ៤ព្រះពុទ្ធក្នុងភទ្ទកប្បនេះ ។ ព្រះពុទ្ធកកុសន្ធៈបញ្ចុះធម្មក្រក. ព្រះពុទ្ធកោនាគមនៈ បញ្ចុះវត្តពន្ធ. ព្រះពុទ្ធកស្សបៈ បញ្ចុះសាដក. ព្រះពុទ្ធគោតម បញ្ចុះសក់ ។

នៅក្រោយព្រះពុទ្ធលោកបរិនិព្វានទៅអស់រយៈកាលយូរក្តី ឬថ្មីៗក្តី ចេតិយត្រូវបានគេធ្វើជាហូរហែ រហូតមកទល់បច្ចុប្បន្ន ។ ដូច្នេះចេតិយរកប្រភពដើម ឃើញមិនច្បាស់ឡើយ ដោយហេតុថា ចេតិយគឺជាគារវវត្ថុមួយប្រភេទដែលគេនិយមរាប់អានតៗគ្នាតាំងតែពីមុនពុទ្ធកាលមកម្ល៉េះ ។

## សារៈសំខាន់របស់ចេតិយ

ចេតិយទោះបីរកប្រភពដើមមិនប្រាកដក៏ដោយ ក៏ប៉ុន្តែចេតិយគេធ្វើឡើង គឺសម្រាប់បញ្ចុះសព ឬ អដ្ឋិធាតុរបស់អ្នកមានគុណ ដើម្បីធ្វើជាសក្ការបូជាទៅថ្ងៃក្រោយ ជាការរំលឹកនូវគុណរបស់លោកផង ជាការបូជាគុណរបស់លោកផង និងជាការសន្សំនូវបុណ្យកុសលរៀងៗខ្លួនផង ។ មួយទៀតចេតិយបើមិនសម្រាប់បញ្ចុះសព ឬ អដ្ឋិធាតុបុគ្គលមានគុណទេ គេធ្វើជារូបបដិមាបុគ្គលទាំងនោះតម្កល់ទុកដូចជារូបបដិមាព្រះពុទ្ធ ឬ ព្រះអាទិទេពផ្សេងៗជួនកាលមានបដិមាស្តេច មន្ត្រីធំៗផងដែរ ដែលគេចាត់ទុកថាជាបុគ្គលដែលគួរគោរពបូជា ។



www.elibraryofcambodia.org

**បុគ្គលគួរដាក់ក្នុងចេតិយ**

បុគ្គលដែលគួរដាក់ក្នុងព្រះចេតិយនៅក្នុងមហាបរិនិព្វានសូត្រ បាន ពណ៌នាជាដំណើររឿងថា ពេលមួយជាពេលដែលព្រះពុទ្ធជាម្ចាស់នៃយើង លោកទៀបបរិនិព្វានទៅហើយ ក្នុងពេលនោះឯង ព្រះអានន្ទត្ថេរបានក្រាប ទូលសួរព្រះពុទ្ធជាម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន តើបុគ្គលពួកណាខ្លះ ដែល គួរដាក់ក្នុងព្រះចេតិយ? ព្រះពុទ្ធជាម្ចាស់ព្រះអង្គក៏ត្រាស់តបចំពោះព្រះអានន្ទ ត្ថេរដោយសេចក្ដីថា៖

**ចត្តារោ មេ ភិក្ខវេ ថូបារហបុគ្គលា សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ អរហា ចក្កវត្តិរាជ** ប្រែថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគួរដាក់ក្នុងចេតិយមាន៤ពួកគឺ ព្រះសម្មាសម្ពុទ្ធ១, ព្រះបច្ចេក ពុទ្ធ១, ព្រះអរហន្ត១, ស្ដេចចក្រពត្តិ១, បុគ្គលទាំង ៤ពួកនេះជាបុគ្គលគួរ ដាក់ក្នុងចេតិយ ។ ម្នាលអានន្ទ ដោយហេតុថា បុគ្គលទាំង ៤ពួកនេះ កាលណា បើបុគ្គលបានបូជាអដ្ឋិធាតុលោកដោយចិត្តជ្រះថ្លា ក៏អាចជាជនកបច្ច័យ នាំ សត្វឱ្យកើតក្នុងសុគតិភព សមគួរតាមបសាទចិត្តដែលប្រព្រឹត្តទៅក្នុងព្រះ ចេតិយដែល តម្កល់នូវអដ្ឋិធាតុរបស់លោក ។



www.elibraryofcambodia.org

## កន្លែងដែលគួរធ្វើចេតិយ

នៅក្នុងមហាបរិនិព្វានសូត្រដដែល ព្រះអានន្ទទូលសួរព្រះពុទ្ធជាម្ចាស់ទៀតថា បពិត្រ ព្រះអង្គដ៏ចម្រើន តើកន្លែងណាដែលគួរធ្វើចេតិយ ? ព្រះពុទ្ធទ្រង់ត្រាស់តបថា ម្នាលអានន្ទកន្លែងដែលគួរធ្វើព្រះចេតិយនោះ គឺកន្លែងណាដែលមានផ្លូវបែក ជាបួនមនុស្សដើរចេញចូលច្រើន ។ ម្នាលអានន្ទ ដោយហេតុថា ការធ្វើក្នុងទីកន្លែងដែលមានផ្លូវបែកជាបួន គឺដើម្បីជាទីធ្វើនូវសក្ការបូជានៃមនុស្សនិករ ដែលធ្វើដំណើរមកពីទិសទាំងបួនបាន ឃើញទាំងអស់គ្នាឱ្យកើតចិត្តជ្រះថ្លា ក្នុងចិត្តសន្សំនូវអនុស្សតានុត្តិរិយកុសល និងមយបុញ្ញរាសី ។

ព្រះពុទ្ធទ្រង់សម្តែងបញ្ជាក់ទៀតថា ម្នាលអានន្ទ ជនទាំងឡាយណានឹងលើកឡើងនូវកម្រងផ្កា ឬសុគន្ធជាតិ ឬក៏នូវលំអិតបូជាព្រះចេតិយនោះ ក្តី ញុំាំងចិត្តឱ្យជ្រះថ្លានៅក្នុងគុណព្រះពុទ្ធ ព្រោះឃើញព្រះចេតិយនោះក្តី ម្នាលអានន្ទ កិច្ចទាំងអស់នោះសុទ្ធតែប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ជនទាំងឡាយអស់កាលដ៏យូរ ។

## គុណនៃការបូជាចេតិយ

នៅក្នុងគម្ពីរមង្គលត្ថទីបនី ភាគ១ ព្រះមង្គលាចារ្យ លោកលើករឿង



www.elibraryofcambodia.org

កោសាតកីទេវធីតា មកសម្តែងបញ្ជាក់ថា ពេលព្រះបរមគ្រូនៃយើងលោកបរិនិព្វានទៅហើយ ព្រះបាទអជាសត្រូវបានលះនូវព្រះរាជទ្រព្យជា ច្រើនធ្វើនូវព្រះចេតិយដាក់អដ្ឋិធាតុរបស់ព្រះអង្គដោយសេចក្តីជ្រះថ្លា ។

ក្នុងពេលនោះឯង មានឧបាសិកាម្នាក់ នៅអាស្រ័យក្នុងក្រុងរាជគ្រឹះបានសំអិតសំអាងកាយយ៉ាងសមរម្យទាំងព្រឹក ហើយក៏បានកាន់យកនូវវល្លិននោងព្រៃ ៤ទង ដោយតាំងចិត្តថា អាត្មាអញនឹងយកទៅបូជាព្រះចេតិយដែលដាក់ព្រះអដ្ឋិធាតុព្រះសម្មាសម្ពុទ្ធ ។ ដោយនាងមានចិត្តជ្រះថ្លាពន់ពេកភ្លេចមើលសព្វទីឋាន ពេលនោះឯងមានគោកូនខ្ចីមួយបានបោលឆ្ពោះមករករូបនាង ហើយក៏ជល់ស្លាប់មួយរំពេច ដោយពុំទាន់យកផ្កាននោងនោះទៅដល់ទីព្រះចេតិយផង ។

ទោះបីដូច្នេះក្តី ចិត្តនាងបានជ្រះថ្លា ហើយពីខាងដើមចំពោះព្រះចេតិយ លុះនាងស្លាប់ទៅបានទៅកើតជាទេវធីតានៅឋានតាវតឹង្ស ចំកណ្តាលពួកទេវបុត្រ ទេវធីតារបស់សក្កទេវរាជ ដែលព្រះអង្គនាំទៅក្រសាលក្នុងឧទ្យាន។ ពណ៌សំលៀកបំពាក់របស់នាង សុទ្ធតែពណ៌លឿង ដូចផ្កាននោងទាំងរថរបស់នាងទៀតសោត ក៏មានពណ៌លឿងដែរ ដូច្នេះហើយ ទើបគេហៅឈ្មោះនាងថា កោសាតកីទេវធីតា។ សក្កទេវរាជ ទ្រង់ឆ្ងល់ក៏ត្រាស់សួរ



www.elibraryofcambodia.org

នូវបុណ្យកម្មរបស់ នាងដោយព្រះគាថាដូចខាងក្រោម ៖

ម្នាលនាងដ៏ចម្រើន អ្នកមានសំពត់លឿងស្អិតស្អាង ដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ដោយផ្កាឧប្បលលឿងមានភោជនពណ៌លឿង មានឆត្រលឿងមានរថលឿង មានសេះលឿង មានផ្លិតលឿងក្នុងភពជាមនុស្សក្នុងកាលមុន នាងបានធ្វើកម្មដូចម្ដេច ? ម្នាលនាងទេវធីតា យើងសួរហើយនាងចូរប្រាប់ចុះ នេះគឺជាផលនៃកម្មអ្វី ? ។

លំដាប់នោះឯង នាងទេវធីតានោះ លុះនាងស្ដាប់នូវសំនួរ អំពីសក្កទេវរាជចប់ហើយ នាងក៏ឆ្លើយតបចំពោះសក្កទេវរាជ តាមបុណ្យកម្មដែលនាងបានធ្វើកាលនៅឋានមនុស្សដោយព្រះគាថាដូចខាងក្រោម ៖

បពិត្រព្រះអង្គដ៏ចម្រើន ! មានវល្លិនរនោងព្រៃ ជាវល្លិមានជាតិល្វីងដែលគេមិនត្រូវការ ហើយខ្ញុំម្ចាស់មានចិត្តជ្រះថ្លា ហើយបានយកផ្ការនោងព្រៃ ៤ទង ទៅបូជាព្រះស្តូប (ចេតិយ) ឧទ្ទិសចំពោះព្រះសរីរៈ របស់ព្រះសាស្ដា ខ្ញុំម្ចាស់កំពុងមានចិត្តប្រព្រឹត្តទៅក្នុងព្រះធាតុ នៃព្រះមានព្រះភាគនោះមិនបានក្រឡេកមើលផ្លូវ មេគោនោះផង គ្រានោះស្រាប់តែមេគោ មកជល់ខ្ញុំម្ចាស់ដែលមានអធ្យាស្រ័យមិនទាន់ដល់ព្រះស្តូប (ចេតិយ) ហើយក៏



www.elibraryofcambodia.org

ស្លាប់ទៅ បើខ្ញុំម្ចាស់គប្បីសន្សំបុណ្យនោះសម្រេចម្ល៉េះ សមជាមានសម្បត្តិដ៏លើសលុបជាងនេះពិតមែន បពិត្រព្រះអង្គជាធំលើទេវតា នាមមឃវៈជាទេវកញ្ញា ខ្ញុំម្ចាស់បានលះបង់នូវរាងកាយជាមនុស្សមកកើតជាមួយ នឹងព្រះអង្គព្រោះកម្មនោះ ។

**សក្កទេវរាជសម្តែងធម៌**

កាលជាក្រោយមកទៀត សក្កទេវរាជទ្រង់ក៏សម្តែងធម៌ដល់ពួកទេវបុត្រ ទេវធីតា នាឋានតាវតឹង្ស មានមាតលិទេវបុត្រ ជាប្រធាន ។ ព្រះធម៌ទេសនាក្នុងពេលនោះ គឺទ្រង់សម្តែងអំពីការបំពេញបុណ្យរបស់ទេវធីតាកោសាតកី ដែលនាងបានរៀបរាប់ប្រាប់ព្រះអង្គ ក្នុងពេលព្រះអង្គសួរនូវបុព្វកម្មរបស់នាងនោះ ។ ជាការជាក់ស្តែងដូចព្រះគាថាទ្រង់សម្តែងថា :

" ម្នាលមាតលិ អ្នកចូរមើលនូវសេចក្តីអស្ចារ្យនេះជាផលនៃកម្មវិចិត្រទេយ្យធម៌ សូម្បីតែបន្តិចបន្តួចដែលបុគ្គលបានធ្វើហើយ បុណ្យត្រឡប់ទៅជាមានផលច្រើន កាលបើចិត្តជ្រះថ្លាហើយ ចំពោះព្រះតថាគត ជាព្រះសម្ពុទ្ធជាព្រះបច្ចេកពុទ្ធ ឬសាវ័ក របស់ព្រះតថាគតនោះ ទក្ខិណាទានឈ្មោះថាមានផលតិចតួចមិនមែនសោះឡើយ ម្នាលមាតលិ អ្នកចូលមកចុះ សូម្បីយើងទាំងឡាយក៏នឹងបូជាព្រះធាតុ របស់ព្រះតថាគត ឱ្យលើសលុបជាងនេះ



www.elibraryofcambodia.org

ទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ ជាហេតុនាំឱ្យមានសេចក្ដីសុខ សូម្បីកាលព្រះតថាគតទ្រង់ឋិតនៅក្ដី បរិនិព្វានទៅហើយក្ដី បើតាំងចិត្តស្មើផលក៏មានស្មើ ត្បិតថាសត្វទាំងឡាយ អ្នកមានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន ទាយកទាំងឡាយ រមែងទៅកាន់ឋានសួគ៌បាន ព្រោះការបូជាចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងឡាយនោះ ទ្រង់កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើនហ្ន៎ ។

សក្កទេវរាជ លុះទ្រង់សម្ដែង យ៉ាងដូច្នេះចប់ហើយ ទ្រង់រម្ងាប់នូវព្រះឧស្សាហ៍ក្នុងការស្ដេចយាងទៅប្រពាតព្រះឧទ្យាន ស្ដេចយាងត្រឡប់អំពីនោះមកវិញ ទ្រង់ធ្វើការបូជាព្រះចូឡាមណីចេតិយអស់មួយសប្ដាហ៍ (៧ថ្ងៃ) ដល់ពេលជាខាងក្រោយមកទៀត ទ្រង់បានត្រាស់នូវរឿងរ៉ាវនោះ (រឿងកោសាតកីទេវធីតា) ចំពោះព្រះនារទត្ថេរដ៏មានអាយុ ដែលលោកនិមន្តទៅឋានតាវតិង្សនោះ ដោយព្រះគាថាដូចខាងលើនេះស្រាប់ ។ ពេលធ្វើនូវបឋមសង្គាយនា ព្រះថេរៈ ក៏សម្ដែងនូវរឿងនេះដែរដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ។

ព្រះថេរៈទាំងឡាយលោកក៏លើកយកនូវរឿងនេះ មកសម្ដែងពេលសង្គាយនានោះឡើង ។



www.elibraryofcambodia.org

ដូច្នេះគុណនៃការបូជានូវព្រះចេតិយ មានជាប្រយោជន៍ដ៏ច្រើន ដូចរឿងដែលបានស្រង់ចាកគម្ពីរមកដាក់នៅខាងលើនេះ ជាគោលអាងធំ ។ បុគ្គលស្វែងរកនូវបុណ្យ គួរតែកាន់យកវត្ត គឺការបូជានូវព្រះចេតិយផងដែរ ទោះបីផ្កាកម្រងក្តី គ្រឿងក្រអូបក្តី ឬចិត្តក្តី ។ ដោយហោចទៅ សូម្បីតែពួកទេវតា ក៏កាន់យកនូវវត្តគឺការបូជានេះដែរ ដូចយើងបានដឹងរួចមកហើយនៅខាងលើ ។ នៅក្នុងគម្ពីរមង្គលត្ថទីបនី ភាគ១ ដដែលត្រង់មង្គលទី ៣ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងចំពោះពួកទេវតាថា **បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ** ការបូជាចំពោះបុគ្គលដែលគួរបូជា ទាំងឡាយជាមង្គលដ៏ឧត្តម" ។

## ២. កំណើតពុទ្ធចេតិយ

ដូចយើងបានអានរួចមកហើយ ចេតិយគ្មានដើមកំណើតប្រាកដថាកើតចេញពីសម័យណាឱ្យច្បាស់លាស់បានទេ ។ គម្ពីរគ្រាន់តែបញ្ជាក់ថា មានតាំងពីបុរាណកាលមកម្ល៉េះ តែនេះនិយាយចំពោះចេតិយទូទៅ មិនថាចេតិយសម្រាប់ដាក់បុគ្គល ៤ពួក ឬ ក្រៅពីបុគ្គល ៤ពួក ដូចជាសាស្ត្រាចារ្យ ដទៃ ឬបុគ្គលដទៃៗនោះទេ គឺនិយាយក្នុងលក្ខណៈជាទូទៅ ។ ដោយឡែកចំពោះចេតិយ សម្រាប់ដាក់អដ្ឋិធាតុព្រះពុទ្ធវិញ ដែលយើងហៅថាពុទ្ធចេតិយ



www.elibraryofcambodia.org

ដូចចេតិយនាងកោសាតកីទេវតា យកផ្កាននោងព្រៃទៅថ្វាយជាដើម គឺមានដើមកំណើតច្បាស់លាស់ដូចខាងក្រោម ៖

នាកាលដែលព្រះសម្មាសម្ពុទ្ធនៃយើង លោកបានត្រាស់ដឹងក្នុងលោកក្នុងពេលនោះឯងអ្នកកាន់ព្រះពុទ្ធសាសនា និយមរាប់អានទូវត្រៃសរណគមន៍ជាគ្រឹះធំ គឺព្រះពុទ្ធ១. ព្រះធម៌១. និងព្រះសង្ឃ១ គ្មានវត្ថុដទៃជាចេតិយក្នុងព្រះពុទ្ធសាសនា ក្រៅពីត្រៃសរណគមន៍នេះទេ ត្រៃសរណគមន៍ទាំង៣នេះចាត់ទុកជាមេចេតិយនៅក្នុងសាសនា ។ ដើមកំណើតដែលនាំអោយកើតពុទ្ធចេតិយជាដំបូងនោះមានក្នុងរឿងខ្លះពោលទុកមកថា ៖

កាលព្រះពុទ្ធជាម្ចាស់លោកទៅសម្តែងធម៌ប្រោសពុទ្ធមាតា នាឋានតាវតឹង្ស អស់រយៈពេល៣ខែនោះ ព្រះបាទបសេនទិកោសលដែលជាពុទ្ធមាមករាជមានព្រះរាជហឫទ័យនឹកព្រះពុទ្ធអង្គជាខ្លាំង ។ ដោយហេតុដូច្នោះហើយ ព្រះអង្គទ្រង់បញ្ជាឱ្យគេសាងពុទ្ធរូបស្នងព្រះអង្គអំពីខ្លឹមចន្ទន៍ទុកសម្រាប់ព្រះអង្គទត និងគោរពបូជា តំណាងឱ្យអង្គព្រះសម្មាសម្ពុទ្ធ ដោយផ្ទាល់ ។ ព្រះពុទ្ធរូបដែលគេធ្វើតំណាងព្រះអង្គដូច្នេះ ក៏រាប់ថាជាពុទ្ធចេតិយមួយដែរ ព្រោះព្រះពុទ្ធរូបនោះ ចាត់ថារូបដែលបុគ្គលគប្បីបូជាដូចចេតិយដែរ ។



www.elibraryofcambodia.org

ដោយឡែក រឿងរ៉ាវដែលលើកមកខាងលើអំពីដើមកំណើតពុទ្ធចេតិយ បើយើងយកមកពិចារណា តាមគម្ពីរផ្សេងៗទៀតដែលយើងបានស្រាវជ្រាវ ឃើញអំពីដើមកំណើតពុទ្ធចេតិយនេះ ឃើញថាមានសេចក្ដីផ្សេងអំពីគេ ។ ដូច្នេះរឿងរ៉ាវនេះយើងអាចសន្និដ្ឋានបានថា ប្រហែលជារឿងដែលលោកអ្នកប្រាជ្ញណាមួយ លោកតែងក្រោយក្នុងបំណងអ្វីមួយ ដោយហេតុថាៈ បណ្ដា ពុទ្ធចេតិយ ក្នុងពុទ្ធសាសនា នាពេលព្រះអង្គព្រះជន្មនៅនោះ ក្រៅអំពីត្រៃសរណគមន៍ទៅ មិនមានអ្វីផ្សេងទៀតជាគោលឡើយ ។

ពុទ្ធចេតិយ ដែលសំដៅយករូបសង្ឃព្រះពុទ្ធនោះ បើតាមប្រវត្តិការណ៍ពិត គឺគេចាប់ផ្ដើមសាងជាដំបូងឡើង ក្រោយពេលព្រះអង្គបរិនិព្វានទៅហើយក្នុងរវាងពុទ្ធសករាជ ៤០០ ទៅ ៥០០ឆ្នាំ ។ ប្រវត្តិបានបញ្ជាក់បន្ថែមទៀតថា ព្រះពុទ្ធរូបដែលគេធ្វើមុនគេនោះ គឺនៅប្រទេសគន្ធារៈ មានព្រះបាទមិលិន្ទ (ពួកយោនកហៅថា មេនន្ត្រី ) និងព្រះបាទកនិស្កៈ (ព.ស ៦២០) ជាដើមបានឱ្យគេកសាង។ ដោយហេតុថា ប្រទេសទាំងនេះកាលពីមុនគោរពសាសនាដទៃ គេក៏ធ្វើជាទេវរូបផ្សេងៗ គោរពដល់ពេលមកកាន់ព្រះពុទ្ធសាសនាវិញ គេធ្វើរូបព្រះពុទ្ធគោរពដែរ ព្រោះគេមានទំនៀមដូច្នេះជាយូរមកហើយ ។



www.elibraryofcambodia.org

នៅក្នុងមហាបរិនិព្វានសូត្រ និងនៅក្នុងមិលិន្ទប្បញ្ហា ឃើញមានពុទ្ធដីកា ព្រះអង្គសម្តែងទៅកាន់ព្រះអានន្ទថា ម្នាលអានន្ទ! កាលតថាគតគង់ព្រះជន្មនៅ ពួកភិក្ខុសង្ឃជាពុទ្ធសាវ័ក តែងតែនាំគ្នាមកគាល់តថាគត លុះដល់តថាគតបរិនិព្វានទៅ មិនអាចនាំគ្នាមកគាល់តថាគតបានដូចមុនទៀតទេ ។ ម្នាលអានន្ទ ! ដូច្នេះសម្រាប់ ពួកពុទ្ធសាវ័កណាចង់ឃើញតថាគត ចូរនាំគ្នាមកគោរពបូជានៅទីសំខាន់ៗ ទាំង ៤កន្លែងដែលមានជាស្មាមរូចមកហើយនោះ ទុកដូចបានប្រសព្វចំពោះតថាគតដោយផ្ទាល់ដែរ ។ ទីទាំងបួនកន្លែងនោះគឺ :

១-ទីដែលតថាគតប្រសូត នាព្រៃលុម្ពិនី ក្នុងនគរកបិលភស្តុក្នុងឆ្នាំ ច ខែពិសាខ ថ្ងៃសុក្រ មុនពុទ្ធសករាជ ៨០ឆ្នាំ ។

២-ទីដែលតថាគតបានត្រាស់ដឹង ក្រោមដើមពោធិព្រឹក្សក្នុងស្រុកពុទ្ធគយា នាឆ្នាំរកា ខែពិសាខ ថ្ងៃពុធ មុនពុទ្ធសករាជ ៤៥ឆ្នាំ ។

៣-ទីដែលតថាគតសម្តែងបឋមទេសនាក្នុងព្រៃឥសិបតនមិគទាយវ័ន នានគរពារាណសី ក្នុងថ្ងៃអាទិត្យ ១៥កើត ខែអាសាឍ ឆ្នាំរកា មុនពុទ្ធសករាជ ៤៥ឆ្នាំ ។



www.elibraryofcambodia.org

៤-ទីដែលតថាគតបរិនិព្វាន ក្នុងព្រៃសាលវ័ន ដែនកុសិនារា នាថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ មុនពុទ្ធសករាជ ១ថ្ងៃ ។

ទីឋានទាំងបួនកន្លែងខាងលើនេះ ហៅថាពុទ្ធចេតិយដែរ ដោយហេតុថាព្រះពុទ្ធលោកបានអនុញ្ញាតទុក (ទាំង៤នេះចាត់ទុកថា ជាពុទ្ធចេតិយដែលមានមុនគេក្នុងពុទ្ធសាសនាក៏បានដែរ) ។ ដទៃពីទីស្ថានទាំង ៤ នេះទៅនៅមានពុទ្ធចេតិយដទៃ ២ទៀត ដែលកើតមុនគេដែរ ដូចនៅក្នុងគម្ពីរបឋមសម្ពោធិកថា ពោលទុកមកថា :

កាលបូជាព្រះភ្លើងសរីរៈព្រះពុទ្ធនោះពួកមោរិយក្សត្រ នគរបិប្ផលីវ័នយឺតយូរក្នុងការបញ្ជូនទូតទៅឱ្យសូមព្រះធាតុព្រះអង្គពេក ព្រះធាតុក៏បានទៅនគរដទៃ១អស់ ។ ក្នុងពេលនោះឯង ក៏យកធ្យូងដែលថ្វាយព្រះភ្លើងព្រះអង្គ យកទៅធ្វើព្រះចេតិយដាក់ ។

មួយទៀត អាចារ្យទោណ ដែលជាអ្នកចែកព្រះធាតុព្រះអង្គឱ្យទៅនគរដទៃនោះ ខ្លួនឯងជាមេចំណែកឥតបាននឹងគេ ដូច្នេះពេលនោះអាចារ្យទោណ ក៏យកនូវនាឡិសម្រាប់វាល់ចែកព្រះធាតុដែលធ្វើអំពីលោហៈនោះ ទៅធ្វើជាព្រះចេតិយបញ្ចុះ ។

ក្រៅពីពុទ្ធចេតិយខាងលើ នៅមានពុទ្ធចេតិយជាច្រើនទៀតដែល



www.elibraryofcambodia.org

កើតមានជាដំបូងក្នុងគ្រាសម័យពុទ្ធកាលនោះដែរ ។ ចំពោះពុទ្ធចេតិយទាំងនោះរួមមាន ៤កន្លែងធំៗដែលពួកអ្នកកាន់ពុទ្ធសាសនា និយមហៅថាទីពុទ្ធបាដិហារិយ៍គឺ :

១-ទីដែលព្រះតថាគតទ្រង់យាងចុះចាកពីឋានតាវត្តិង្សសួគ៌ នានគរសង្កស្ស ឥឡូវហៅថា សុជានកោត ។

២-ទីដែលព្រះតថាគតធ្វើមហាយមកបាដិហារិយ៍ នានគរសាវត្ថី ឥឡូវហៅថា សាហេតមាហេត ។

៣-ទីដែលតថាគតទ្រង់ទូន្មានដំរីនាឡាគិរី នាក្រុងរាជគ្រឹះ ឥឡូវហៅថា រាជគី ។

៤-ទីដែលតថាគតទូន្មានស្តេចពានរ (ស្វា) នានគរ វេសាលី ឥឡូវហៅថាពេសាហ៍ ។

ពុទ្ធចេតិយនៅមានជាហូរហែ ដ៏ច្រើនទៀតដែលគេធ្វើឡើងនៅតាមប្រទេសដែលកាន់ព្រះពុទ្ធសាសនាតូចធំ ។ ក៏ប៉ុន្តែ នេះគ្រាន់តែលើកយករឿងហេតុខ្លីៗដែលទាក់ទងនឹងដើមកំណើតពុទ្ធចេតិយនេះមុនគេ មកបញ្ជាក់ឱ្យយល់ខ្លះៗ ។ ដូច្នេះ ពុទ្ធចេតិយ គឺកើតមានក្នុងពេលព្រះអង្គទ្រង់នៅអត្តភាពជាព្រះពោធិសត្វខ្លះ ពេលទ្រង់បានត្រាស់ខ្លះ ពេលទ្រង់ដើរប្រោសសត្វខ្លះ និង



www.elibraryofcambodia.org

ពេលទ្រង់បរិនិព្វាន ក្រោយបរិនិព្វានខ្លះ រហូតមកទល់បច្ចុប្បន្ន ។ ៧

បច្ចុប្បន្នពុទ្ធចេតិយ ត្រូវបានពួកអ្នកកាន់អានព្រះពុទ្ធសាសនា តាមប្រទេសនានានាំគ្នាធ្វើជាហូរហែ ។ ក្នុងនោះប្រទេសខ្លះក៏បានព្រះធាតុព្រះពុទ្ធបញ្ចុះទុក ដូចជាសូមចែកពីប្រទេសដែលមាន ប្រទេសខ្លះក៏បានគ្រឿងបរិក្ខារទ្រង់បញ្ចុះ និងប្រទេសខ្លះទៀតធ្វើជារូបព្រះអង្គបញ្ចុះ ឬ គំនូរព្រះអង្គបញ្ចុះដើម្បីទុកធ្វើជាទីសក្ការបូជា ដោយហេតុថាស្រុកភូមិនៅឆ្ងាយពីទីកន្លែងព្រះអង្គ (៩ណ្ណា) ។

## ប្រភេទនៃពុទ្ធចេតិយ

ពុទ្ធចេតិយបើតាមការសិក្សាស្រាវជ្រាវកន្លងមកឃើញថា មានចំនួនច្រើនប្រភេទណាស់ទាំងការបញ្ចុះនូវអដ្ឋិធាតុ ឬ បរិក្ខារព្រះពុទ្ធនិងទាំងរចនាប័ទ្មរូបរាងព្រះចេតិយ ។ ក៏ប៉ុន្តែទោះបីមានចំនួនច្រើនប្រភេទដូច្នេះក៏ដោយតែបើចែកដោយសង្ខេបមានចំនួន ៤យ៉ាងគឺ :

១-ធាតុចេតិយ : ចេតិយសម្រាប់បញ្ចុះព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ឬ សារីរិកធាតុព្រះបច្ចេកពុទ្ធ ព្រះអរហន្ត និងស្តេចចក្រពត្តិ. ក្រៅពីនេះចេតិយសម្រាប់បញ្ចុះធាតុសាមញ្ញជនផ្សេងៗក៏ហៅថាធាតុចេតិយបានដែរ ។



www.elibraryofcambodia.org

២-បរិភោគចេតិយ : ចេតិយសម្រាប់បញ្ចុះគ្រឿងបរិក្ខារ របស់ព្រះសម្មាសម្ពុទ្ធដូចជាវត្ថពន្ធចង្កេះ និងធម្មក្រកជាដើម ។

៣-ធម្មចេតិយ : ចេតិយសម្រាប់តម្កល់ព្រះធម្មក្ខន្ធទាំង ៨៤០០០ ដែលព្រះពុទ្ធលោកបានត្រាស់ដឹង និងទ្រង់បានប្រតិស្ឋានទុកដល់ពួកវេនេយ្យសត្វ (ព្រះត្រៃបិដក) ហៅថាធម្មមន្ទីរសម្រាប់បញ្ចុះ ឬទុកដាក់គម្ពីរដីកាក៏បាន ។

៤-ឧទ្ទេសិកចេតិយ : ចេតិយសម្រាប់ឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធ ដូចជាសម្រាប់ដាក់ព្រះពុទ្ធបដិមា សម្រាប់គូរនូវរឿងព្រះពុទ្ធក្នុងកាលផ្សេងៗ ដូចជាគូររឿងទសជាតក ពុទ្ធប្បវត្តិជាដើម ។

**មូលហេតុនៃធាតុចេតិយ**

នៅក្នុងមហាបរិនិព្វានសូត្រ និងនៅក្នុងគម្ពីរបឋមសម្ពោធិ ត្រង់ធាតុវិភជ្ជនបរិវត្តន៍បានសម្តែងពីមូលហេតុដើមនៃធាតុចេតិយថា កាលព្រះពុទ្ធជាម្ចាស់នៃយើងលោកបរិនិព្វានទៅ ពួកមល្លក្សត្រនៅនគរកុសិនារា ក៏បានចាត់ចែងពិធីថ្វាយព្រះភ្លើងរួចមក ព្រះបរមធាតុរបស់ព្រះអង្គតែចែកជាពីរប្រភេទ គឺព្រះធាតុដែលមិនបាក់បែក១. ព្រះធាតុដែលបាក់បែក១ ។



www.elibraryofcambodia.org

**ធាតុមិនបាក់បែកមាន ៧អង្គគឺ :**

- ព្រះឥណ្ហសធាតុ ឆ្អឹងថ្ងាស ១
- ព្រះបាថាធាតុ ចង្កូមកែវ ៤
- ព្រះអក្កកធាតុ ឆ្អឹងដងកាំបិត ២ ។

**ធាតុដែលបែកបាក់មាន ៣ប្រភេទ**

១/ ព្រះបរមធាតុខ្នាតធំ មានទំហំប៉ុនមួយកំណាត់គ្រាប់សណ្តែកបាយ មានពណ៌ដូចមាស មានចំនួន ៥នាឡិ

២/ ព្រះបរមធាតុខ្នាតកណ្តាលមានទំហំប៉ុនកំណាត់គ្រាប់អង្ករ មានពណ៌ដូចកែវភ្លឺ មានចំនួន ៦នាឡិ

៣/ ព្រះបរមធាតុខ្នាតតូចបំផុត មានទំហំប៉ុនគ្រាប់ស្ពៃមានពណ៌ដូចផ្កាថ្កុលមានចំនួន ៥នាឡិ ។

ព្រះបរមសារីរិកធាតុទាំងពីរប្រភេទធំៗនៅខាងលើនេះ ត្រូវបានប្រតិស្ឋាន (តម្កល់ទុក ឬ បញ្ចុះទុក) ក្នុងទីផ្សេងៗពីគ្នា ។ ព្រះធាតុដែលមិនបាក់បែកទាំង ៧អង្គ ត្រូវបានយកទៅបញ្ចុះទុកក្នុងទីស្ថានទាំង ៧កន្លែងដែរគឺ :

ក-ព្រះចង្កូមកែវស្តាំខាងលើ នៅឋានតាវតឹង្ស



www.elibraryofcambodia.org



www.elibraryofcambodia.org

ខ-ព្រះចង្កូមកែវស្តាំខាងក្រោមនៅសីហឡ

គ-ព្រះចង្កូមកែវឆ្វេងខាងលើនៅដែនគន្ធារៈ

ឃ-ព្រះចង្កូមកែវឆ្វេងខាងក្រោមនៅពិភពនាគ

ង-ឆ្អឹងដងកាំបិតឆ្វេង នៅឋានព្រហ្មលោក

ច-ឆ្អឹងដងកាំបិតស្តាំ មិនប្រាកដទី

ឆ-ឆ្អឹងថ្ងាសមិនប្រាកដទី ។

ព្រះបរមធាតុដែលមិនបាក់បែកទាំង ៧អង្គដែលបានប្រតិស្ឋានទុកក្នុងកន្លែងទាំង៧នេះ សុទ្ធតែធ្វើព្រះចេតិយសម្រាប់ដាក់ដ៏សមគួរមិនមែនយកទៅទុកចោលនោះទេ នេះចាត់ទុកជាមូលហេតុនៃធាតុចេតិយដំបូងដែរ ។ ក្រៅពីព្រះធាតុមិនបាក់បែកទាំង៧អង្គនេះ ទៅនៅមានព្រះធាតុដែលបាក់បែក៣ប្រភេទទៀត ដែលអាចារ្យទោណ បានចែកទៅឱ្យមហាប្រទេសធំៗទាំង៨ ដូចមានឈ្មោះខាងក្រោម :

ក-នគររាជគ្រឹះ (មគធរដ្ឋ) ឥឡូវហៅថា រាជគី ក្នុងរាជ្យព្រះបាទអជាសត្រូវ.

ខ- នគរកបិលភស្តុ (សក្កជនបទ) ឥឡូវហៅថា ភូឥលះ នៅក្នុងរដ្ឋនេប៉ាល់ ព្រះញាតិរបស់ព្រះអង្គ (ព្រះពុទ្ធ) ក្សត្រសក្យរាជ.



www.elibraryofcambodia.org



ព្រះចេតិយមាសដំកល់

ព្រះចង្កូមកែវឆ្វេង, ប្រទេសចិន

www.elibraryofcambodia.org

ព្រះកេសធាតុ (សក់ដែលសល់ពេលបូជារូបមិនឆេះ) ព្រះលោមធាតុ (រោមដែលមិនឆេះ) និងព្រះនខធាតុ (ក្រចកដែលមិនឆេះ) ។ ព្រះកេសធាតុ ដែលព្រះអង្គកាត់ចេញពេលចេញបួស ប្រតិស្ឋានក្នុងចូឡាមណីចេតិយនាឋានតាវតឹង្ស ព្រះកេសធាតុ ៨សរសៃដែលព្រះអង្គដកឱ្យពាណិជពីរនាក់បងប្អូនយកទៅបូជាប្រតិស្ឋានទុកក្នុងសិង្គុត្តរចេតិយ ។ ព្រះធាតុផ្សេងៗទៀតដូចមាននៅខាងលើត្រូវបានពួកទេវតា នាំយកមួយអង្គមួយចំណែក (មួយសរសៃ ឬធ្មេញមួយ រោមមួយ ឬក៏ក្រចកមួយ) ទៅកាន់ចក្រវាឡដទៃៗរៀងៗអង្គ ។

## មូលហេតុនៃបរិភោគចេតិយ

មូលហេតុដែលនាំឱ្យមានបរិភោគចេតិយនេះឡើង ដោយមានរឿងដំណាលថា ពេលព្រះពុទ្ធជាម្ចាស់នៃយើងលោកទៀបបរិនិព្វាន ទ្រង់អនុញ្ញាតទុកឱ្យបរិស័ទគោរពបូជានូវទីសំវេជនីយដ្ឋានធំៗ ៤កន្លែងគឺ :

ក-ទីព្រះអង្គប្រសូត

ខ-ទីព្រះអង្គត្រាស់ដឹង

គ-ទីព្រះអង្គសម្តែងបឋមទេសនា

ឃ-ទីព្រះអង្គបរិនិព្វាន



www.elibraryofcambodia.org



ព្រះចេតិយមាសដីកល់

ព្រះចង្កមកែវ, ប្រទេសភូមា

www.elibraryofcambodia.org

ទីសំវេជនីយដ្ឋានទាំង៤កន្លែងនេះ លោកអ្នកប្រាជ្ញរាប់បញ្ចូលក្នុងប្រភេទបរិភោគចេតិយដោយព្រះអង្គលោកបានអនុញ្ញាតទុក ។ ក្រៅពីទីទាំង៤កន្លែងនេះទៅ នៅមានបរិភាគចេតិយពីរកន្លែងទៀតដែលមានសម្តែងទុកក្នុងគម្ពីរបឋមសម្ពោធិកថា ថាកាលព្រះមល្លក្សត្រថ្វាយព្រះភ្លើងព្រះពុទ្ធសិរីរៈនោះ ពួកមោរិយក្សត្រនៅនគរបិប្ផលិវ័ន ក្របញ្ជូនទូតឱ្យទៅសូមព្រះបរមសារីរិកធាតុនឹងគេ លុះទៅដល់នគរកុសិនារា ព្រះបរមសារីរិកធាតុត្រូវគេចែកអស់ ។ ពេលនោះទូតក៏សម្រេចចិត្តយកធ្យូង (ព្រះអង្គារ) ទៅធ្វើចេតិយដាក់សម្រាប់គោរពបូជា ។ មួយទៀតសម្តែងពីអាចារ្យទោណអ្នកចែកព្រះសារីរិកធាតុ លុះចែករួចក៏យកនាឡិ (តុម្ពៈ) ដែលវាល់ចែកព្រះធាតុដល់គេនោះធ្វើព្រះចេតិយដាក់ទុកក្នុងខេត្ត-ក្រុងកុសិនារា សម្រាប់គោរពបូជាដែរ ។

ដទៃពីទីស្ថានទាំង៦កន្លែងខាងលើនេះទៅ នៅមានទីស្ថាន៤កន្លែងផ្សេងទៀតដែលមានគេនិយមគោរពបូជាដូចទីស្ថានទាំង៦ ខាងលើនេះដែរ ហើយអ្នកប្រាជ្ញរាប់បញ្ចូលក្នុងប្រភេទបរិភោគចេតិយដែរនោះគឺ :

ក-ទីដែលព្រះអង្គចុះពីឋានតាវតឹង្ស

ខ-ទីដែលព្រះអង្គធ្វើមហាយមកបាដិហារិយ៍



www.elibraryofcambodia.org

គ-ទីដែលព្រះអង្គទូន្មានដីរនាឡាគីរី

ឃ-ទីដែលព្រះអង្គទូន្មានស្តេចស្វា ។

មានពុទ្ធបរិក្ខារ១០ទៀត ដែលគេនិយមគោរពរាប់អានថាជា បរិ-ភោគចេតិយដែលបានប្រតិស្ឋានទុកកន្លែងទាំង ១០គឺ :

ក-កាយពន្ធន និងបាត្រ នៅក្នុងនគរបាដលិបុត្រ

ខ-សំពត់ឧទកសាដក នៅក្នុងនគរបញ្ចាលរាជ

គ-សំពត់ធម្មកុន្ទ នៅក្នុងនគរកោសលរដ្ឋ

ឃ-ឈើស្ទន់ នៅក្នុងនគរមិថិលា

ង-សំពត់តម្រងទឹកនៅក្នុងនគរវិទេហរដ្ឋ

ច-កាំបិតកោរ និងបំពង់ម្ជុល នៅក្នុងនគរឥន្ទបត្ត

ឆ-ទ្រនាប់ព្រះបាទ និងស្រោមបាត្រ នៅក្នុងនគរឱសសិព្រាហ្មណ៍-គ្រាម

ជ-គ្រឿងកម្រាលនៅក្នុងនគរមកុដ

ឈ-ត្រៃចីវរ នៅក្នុងនគរភទ្ទរដ្ឋ

ញ-និសីទនសន្ថ័ត នៅក្នុងនគរកុរុរដ្ឋ ។



www.elibraryofcambodia.org

នៅមានបរិភោគចេតិយជាច្រើនទៀត ដែលគេនិយមគោរពដែរ ដូចជាស្នាមពុទ្ធព្រះបាទ៥កន្លែង ដែលទ្រង់ប្រតិស្ឋានពេលមានព្រះជន្មនៅ នោះគឺលើកំពូលភ្នំសុវណ្ណមាលិក១. លើភ្នំសុវណ្ណបពិត១. លើភ្នំសុមនកូដ១. នៅយោនកបុរី១. នៅឆ្នេរស្ទឹងនម្មទា១ រួមត្រូវជា ៥ ។ ក្រៅពីទីទាំង ៥ នេះទៅ នៅមានព្រះពោធិព្រឹក្ស ដែលជាពោធិព្រះអង្គត្រាស់ដឹង និងពូជពោធិនេះ ដែលគេយកដាំតាមទីឬប្រទេសជាច្រើនទៀត លោករាប់ចូលក្នុងបរិភោគចេតិយដែរ ។

**មូលហេតុនៃធម្មចេតិយ**

មូលហេតុដែលនាំអោយកើតនូវធម្មចេតិយឡើង កន្លែងខ្លះពួកអ្នកប្រាជ្ញសម្តែងទុកមកថា ពេលព្រះអង្គជិតបរិនិព្វាន ព្រះអានន្ទត្អែរត្អូញត្អែរទូលព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន ឥតមានពីព្រះអង្គទៅ គ្មានព្រះពុទ្ធជាគ្រូឡើយ ។ ពេលនោះទ្រង់មានពុទ្ធដីកាតបថា ម្នាលអានន្ទ ! អំណើះពីតថាគតបរិនិព្វានទៅ អ្នកកុំសម្គាល់ថាគ្មានព្រះពុទ្ធជាគ្រូ ធម៌ដែលតថាគតសម្តែងហើយ វិន័យដែលតថាគតបញ្ញត្តទុកហើយ នោះទុកជាព្រះពុទ្ធជាគ្រូ ប្រោសសត្វជំនួសតថាគត ដូចកាលតថាគតរស់នៅដែរ ជាពិសេសកាល តថាគតរស់នៅព្រះពុទ្ធមានតែមួយអង្គ ដល់តថាគតបរិនិព្វានទៅ ព្រះពុទ្ធមានរហូតដល់



www.elibraryofcambodia.org

ទៅ ៨៤០០០អង្គ គឺចំនួនធម៌ដែលតថាគតប្រតិស្ឋានទុកហ្នឹងឯង ។

ដូច្នេះអាចសន្និដ្ឋានបានថា កាលមុនអ្នកមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ពួកអ្នកស្រុកឬប្រទេសខ្លះ នៅឆ្ងាយពីធាតុចេតិយ និងបរិភោគចេតិយ ចង់ធ្វើសក្ការបូជាមិនងាយបានទៅ ឬ យូរទើបទៅដល់ ក៏បែកគំនិតធ្វើជាព្រះចេតិយ នៅក្នុងស្រុក ឬ នៅក្នុងប្រទេសខ្លួនឡើង ដើម្បីធ្វើជាសក្ការបូជាតាមសទ្ធាជ្រះថ្លា ។ ចំពោះព្រះធម្មចេតិយ ដែលធ្វើនោះ គេជ្រើសរើសយកព្រះធម៌ជាគោលសំខាន់ ក្នុងព្រះពុទ្ធសាសនា មកចារឹកដាក់ ដូចជាព្រះគាថា ក្នុងព្រះអរិយសច្ចៈជាដើម គឺ :

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ (អហ) តេសញ្ច យោ និរោធោ ឯវំ វាទី មហាសមណោ ។**

ប្រែថា "ធម៌ទាំងឡាយឯណា មានហេតុជាដែនកើនឡើង ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះផង និងពោលនូវសេចក្ដីរលត់នៃធម៌ទាំងឡាយនោះផង ព្រះតថាគតតែងមាន វាទៈមកយ៉ាងនេះឯង" ។

ពេលក្រោយមកទៀត ធម្មចេតិយ បើតាមការស្រាវជ្រាវប្រវត្តិពុទ្ធសាសនាកន្លងមក ប្រហែលក្នុងរវាងពុទ្ធសករាជ ៤៥២ ដែលជាសម័យចារព្រះត្រៃបិដកទុក ក្នុងសាស្ត្រាស្លឹករឹត ពេលនោះឃើញថាព្រះធម្មចេតិយតែង



www.elibraryofcambodia.org

កើតច្រើនជាងមុន ។ ដោយហេតុថា ពេលដែលលោកអ្នកប្រាជ្ញលោកមកចារគម្ពីរព្រះត្រៃបិដកត១គ្នា យកទៅសិក្សា ទៅតាមស្រុក ឬប្រទេសរៀង១ខ្លួននោះគេតែងតែធ្វើទីស្ថានសម្រាប់តម្កល់ទុកយ៉ាងសមរម្យ ។ ដូច្នោះទីដែលដាក់ទុកគម្ពីរបិដកនោះ ក៏រាប់ថាជាធម្មចេតិយមួយដែរ តួយ៉ាងដូចកន្លែងដាក់គម្ពីរព្រះត្រៃបិដកសព្វថ្ងៃជាដើម ។

**មូលហេតុនៃឧទ្ទេសិកចេតិយ**

ឧទ្ទេសិកចេតិយ គ្មានវត្ថុតាងណាមួយជាលក្ខណ៍ច្បាស់លាស់ ដូចចេតិយផ្សេង១ទៀតឡើយ ។ តាមការសន្និដ្ឋាន ឧទ្ទេសិកចេតិយនេះជារបស់ដែលគេសាងឡើងដោយចេតនាល្អ ក្នុងបំណងឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធនៃយើង ។ មួយទៀតឧទ្ទេសិកចេតិយនេះ គ្មានគោលកំណត់ថាត្រូវធ្វើដូច្នេះ ឬដូច្នោះទេ តែលោកបញ្ជាក់ទុកមកថា បណ្តាពុទ្ធចេតិយដែលគេសាងឡើងបើមិនមែនជាធាតុចេតិយ បរិភោគចេតិយ ឬ ធម្មចេតិយទេ គឺជាឧទ្ទេសិកចេតិយហើយ ។

បើតាមការស្រាវជ្រាវឧទ្ទេសិកចេតិយតាំងពីសម័យបុរាណ រហូតមកដល់សព្វថ្ងៃនេះឃើញថា ពួកពុទ្ធបរិស័ទចូលចិត្តធ្វើឡើង ជាងចេតិយបីប្រភេទខាងលើ ព្រោះមិនបាច់ចាំមានអដ្ឋិធាតុ ឬ បរិក្ខាររបស់ព្រះពុទ្ធក៏មិនថ្វី



www.elibraryofcambodia.org

ដោយធ្វើជាព្រះបដិមា តំណាងបញ្ចុះទុកក្នុងចេតិយនោះជាការស្រេច ។ ក៏ប៉ុន្តែ ការធ្វើឧទ្ទេសិកចេតិយ ក្នុងជំនាន់បុរាណភាគច្រើន គេចូលចិត្តធ្វើតែបល្ល័ង្កចោលទទេ មិនមានដាក់រូបបដិមាស្នងព្រះអង្គផងឡើយ ។ ដោយហេតុថា កាលព្រះអង្គលោកគង់ព្រះជន្មនៅនោះ ពួកសាវ័កទាំងឡាយ តែងតែនាំគ្នា រៀបចំនូវអាសនៈសម្រាប់ទទួលព្រះអង្គគង់ និងសម្តែងធម៌ទេសនាដូច្នេះ ទោះបីព្រះអង្គលោកបរិនិព្វានទៅហើយក៏ដោយ ក៏នៅជាប់ទំនៀមនេះរហូត ។

កាលជាខាងក្រោយមកទៀតឧទ្ទេសិកចេតិយ បានប្រែក្លាយពីពេលដើមជាច្រើនអន្លើ ដូចជាគេសាងជារូបស្នងព្រះអង្គដាក់នៅលើបល្ល័ង្កនោះជាដើម ។ ចំពោះពុទ្ធបដិមាដែលលោករាប់ចូលជាឧទ្ទេសិកចេតិយនេះ បើតាមអ្នកប្រាជ្ញប្រវត្តិសាស្ត្រ ត្រាច់រង្គាត់ស្រាវជ្រាវរកបុរាណវត្ថុក្នុងប្រទេសផ្សេងៗមានប្រទេសឥណ្ឌាជាដើម ឃើញថាព្រះពុទ្ធរូបមានច្រើនបែបណាស់ក៏ប៉ុន្តែ បើទុកជាយ៉ាងណាក៏ព្រះពុទ្ធរូបនោះៗប្លែកពីមនុស្សធម្មតាដែលអាចឱ្យអ្នកផងឃើញ ហើយគួរឱ្យស្គាល់បានភ្លាមថាជាព្រះពុទ្ធរូប ។ ព្រះពុទ្ធរូបនៅប្រទេសខ្មែរ ពួកអ្នកប្រាជ្ញប្រចាំប្រទេស បានស្រាវជ្រាវឃើញមាន៨ប្រភេទ គឺ :



www.elibraryofcambodia.org

១-ព្រះពុទ្ធរូបសមាធិ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំ ផ្ងារលើព្រះហស្តឆ្វេង តម្រួតលើព្រះភ្នែនហៅថា វិតកិមុទ្រា [១] ។

២-ព្រះពុទ្ធរូបមារវិជ័យ (ការផ្ចាញ់មារ) គង់ពត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំផ្ទាប់លើព្រះឧរុ (ភ្លៅ) បង្អុលចុះទៅផែនដី ព្រះហស្តឆ្វេងផ្ងារដាក់លើព្រះឧរុ ហៅថា ភូមិស្បូសមុទ្រា ។ ព្រះពុទ្ធរូបនេះ កាលបើគេគូរនៅជញ្ជាំងវិហារ ឬលើផ្ទាំងសំពត់ៈ ឃើញសុទ្ធតែមានរូបពួក ពលមារាធិរាជ កាន់អាវុធគ្រប់ដៃ ។

៣-ព្រះពុទ្ធរូបសម្តែងធម្មចក្រ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំក្តោបម្រាមធ្វើជាវង់មូលដូចជារូបកង់រទេះ, ព្រះហស្តឆ្វេងធ្វើអាការៈដូចព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរុក៏មានហៅថា ធម្មចក្រមុទ្រា ។ ព្រះពុទ្ធរូបបែបនេះកាលបើគេគូរ តែងតែមានរូបបញ្ចវគ្គិយភិក្ខុកំពុងអង្គុយគោរពស្តាប់ធម្មចក្កប្បវត្តនសូត្រ ដែលជាបឋមទេសនា ។

៤-ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសម្តែងធម៌ប្រោសសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មានគង់ពត់ព្រះភ្នែនក៏

---

(១) "មុទ្រា" ជាភាសាសំស្ក្រឹត, បាលីថា "មុទ្ទៈ" ប្រែជាខ្មែរថា "សញ្ញាសម្គាល់ អាការៈ, សណ្ឋាន, ទ្រង់ទ្រាយ" ។



www.elibraryofcambodia.org

មានព្រះហស្តស្តាំវាចេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះហៅថា អភយ-មុទ្រា ។

៥-ព្រះពុទ្ធរូបប្រទានពរ មានព្រះហស្តទាំងពីរសំយុងចុះបែរបាតព្រះហស្តទៅខាងមុខទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មានជាតំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំដោយត្រូវការចង់ជួបចង់ឃើញក្តីក្រាបទូលសូរធមិអាចិចំពោះព្រះអង្គក្តី ហៅថាវរមុទ្រា ។

៦-ព្រះពុទ្ធរូបទ្រង់ឈរឱបបាត្រ ជាតំណាងកាលដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត ហៅថាបាត្រាទានមុទ្រា ។

៧-ព្រះពុទ្ធរូបទ្រង់ផ្ទុំជាតំណាង កាលដែលព្រះអង្គផ្ទុំផ្ទៀងព្រះកាយទៅខាងស្តាំ ព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ដោយទ្រង់ផ្ទុំធម្មតាក្តី ផ្ទុំលើមនោសញ្ចោសនៈជា អនុដ្ឋានសញ្ញាទ្រង់បរិនិព្វានក្តីហៅថា សយនមុទ្រា ។

៨-ព្រះពុទ្ធរូបនាគប្រក់ ជាតំណាងកាលព្រះអង្គគង់នៅភ្នំស្រះមុជ្ជលិន្ទ ដែលក្នុងពេលនោះមានភ្លៀង បង្អុរខ្លាំងមាននាគរាជមកពេនព័ន្ធព្រះអង្គបើកពពារគ្របបាំងលើព្រះអង្គដើម្បីការពារភ្លៀង ។

បណ្តាព្រះពុទ្ធរូបទាំង៨បែបខាងលើនេះ ជារូបដែលយកថ្មមកធ្លាក់ក៏មាន យកចម្លាក់ពុម្ពលាយស៊ីម៉ង់ត៍ នឹងខ្សាច់បោះពុម្ពក៏មាន តែឥឡូវនេះ



www.elibraryofcambodia.org

គេមានតែបោះពុម្ព ។ ព្រះពុទ្ធរូបដែលមានលក្ខណៈផ្សេងគ្នាដូច្នេះ កើតឡើងដោយពួកសិល្បករនៃបុព្វបុរសខ្មែរ ជាពុទ្ធសាសនិកខាងនិកាយថេរវាទ (ហីនយាន) បានរចនាឡើងដោយយកពុទ្ធប្បវត្តិជាគោលធំ ។ ជួនកាលនៅកន្លែងខ្លះ ឬ ពេលខ្លះ គេគូរនូវពុទ្ធរូបទាំង ៨ បែបនេះដាក់នៅលើជញ្ជាំងវិហារក៏មាន គូរលើផ្ទាំងសំពត់ក៏មាន លើផ្ទៃកញ្ចក់ក៏មាន ។ តាមការសង្កេតបច្ចុប្បន្ន ចំពោះការគូរនូវពុទ្ធរូបលើជញ្ជាំងព្រះវិហារជាដើមនេះ អាចលើសពី ៨ បែបក៏មាន គឺគេគូរជាកណ្ឌៗតាមរឿងពុទ្ធប្បវត្តិ ហើយគេគូរតាមរឿងទសជាតកទាំង ១០កណ្ឌផងដែរ ។ ចំពោះរឿងទសជាតកសព្វថ្ងៃ ភាគច្រើនគេនិយមសាងជារូបបដិមា អំពីស៊ីម៉ង់ត៍ដាក់តាមសួនច្បារក្នុងវត្តអារាមក៏មានទាំងអស់នេះសុទ្ធតែរួមចូលក្នុងប្រភេទឧទ្ទេសិកចេតិយទាំងអស់ ។

## ប្រយោជន៍នៃពុទ្ធចេតិយ

ចេតិយក្នុងព្រះពុទ្ធសាសនា ទោះបីលោកចែកទៅមាន ៤ ប្រភេទក៏ដោយ តែបណ្តាចេតិយទាំងអស់នោះគេស្ថាបនាឡើងគឺថ្វាយចំពោះព្រះពុទ្ធតែមួយសម្រាប់ធ្វើសក្ការបូជា ។ ដូច្នេះចេតិយទាំង ៤ ប្រភេទនេះ ហៅរួមដោយខ្លីមកគឺ ពុទ្ធចេតិយ (ចេតិយព្រះពុទ្ធ) ហៅបែបនេះ ឈ្មោះថាបានដល់ចេតិយទាំង ៤ប្រភេទនោះហើយ ។



www.elibraryofcambodia.org




ព្រះសក្យមុនីចេតិយ

www.elibraryofcambodia.org

ចំពោះផលប្រយោជន៍នៃពុទ្ធចេតិយនេះ មានផលដ៏សន្ធឹកសន្ធាប់ដូច្នេះ គឺនឹងបានជាប្រដាប់ដាស់តឿនដល់ចិត្តពួកពុទ្ធសាសនិកជន ទូទៅទាំងអស់ឱ្យនឹករលឹកដល់ព្រះសាស្ដាចារ្យ (ព្រះពុទ្ធ) របស់យើងឱ្យនឹករលឹកដល់សេចក្ដីល្អផ្សេងៗ និងគុណសម្បត្តិដ៏ច្រើនរបស់ព្រះអង្គ និងគុណដែលទ្រង់បានជួយដល់ពុទ្ធបរិស័ទ ជាពិសេសទៀតនោះ ពុទ្ធចេតិយ ជាប្រដាប់សម្រាប់ជួយឱ្យពុទ្ធបរិស័ទ ចម្រើននូវពុទ្ធានុស្សតិបានដោយងាយ ។ ការរលឹកចំពោះព្រះពុទ្ធ ជាផ្លូវដ៏ល្អ អាចនាំឱ្យអ្នកនឹករលឹក ដើរតាមគតិដំណើរដ៏ល្អរបស់ព្រះអង្គបានយ៉ាងស្រួល។ ដូចមានរឿងតំណាលថា មានព្រះថេរមួយព្រះអង្គកំពុងតែបោសសម្អាតនូវទីវត្តអារាមឱ្យបានស្អាតក្នុងពេលនោះឯងស្រាប់តែបានឃើញនូវព្រះពុទ្ធរូប ដែលបាននិមិត្តចំពោះព្រះភ័ក្ត្រលោកនឹករលឹកដល់ព្រះពុទ្ធជាម្ចាស់ហើយចម្រើននូវវិបស្សនាក៏បានលុះនូវអរហត្តផលភ្លាមមួយរំពេច ។

## អានិសង្សបូជាពុទ្ធចេតិយ

នៅក្នុងគម្ពីរមង្គលត្ថទីបនី ភាគ ១ មង្គលទី ៣ ទ្រង់សម្ដែងថាការបូជាដល់បុគ្គលគួរបូជា ជាមង្គលដ៏ឧត្ដម ។ ក្នុងមង្គលនេះ លោកចែកការបូជាជាពីរយ៉ាងគឺ អាមិសបូជា បូជាដោយអាមិស១. បដិបត្តិបូជា បូជាដោយបដិបត្តិ ។ បណ្ដា បូជាទាំងពីរបែបនេះលោកបញ្ជាក់ថា ការបូជាដោយបដិបត្តិជា



www.elibraryofcambodia.org

ការបូជាដ៏ប្រសើរ ព្រោះប្រយោជន៍ ដ៏ធំគឺធ្វើឱ្យពុទ្ធសាសនា មានអាយុកាលយូរតទៅមុខទៀតបាន ។

ក៏ប៉ុន្តែសូមបញ្ជាក់ឱ្យយល់ច្បាស់ទាំងអស់គ្នាឡើងវិញថា ការបូជាដោយបដិបត្តិបូជា ជាបូជាដ៏ប្រសើរ នោះគឺលោកសំដៅយកការបូជារបស់ពួកបព្វជិតតែមួយពួកទេ មិនទូទៅដល់ការបូជាពួកគ្រហស្ថឡើយ ។ មែនពិតបព្វជិតមិនគួរណាគិតដល់អាមិសទាំងឡាយឡើយ ព្រោះលះបង់ចោលហើយ ឬ ចេញចាកហើយ គិតយ៉ាងណា ខំបដិបត្តិឱ្យល្អ នេះជាការប្រពៃណាស់ទៅហើយ ឈ្មោះថា ការបូជាចំពោះព្រះពុទ្ធពេញទីទៅហើយ ព្រោះថាព្រះពុទ្ធទ្រង់បញ្ញត្តអនុញ្ញាតឱ្យពួកបព្វជិតធ្វើបែបនេះ ។

ដោយឡែក ចំពោះគ្រហស្ថពុំបានចេញចាកពីអាមិសទាំងនោះឡើយ ផ្ទុយទៅវិញគឺជាអ្នកខំស្វះស្វែងរកនូវអាមិសទាំងនោះមកបញ្ចូលថែមទៀត។ ដូច្នេះពួកគ្រហស្ថដោយហេតុនៅជាប់ជំពាក់ដោយអាមិសយ៉ាងនេះ វាសមគួរណាស់ក្នុងការបូជានូវអាមិសទាំងនេះ។ ហេតុនេះ បើគ្រហស្ថណាបានបូជាដោយអាមិសទាំងអស់នេះ នោះការបូជាឈ្មោះថាមានផលច្រើនមិនអាចគណនាបានឡើយ ។

**ការបូជាដោយបដិបត្តិរបស់បព្វជិត**

ការបូជាដោយបដិបត្តិរបស់បព្វជិត ក្នុងគម្ពីរព្រះវិន័យ មានពុទ្ធដីកា



www.elibraryofcambodia.org

ក្រាស់ទុកមកថា បើភិក្ខុគោរពបដិបត្តិឱ្យត្រូវតាមវិន័យរបស់ខ្លួនទាំង ២២៧ បើសាមណេរគោរពបដិបត្តិឱ្យត្រូវតាមវិន័យរបស់ខ្លួនសិក្ខាបទ១០ ទណ្ឌកម្ម ១០ នាសនង្គៈ១០ ជាដើម នោះភិក្ខុសាមណេរនោះឈ្មោះថា បូជាសមគួរហើយ គឺបដិបត្តិបូជា ។ ក្រៅពីនេះកាន់នូវវត្តជាច្រើន ដូចជាការចូលទៅកាន់ទីព្រះចេតិយណាមួយបណ្តាពុទ្ធចេតិយទាំង ៤ មានវត្តអារាមជាដើម ដែលលោកហៅថាជាឧទ្ទេសិកចេតិយ ដែលត្រូវបូជាដោយបដិបត្តិដូច្នេះគឺ :

ធម៌ ជាទំនៀមរបស់ភិក្ខុសាមណេរដែលនឹងចូលទៅក្នុងចេតិយដ្ឋានជាទីនឹករលឹកដល់ព្រះសាស្ត្រាចារ្យជាម្ចាស់ ភិក្ខុសាមណេរនោះ ត្រូវសម្តែងអាការៈគោរពបដិបត្តិចំពោះព្រះអង្គយ៉ាងនេះ គឺមិនត្រូវបាំងឆត្រនៅទីនោះ មិនត្រូវពាក់ស្បែកជើងនៅទីនោះ មិនត្រូវឃ្លុំចីវរជាដើម ។ ដទៃពីនេះមិនត្រូវសម្តែងអាការៈផ្សេងៗនៅទីនោះ ដូចជានិយាយខ្លាំងៗ អង្គុយសណ្តូកជើង នោម ឬជុះ ឬក៏ស្តោះទឹកមាត់ -ល- ក្នុងទីលានព្រះចេតិយចំពោះព្រះភក្ត្របដិមា បែបនោះចាត់ទុកការបូជាពុទ្ធចេតិយរបស់បព្វជិតដោយបដិបត្តិ-បូជាចំពោះព្រះសាស្ត្រាចារ្យ ។

**ការបូជាដោយអាមិសរបស់គ្រហស្ថ**

មិនមានគម្ពីរដីកាណាមួយទ្រង់បញ្ជាក់ថា គ្រហស្ថត្រូវបូជាដោយ



www.elibraryofcambodia.org

អាមិសចំពោះព្រះអង្គជាដើមដោយវត្ថុនេះ ឬវត្ថុនោះដោយចំនួនប៉ុណ្ណោះ ឬប៉ុណ្ណោះជាដើមឡើយ ។ ក្នុងគម្ពីរបញ្ជាក់ត្រឹមថាដោយសទ្ធា ឬតាមសទ្ធាដែលបានជ្រះថ្លា ។ ក៏ប៉ុន្តែតាមការស្រាវជ្រាវកន្លងមក ឃើញថាការបូជារបស់ពួកគ្រហស្ថពោលដោយពិស្តារ គឺបច្ច័យទាំង ៤ និងទានវត្ថុទាំង ១០ ។

ក្នុងការបូជានេះ នៅពេល ធ្វើដំណើរទៅទីព្រះចេតិយមានវត្តអារាមជាដើម ក៏ត្រូវតែបូជាដោយបដិបត្តិផងដែរ ដូចជាដោះស្បែកជើង ដោះមួក និងមិនអង្គុយសណ្ដូកយើង ឬ ជុះនោម ស្ដោះទឹកមាត់ជាដើមដែរ ។ បន្ទាប់មកសូមបូជាដោយបច្ច័យទាំង ៤ ឬ ទានវត្ថុទាំង ១០វត្ថុណាមួយ មានគ្រឿងក្រអូប ផ្កាកម្រង ប្រទីបផ្កាលាជាអាទិ៍ បែបនេះចាត់ទុកការបូជាពុទ្ធចេតិយរបស់គ្រហស្ថដោយអាមិសបូជា ចំពោះព្រះសាស្ដាចារ្យ ។

នៅក្នុងគម្ពីរអដ្ឋសាលិនីអដ្ឋកថាអភិធម្មសង្គណី បានលើកជានិទានបញ្ជាក់ពីអានិសង្សបូជាពុទ្ធចេតិយ ដោយសេចក្ដីថា ព្រះពុទ្ធព្រះនាមមង្គលៈព្រះអង្គមានរស្មីផ្សាយចេញ អំពីព្រះកាយ ពុំដូចព្រះពុទ្ធអង្គដទៃៗទៀតទេ គឺព្រះកាយរបស់ព្រះអង្គមានរស្មីផ្សាយចេញអំពីព្រះសារីរៈ ទៅកាន់លោក-ធាតុ១ម៉ឺន. ឬ ហើយតាំងនៅជាធម្មតា១ រហូតទ្រង់បរិនិព្វាន ។

ក្នុងគម្ពីរបានបញ្ជាក់ទៀតថា ក្នុងពេលនោះឯង វត្ថុធាតុទាំងឡាយ



www.elibraryofcambodia.org

មានព្រៃភ្នំក្រំថ្ម ទន្លេ សមុទ្រ ជាដើម ហាក់ដូចជាស្រោចស្រពទៅដោយតប្បារមាស ដោយហោចទៅ សូម្បីឆ្នាំងបាយ ចានក្បានជាដើម ក៏មានពណ៌ដូចមាសដែរ ដោយសារពន្លឺរស្មីនៃព្រះពុទ្ធអង្គនោះឯង ។ ព្រះអង្គមានព្រះជន្ម ៩ម៉ឺនឆ្នាំ ។

ចំណែកព្រះចន្ទ និងព្រះអាទិត្យទាំងឡាយ មិនអាចមានពន្លឺជាងពន្លឺព្រះកាយព្រះអង្គបានឡើយ ។ ដូច្នេះការកំនត់យប់ថ្ងៃពុំប្រាកដ ។ ពួកសព្វសត្វទាំងឡាយត្រាច់ចរកាន់ទីស្ថានផ្សេងៗ ដោយពន្លឺនៃព្រះកាយរបស់ព្រះអង្គដូចជាគេធ្វើដំណើរដោយសារពន្លឺព្រះអាទិត្យ ព្រះចន្ទ ក្នុងពេលសព្វថ្ងៃនេះដែរ ។

សព្វសត្វចំណាំបានថា នេះពេលយប់ នេះពេលថ្ងៃដោយសារផ្កាទាំងឡាយរីកពេលល្ងាច និងសត្វស្លាបទាំងឡាយវាស្រែកក្នុងពេលព្រឹក ។ សូមបញ្ជាក់ថា ពន្លឺព្រះកាយរបស់ព្រះអង្គនេះគឺមិនបាច់ចាំធ្វើបាដិហារិយ៍ ដូចព្រះពុទ្ធផ្សេងៗទេ គឺប្រក្រតីធម្មតា ។ ព្រះពុទ្ធអង្គផ្សេងៗបើចង់ឱ្យភ្លឺដូច្នោះលុះត្រាតែធ្វើបាដិហារិយ៍ លុះចប់នៃការធ្វើពន្លឺដ៏ធំធេងនោះក៏ត្រូវរលត់វិញដែរ។ ព្រះពុទ្ធមង្គលៈ ដែលទ្រង់មានពន្លឺបែបនេះដោយអានិសង្សកាលទ្រង់នៅជាព្រះពោធិសត្វបានបូជានូវប្រទីបចំពោះពុទ្ធចេតិយមួយ ហើយទ្រង់បាន



www.elibraryofcambodia.org

គិតពិចារណាថា គួរអាត្មាអញបរិច្ចាគនូវជីវិតបូជាពុទ្ធចេតិយនេះទ្រង់ក៏រុំនូវសារីរៈទ្រង់ទាំងមូលដូចគេរុំចន្លុះហើយយកភាជន៍កំពស់១ហត្ថ មានមកុដក្បាច់១សែន ពេញដោយសប្បិ (ប្រេងទឹកដោះ) ដាក់ប្រឆេះ១ពាន់ក្នុងសុវណ្ណភាជន៍នោះ បន្ទាប់មកក៏យកភ្លើងដុតឱ្យឆេះឡើងទ្រង់ក៏ដើរប្រទក្សិណនូវពុទ្ធចេតិយនោះអស់រយៈពេល១ រាត្រី ។ លុះព្រឹកឡើងដោយអានិសង្សហុចផលទាន់ហាន់ដល់ទ្រង់ ព្រះកាយរបស់ទ្រង់ពុំឆេះដល់ឡើយសូម្បីតែរោមមួយក៏ពុំឆេះ ។ ឃើញហេតុដ៏អស្ចារ្យបែបនេះទ្រង់ក៏តាំងសេចក្តីប្រាថ្នាឱ្យព្រះកាយរបស់ព្រះអង្គភ្លឺគ្របដណ្តប់អស់ចក្រវាឡជាច្រើន ។

## អានិសង្សការសាងពុទ្ធចេតិយ

ការសាងពុទ្ធចេតិយថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ជាចេតិយបែបណាមួយក៏ដោយ គឺមានអានិសង្សរាប់មិនអស់ ។ ក្នុងការសាងនេះគឺធ្វើទៅតាមសមត្ថភាពដែលអាចធ្វើទៅបាន គ្រឿងសំណង់ទោះបីអំពីខ្សាច់ឬដីក្តី អំពីថ្មក្តី អំពីឈើក្តី និងអំពីឥដ្ឋលាយជាមួយបាយអក្តី...កុំតែសំខាន់ឱ្យតែចិត្តជ្រះថ្លា ។ អានិសង្សក្នុងគម្ពីរពុំឃើញមានប្រាប់ថាបានចំនួនប៉ុណ្ណេះ ឬចំនួនប៉ុណ្ណោះទេ ក៏ប៉ុន្តែដើម្បីជាភ័ស្តុតាង ក្នុងអានិសង្សសាងនូវពុទ្ធចេតិយនេះ ខ្ញុំសូមលើកយករឿង ព្រះសុធាបិណ្ឌិយត្ថេរ មកបញ្ជាក់ដូចខាងក្រោម :



www.elibraryofcambodia.org

រឿងនេះមានសម្តែងទុកក្នុងគម្ពីរមង្គលត្ថទីបនីភាគ១ មកថាមាន កុលបុត្រម្នាក់ បានសន្សំបុណ្យជារឿយៗ អំពីព្រះពុទ្ធមុនៗ មិនដែលខាន ឡើយ ។ ក្នុងពេលព្រះសម្មាសម្ពុទ្ធព្រះនាមសិទ្ធត្ថ ( មិនមែនព្រះពុទ្ធគោតមទេ គឺព្រះនាមព្រះពុទ្ធមុន) ទ្រង់បានត្រាស់ដឹងក្នុងលោក កុលបុត្រនោះក៏បានមក កើតជាមនុស្សលោកទាន់សាសនារបស់ព្រះអង្គ ។ ក៏ប៉ុន្តែពេលព្រះអង្គគង់ ព្រះជន្មនៅកុលបុត្រនោះមិនបានធ្វើបុណ្យអ្វីជាមួយព្រះអង្គទេ លុះទ្រង់ បរិនិព្វានទៅពួកពុទ្ធបរិស័ទទាំងឡាយនាំគ្នាធ្វើធាតុចេតិយបញ្ចុះអដ្ឋិធាតុព្រះ អង្គទុកធ្វើសក្ការបូជា ។

ពេលពួកពុទ្ធបរិស័ទកំពុងនាំគ្នាកសាងព្រះធាតុចេតិយនោះ កុលបុត្រ រូបនោះបានយកកំបោរស ១ដុំទៅដាក់ក្នុងចន្លោះឥដ្ឋ ២ដុំដោយចិត្តជ្រះថ្លាឥត ឧបមា។ ដោយអំណាចបុញ្ញកម្មដែលបានយកកំបោរស ១ដុំដាក់ក្នុងទីចន្លោះ ឥដ្ឋ២ដុំនោះកុលបុត្ររូបនោះ ក៏បានអន្ទោលទៅមកក្នុងទេវលោកនិងមនុស្ស លោកទាំងឡាយអស់ ៩៤កប្បមិនដែលស្គាល់ពាក្យថាវេទនា ។

ក្នុងពេលព្រះពុទ្ធគោតមបរមគ្រូនៃយើងលោកកើតក្នុងលោក កុល បុត្ររូបនោះបានច្យុតចាកទេវលោក មកកើតក្នុងមនុស្សលោកយើងនេះ ក្នុង ត្រកូលមួយដ៏ស្តុកស្តម្ភ ។ លុះពេលដឹងសព្វគ្រប់ហើយ ក៏មានចិត្តជ្រះថ្លាចំពោះ



www.elibraryofcambodia.org



វត្ត កាគុ ស្ថិតនៅខេត្ត ថាន់ហ្ស៊ី ប្រទេស ភូមា
មានចេតិយ ២៧៤៨ចេតិយ

www.elibraryofcambodia.org

ព្រះសាស្ត្រាចារ្យនៃយើង ហើយក៏សូមចូលបួសក្នុងសំណាក់ព្រះអង្គ ។ មិនយូរប៉ុន្មានក៏បានសម្រេចនូវព្រះអរហន្ត ។ ព្រះអរហន្តអង្គនេះមាននាមប្រាកដថា ព្រះសុចាបិណ្ឌិយត្ថេរ ។ ព្រះថេរអង្គនេះ ព្រះអង្គប្រកាសពីការធ្វើបុណ្យពីពេលមុន មិនឥតអំពើដោយព្រះគាថាដូច ខាងក្រោម :

"បុគ្គលណាមួយ ក៏មិនអាចដើម្បីនឹងរាប់បុណ្យរបស់បុគ្គលអ្នកបូជានូវបុគ្គលដែលគួរបូជាទាំងឡាយ គឺព្រះពុទ្ធ ឬក៏ពួកសាវ័កជាអ្នកកន្លងនូវធមិជាគ្រឿងធ្វើឱ្យយឺតយូរបានហើយជាអ្នកឆ្លងផុតសេចក្ដីសោក និងការខ្សឹកខ្សួលបានហើយ ថាបុណ្យនេះមានប្រមាណប៉ុណ្ណោះឯងបានឡើយ ។ មួយទៀត អ្នកណាមួយក៏មិនអាចដើម្បីនឹងរាប់បុណ្យរបស់បុគ្គលអ្នកបូជានូវបូជារហបុគ្គលទាំងឡាយនោះ ជាអ្នកមិនញាប់ញ័រដោយលោកធមិជាអ្នករលត់ ហើយជាអ្នកមិនមានភ័យមកអំពីទីណាៗថា : បុណ្យនេះមានប្រមាណប៉ុណ្ណោះឯងដូច្នេះបានឡើយ ។ មួយទៀតបុគ្គលណាក្នុងលោកនេះគប្បីគ្រប់គ្រងនូវភាពជាឥស្សរៈ (ជាធំ) នៃទ្វីបទាំង៤ ទ្រព្យទាំងអស់របស់បុគ្គលនោះៗ រមែងមិនដល់នូវចំណែកទី ១៦ នៃការបូជានេះឡើយ ។ ខ្ញុំមានចិត្តជ្រះថ្លាហើយ បានយកដុំកំបោរ (បាយអ) ដាក់ហើយក្នុងចន្លោះនៃដុំឥដ្ឋក្នុងព្រះចេតិយរបស់ព្រះពុទ្ធទ្រង់ព្រះនាមសិទ្ធត្ថ ព្រះអង្គប្រសើរជាងនរជន ។



www.elibraryofcambodia.org

ខ្ញុំបានធ្វើហើយនូវអំពើណាមួយក្នុងកាលណោះ ព្រោះអំពើនោះ ទើបខ្ញុំមិនដែលបានស្គាល់ទុគ្គតិរហូតអស់ ៩៤កប្ប អំពីភទ្ទកប្បនេះទៅ នេះគឺជាផលនៃការជូសជុល ។ ក្នុងកប្បទី ៣០ អំពីភទ្ទកប្បនេះឯង ខ្ញុំបានកើតជាស្តេចចក្រពត្តិ ទ្រង់មានព្រះនាមថា ព្រះបាទបដិសង្ខារៈ ជាអ្នកដល់ព្រមហើយដោយរតនៈ៧ប្រការ រហូតអស់ ១៣លើក. ធម៌ទាំងឡាយនេះគឺ បដិសម្ភិទា៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ. ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

ដូច្នេះការបានសេចក្តីសុខដ៏ប្រសើរក្នុងភពតូច ភពធំទាំងឡាយ ក្នុងសង្សារវដ្តនេះក្តី និងការបានជាទីបំផុតជាតិ នូវភាវៈជាព្រះអរហន្ត គឺព្រះនិព្វានក្តី របស់ព្រះសុធាបិណ្ឌិយត្ថេរ គឺសម្រេចដោយបុណ្យដែលលោកបានចូលរួមសាងនូវពុទ្ធចេតិយចំណែកដ៏តូចទុកមកហើយពីពេលមុន។ ហេតុនេះក្នុងការបំពេញនូវបុណ្យ គួរតែនាំគ្នាបំពេញនូវបុណ្យផ្នែកនេះទុកមួយចំណែកដែរ ដើម្បីជាប្រយោជន៍ជាច្រើនក្នុងភពតូចនិងភពធំ និងព្រះនិព្វានជាទីបំផុតជាតិ ។

### ៣. បកិណ្ណកពុទ្ធចេតិយ

ការរៀបរាប់អំពីពុទ្ធចេតិយទាំង ៤ ប្រភេទធំៗនៅខាងលើ នេះ



www.elibraryofcambodia.org

គឺជាថាវរវត្ថុដ៏ពិតដែលសិល្បករស្ថាបនាឡើងអំពីវត្ថុធាតុ ផ្សេងៗដូចជាអំពីថ្ម ឬអំពីឈើ ឬក៏អំពីឥដ្ឋ និងឬក៏អំពីស៊ីម៉ង់ត៍ជាដើម ដែលជាថាវរវត្ថុស្ថិតនៅបានយូរអង្វែងសម្រាប់ធ្វើសក្ការបូជាតៗគ្នាទៅមុខទៀត ។ ថាវរវត្ថុទាំងនេះឃើញថាគេបានស្គាល់ជាទូទៅអស់ទៅហើយ ដទៃពីថាវរវត្ថុទាំងនេះ នៅមានចេតិយមួយប្រភេទទៀតដែលគេរាប់ថា ជាប្រភេទនៃពុទ្ធ-ចេតិយដែរនោះគឺ វាលុកចេតិយ ឬភ្នំខ្សាច់ ជាវត្ថុដែលគេធ្វើឡើងអំពីខ្សាច់សុទ្ធ ។

ចំពោះវាលុកចេតិយ ឬភ្នំខ្សាច់ខាងលើនេះ គ្មានលក្ខឋាននៅក្នុងគម្ពីរព្រះត្រៃបិដកច្បាស់លាស់ទេ បើមានគឺមាននៅក្នុងគម្ពីរ ឬសូត្រដែលគេតែងឡើងក្រោយៗវិញ តែទោះបីដូច្នោះក្តីបវេណីនៃការសាងពុទ្ធចេតិយប្រភេទនេះ ក៏មិនមែនទើបតែមានក្នុងគ្រាបច្ចុប្បន្នដែរ ។ គោលបំណងនៃការសាងវាលុកចេតិយនេះ បើតាមការស្រាវជ្រាវនូវក្បួនចាស់ៗ ឃើញថាមានគោលធំៗ ពីរយ៉ាងគឺ :

ក-សម្រាប់ពួកអ្នកប្រាជ្ញជាន់ខ្ពស់ដែលលោកមានសេចក្តី ជឿកម្មនិងផលរបស់កម្មច្បាស់លាស់ លោកមិននិយមធ្វើបែបនេះទេ តែបើសិនជាលោក



www.elibraryofcambodia.org

ធ្វើវិញ គឺបំណងដើម្បីឧទ្ទិសថ្វាយជាតំណាងព្រះចូឡាមណីចេតិយដោយត្រង់ៗតែម្តង ។

ខ-សម្រាប់ពួកអ្នកជឿនូវកម្មផលល្អាក់ល្អម ធ្វើឡើងក្នុងពេលបុណ្យចូលឆ្នាំក្តី បុណ្យចម្រើនព្រះជន្មក្តី ពេលមានជម្ងឺឈឺក្តី បំណងធំដើម្បីរំដោះគ្រោះថ្នាក់ភយន្តរាយផ្សេងៗដែលខ្លួនកំពុងជួបប្រទះ ឬមិនទាន់ជួបប្រទះមិនឱ្យកើតមានដល់ខ្លួន ឬឱ្យវិនាសចេញពីខ្លួន ។

ឯខ្នាតសាងវាលុកចេតិយនេះ លោកគ្មានកំណត់ថាត្រូវធ្វើ តូចធំទាបខ្ពស់ ដូច្នេះៗនោះទេ ជាពិសេសគឺអាស្រ័យនៅលើទឹកចិត្ត អ្នកធ្វើប៉ុណ្ណាតាមតែចិត្តចង់។ ក៏ប៉ុន្តែចាំបាច់ត្រូវមានភ្នំធំមួយ នៅចំកណ្តាលហើយមាន ភ្នំតូចៗ ៤ព័ទ្ធជុំវិញគ្រប់ទិសទាំង៤។ នៅជុំវិញភ្នំគេមានធ្វើរាជវ័តតុបតែងលំអស្លឹកដូង ឬ ស្លឹកទន្សែ ឬ រាជវ័តធ្វើ អំពីឬស្សី និងឈើជាដើម ជា ៤ ជ្រុងមានទ្វារចេញចូលតាមទិសធំទាំង ៤ ។

ចំពោះគ្រឿងប្រដាប់ វាលុកចេតិយ ឬភ្នំខ្សាច់នោះបើតាម បែបដើមបានពោលទុកក្នុងតម្រាមកថាគេយកទៀនធូបផ្កាភ្ញីទៅ អុជនឹងដោតដាក់បូជា ។ ក្រៅពីនេះ គេយកទង់ធ្វើអំពីក្រដាសពណ៌ស ទៅដោតបូជានៅលើកំពូលវាលុកចេតិយ ឬ ភ្នំខ្សាច់នោះ ក្នុងវាលុកចេតិយ ឬ ភ្នំខ្សាច់មួយគេ



www.elibraryofcambodia.org

ដោតទង់បី១ដូចគ្នា រួចយកសំពត់ស ប្រវែងប្រមាណ ១ម៉ែ ៥០ទៅពានាពាក់ឆៀងនូវវាលុកចេតិយឬភ្នំខ្សាច់នោះ យកម្ជុលខ្ទាស់ម្ខាងជាប់គ្នាហើយគេសូត្របាលី បំបួស ។

ការបំបួសវាលុកចេតិយ ឬ ភ្នំខ្សាច់នេះ កន្លែងខ្លះគេហៅថាអធិដ្ឋាន គឺអធិដ្ឋានវាលុកចេតិយ ឬ ភ្នំខ្សាច់នោះឱ្យទៅជា តំណាងព្រះចូឡាមណីចេតិយឯឋានត្រៃត្រឹង្សសួគ៌ ។ បាលីដែល បំបួស ឬ អធិដ្ឋាននោះថា ដូច្នេះ "**ឥមំវាលុកចេតិយំ ចូឡាមណី ចេតិយំ អធិដ្ឋាមិ** " (ប្រែថា) ខ្ញុំសូមតាំងចិត្តអធិដ្ឋានព្រះចេតិយខ្សាច់នេះឱ្យជារបស់តំណាងឱ្យព្រះចូឡាណីចេតិយ ។ បាលីបំបួស ឬ អធិដ្ឋានមួយប្រភេទទៀតថា **ឱកាស មយំ ភន្តេ ឥមំវាលុក ចេតិយំ គិរិបព្វតំ បរិមណ្ឌលំ បកាសិត ឧទ្ទិស្ស ចូឡាមណីចេតិយំ មង្គលំ អធិដ្ឋាមិ**

**ទុតិយម្បិ**.....................

**តតិយម្បិ**.....................៕

ការបំបួស ឬ អធិដ្ឋានវាលុកចេតិយ ឬ ភ្នំខ្សាច់ក្នុងពិធី ផ្សេង១ដូចជាបុណ្យចូលឆ្នាំ ឬ បុណ្យភ្ជុំបិណ្ឌជាដើមនៅពេលចប់ កម្មវិធីហើយ តែងតែផ្សឹកវិញ បើមិនផ្សឹកចេញទេ បុគ្គលណាមួយ ដើរកន្លង ឬ ជាន់ ឬក៏ទៅ



www.elibraryofcambodia.org

រំលោយនឹងត្រូវមានបាបដល់ខ្លួន ។ ឯការរៀកវាលុកចេតិយ ឬ ភ្នំខ្សាច់នោះ ដោយបទបាលីថា **ឥមំ វាលុកចេតិយំ បច្ចាក្ខាមិ** (ប្រែថា) ខ្ញុំសូមដកនូវ ការអធិដ្ឋាន វាលុកចេតិយនេះ ។

**កន្លែងសាងវាលុកចេតិយ**

ចំពោះការធ្វើនូវវាលុកចេតិយឬភ្នំខ្សាច់ត្រូវធ្វើនៅទីណា? នឹងក្នុងវេលាណា ?.......មិនមានគោលកំណត់ច្បាស់លាស់ ។ បើតាមបុរាណបណ្ឌិតធ្លាប់ធ្វើកន្លងមកគឺទីណាដែលមានខ្សាច់ល្អ ឬសម្បូរខ្សាច់គេក៏ធ្វើនៅទីនោះ។ នៅក្នុងព្រះរាជពិធីទ្វាទសមាស "ភាគ ១" ឃើញមានសេចក្តីចែងទុកថាមុនពេលថ្ងៃបុណ្យចូលឆ្នាំថ្មី ខ្មែរ ខាងក្រុមយុទ្ធនាធិការ បានដឹកនាំខ្សាច់សពីភ្នំខ្សាច់ស នៅក្នុង ស្រុកលង្វែក ខេត្តកំពង់ឆ្នាំងមកទុកក្នុងព្រះបរមរាជវាំងសម្រាប់ ថ្វាយព្រះករុណាទ្រង់ធ្វើវាលុកចេតិយ ឬ ភ្នំខ្សាច់ ។ តែបើតាមទំនៀមដែលគេនិយមធ្វើភាគច្រើនគឺក្នុងវត្តអារាម ដោយគេប្រារព្ធ នូវហេតុសំខាន់១ពីរយ៉ាងគឺ :

ក-ព្រោះវត្តជាទីប្រជុំនៃមហាជន

ខ-ដើម្បីឱ្យបានដីចូលវត្ត ។



www.elibraryofcambodia.org

ក្រៅពីវត្តក៏មានគេធ្វើខ្លះៗដែរ តែភាគតិច ឬ ពុំសូវមាន ។ វាលុកចេតិយ ឬភ្នំខ្សាច់ត្រូវធ្វើក្នុងពេលណា សំនួរនេះ បើយើងនាំគ្នាសង្កេតមើលតាមរឿងប្រារព្ធដើមមានឡើងខ្លះ ដូចជាមហាសំការសូត្រជាដើម មានកំណត់ដូច្នេះថា ការពូនភ្នំវាលុកចេតិយ ឬ ភ្នំខ្សាច់ គឺត្រូវធ្វើក្នុងសង្ក្រាន្តចូលឆ្នាំថ្មី ។ នៅប្រទេសកម្ពុជា ក្រៅពីធ្វើក្នុងពេលបុណ្យចូលឆ្នាំថ្មីមានធ្វើខ្លះក្នុងពេលភ្ជុំបិណ្ឌ ពេលបុណ្យចម្រើនព្រះជន្មពេលមានជម្ងឺតម្កាត់ជាដើម ។

**មូលហេតុនៃវាលុកចេតិយ**

បើតាមសាស្ត្រាស្លឹករឹត ដែលខ្មែរយើងតែងទុកជាយូរមក ហើយឱ្យឈ្មោះថា អានិសង្សវាលុកចេតិយ ឃើញមានលោកបញ្ជាក់ទុកមកថា ការសាងវាលុកចេតិយ ឬភ្នំខ្សាច់គឺធ្វើតៗគ្នាតាំងតែពីយូរលង់ណាស់មកហើយ តែពុំមានប្រភពច្បាស់លាស់ទេ ។ នៅក្នុងសាស្ត្រា "អានិសង្សវាលុក ចេតិយ" នោះដដែលលោក ប្រាប់ពីមូលហេតុដើម ដោយលើករឿង ៣ មកបញ្ជាក់ដូចខាង ក្រោម :

និទានទី ១ តំណាលពីព្រះពោធិសត្វនាមបារិកជា ឈ្មួញសំពៅ ។ នាសម័យមួយ បារិកបើកសំពៅទៅជួញបានប្រទះឃើញ ផ្ទុកខ្សាច់សល្អនៅតាមឆ្នេរសមុទ្រ ក៏បបួលពួកពាណិជដែលទៅជួញជាមួយគ្នា បើកសំពៅ



www.elibraryofcambodia.org

ឆ្មៀងចូលទៅចតនៅទៀបផ្នូកខ្សាច់នោះ ហើយនាំគ្នាពូនធ្វើជាវាលុកចេតិយ ឧទ្ទិសជាតំណាងចូឡាមណីចេតិយដែលបញ្ចុះព្រះចង្កូមកែវរបស់ព្រះពុទ្ធអំពី បុរាណសឹងប្រតិស្ឋាននៅឋានត្រៃត្រឹង្សទេវលោក ស្រេចហើយពួកពាណិជ ទាំងនោះ ក៏បេះយកផ្កាឈើបូជាដើរប្រទក្សិណ ៣ជុំហើយនាំគ្នាចុះសំពៅ បើកចេញទៅជួញតទៅទៀត ។ បារិកពោធិសត្វ និងពួកឈ្មួញអម្បាលនោះ លុះ រំលាយខន្ធទៅហើយ បានទៅកើតជាទេវបុត្រនៅឋានសួគ៌ ជាច្រើនជាតិ លុះច្យុតពីឋានសួគ៌មកកើតក្នុងមនុស្សលោកបាន ជា ស្តេចចក្រពត្តិ និងជា ស្តេចឯករាជ្យជាច្រើនជាតិ នឹងត្រារាប់ពុំបានឡើយ ក្នុងទីបំផុតបារិកពោធិ សត្វ ក៏បានត្រាស់ជាព្រះពុទ្ធដោយអំណាចផលានិសង្ស ដែលបានសាងវាលុក ចេតិយ ។

និទានទី ២ តំណាលពីនាយនេសាទម្នាក់ (មិនប្រាកដក ឈ្មោះ) ថានាយនេសាទនោះធ្វើតែបាបសម្លាប់សត្វបរិភោគតាំងពីតូចរហូតដល់ចាស់ មិនដែលបានធ្វើបុណ្យដល់ម្តងសោះ ។ នាថ្ងៃមួយមានភិក្ខុសង្ឃ១រូប នឹក អាណិតនាយនេសាទខ្លាំងណាស់ ក៏គិតរកឧបាយឱ្យបានសាងបុណ្យ កុសលខ្លះ លុះគិតដូច្នេះលោកក៏ឃ្លុំចីវរកាន់ យកនូវបាត្រដើរទៅរង់ចាំផ្លូវនាយនេសាទ ថ្ងៃនោះវេលាព្រឹកនាយនេសាទលីលំពែង១ និងពុនបាយ១កញ្ចប់ចេញទៅ



www.elibraryofcambodia.org

ព្រៃ ដើម្បីស្វែងរកសត្វមកចិញ្ចឹមជីវិតដូចកាលសព្វដង ។ លោកភិក្ខុក៏ដើរទៅសុំបិណ្ឌបាត្របាយកញ្ចប់ ដំបូងនាយនេសាទប្រកែកដាច់ថា មិនព្រមប្រគេន តែភិក្ខុនោះចេះតែទទូចសុំ អត់មិនបានក៏រំលែកបាយ១ ពំនូតប្រគេនទៅ ។

ក្រោយនោះកាលនាយនេសាទរំលាងខន្ធស្លាប់ទៅ ត្រូវពួកយមបាល ឬយមភូបាល ចាប់យកខ្លួនទៅសួររកចម្លើយអំពីរឿងកាលនៅក្នុងមនុស្សលោកនោះ បានធ្វើបុណ្យខ្លះដែរឬ? នាយនេសាទតបថា មិនបានធ្វើបុណ្យអ្វីធ្វើតែបាបតាំងពីតូចមក ។ ពួកយមបាលក៏នាំគ្នាចាប់បោះទៅក្នុងរណ្ដៅភ្លើងនរកតែមិនឆេះត្រឡប់ជាខ្ចាត់ចេញមកវិញ យមបាលទឹកឆ្ងល់ក៏សួរបញ្ជាក់ថែមទៀតទទួលនាយនេសាទក្រឡេកទៅ ឃើញអណ្ដាតភ្លើងមានសម្បុរដូចចីវរលោកសង្ឃ ក៏នឹកឃើញដល់ទានដែលខ្លួនបានធ្វើ ទើបឆ្លើយថាកាលនៅក្នុង មនុស្សលោកបានធ្វើទានបាយមួយពំនូកដល់ភិក្ខុ ១រូបដែរ ។ ពួកយមបាលប្រាប់ថាបើដូច្នេះអ្នកឯងត្រូវបានទៅកើតឯឋានសួគ៌មួយអាទិត្យលុះដល់ក្នុងថ្ងៃ ទី ៨ យើងនឹងយកខ្លួនមកឱ្យទទួលទោសនៅឋាននរកនេះវិញ ។ ក្នុងមួយរំពេចនោះវិញ្ញាណរបស់នាយនេសាទ ក៏បានទៅកើតឯឋានសួគ៌ឈ្មោះថា អន្ទំលោកង្សិទីទេវបុត្រ មានវិមានទំហំ១២យោជន៍ បរិបូណ៌



www.elibraryofcambodia.org

ទៅដោយសម្បត្តិ និងស្រីទេពកញ្ញាបម្រើត្រៀបត្រាមាននាងសុវណ្ណឱវិជា ទេពី។ អន្ទំលោកង្សិនីទេវបុត្រសោយសម្បត្តិបាន ៦ថ្ងៃ ក៏នឹកឃើញដល់បណ្ដាំយមបាល ក៏កើតសេចក្ដីទុក្ខទោមនស្សពន់ប្រមាណ ហើយចូលទៅដេកនាងសុវណ្ណឱវិ ឃើញដូច្នេះក៏ចូលទៅសួរ អន្ទំលោកង្សិនីទេវបុត្រក៏រ៉ាយរ៉ាប់រឿងប្រាប់តាំងអំពីដើមរហូតដល់ចប់ ។ នាងសុវណ្ណឱវិលួងលោមថា បើដូច្នេះសូមព្រះអង្គ កុំជាទុក្ខទោមនស្សឡើយ ត្បិតព្រះពុទ្ធសម្ដែងថា "ទោះអ្នកណាធ្វើបាប អម្បាលម៉ានក្ដីបើចង់ឱ្យរួចអំពីកម្មពៀរដែលបានធ្វើហើយគប្បីសាងវាលុកចេតិយធ្វើបុណ្យឆ្លងហើយ នឹងរួចអំពីកម្មពៀរនោះ ហោង " ហេតុនេះសូមព្រះអង្គធ្វើតាមព្រះពុទ្ធបន្ទូលនេះចុះ ទៀងជារំដោះរួចចាកកម្មពៀរជាមិនខាន។ អន្ទំលោកង្សិនីទេវបុត្របានឮ ដូច្នោះមានចិត្តសោមនស្សណាស់ ទើបចាត់ការសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងហើយស្រេចក្នុងរវាងថ្ងៃទី៧ នោះឯង។ លុះដល់ថ្ងៃទី៨ វេលាព្រឹកព្រហាមពួកយមបាលក៏ទៅដល់ស្រែកហៅរកខ្លួនអន្ទំលោកង្សិនីទេវបុត្រឱ្យចេញមក គ្រានោះអន្ទំលោកង្សិនីទេវបុត្រ គេចមុខចេញ នាងសុវណ្ណឱវិ ចេញមកទទួលនិយាយជាសំនួនតបយមបាលថា យើងមិនព្រមបើកឱ្យស្វាមីទៅទេ ព្រោះស្វាមីយើងបានសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងរួចហើយ បាបកម្មទាំង



www.elibraryofcambodia.org

ពួងក៏ជ្រះអស់អំពីខ្លួនហើយ តែបើនៅតែត្រូវការយកខ្លួនទៅធ្វើទោស ក៏ចូររាប់គ្រាប់ខ្សាច់ ១ពែងនេះ បើរាប់អស់ទើបយកទៅបាន ។ យមបាលតបថាមិនសល់ក្រអ្វីទេ ការរាប់ខ្សាច់១ពែងប៉ុណ្ណោះ ហើយក៏នាំគ្នា រាប់តាំងពីព្រឹករហូតដល់ថ្ងៃត្រង់ គ្រាប់ខ្សាច់ដែលយកចេញអំពីពែង រាប់ដាក់ទៅខាងក្រៅទៅជាគំនរយ៉ាងធំកម្ពស់ស្មើចុងត្នោត តែឯគ្រាប់ខ្សាច់នៅក្នុងពែងគង់នៅដដែលគ្មានស្រកស្រុតទៅណាសោះ ពួកយមបាល ទាល់ចំណេះនឹងរាប់ ហើយក៏នាំគ្នាត្រឡប់ទៅយមលោកវិញ ។ ចំណែកអន្ទំលោកង៉ៀនីទេវបុត្របាននៅសោយសម្បត្តិក្នុងទេវលោកអស់ កាលជាអង្វែងមកទៀតមិនបានទៅសោយទុក្ខក្នុងនរក ដូចដែលយមបាលកំណត់ទុកនោះទេ ។ ទាំងនេះក៏ដោយអំណាចផលានិសង្ស ដែលបានកសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងដូចពោលមកហើយ ។

និទានទី ៣ ដំណាលពីរឿងចៅកម្ទិលខ្សាច់ ។ ថាមានក្មេងម្នាក់ចេះតែទៅកន្ទ្រាខ្សាច់លេង ទៅទីផ្នូកខ្សាច់ក្បែរផ្ទះ ហើយដេកនឿយលេងនៅទីផ្នូកខ្សាច់នោះរាល់ៗថ្ងៃ ប្រឡាក់ទៅដោយដីខ្សាច់ប្រលូសតែរាល់ថ្ងៃ ទាល់តែគេហៅថា "ចៅកម្ទិលខ្សាច់" ។

នាថ្ងៃមួយ ព្រះឥន្ទ្របើកទិព្វចក្ខុមើល មកឃើញចៅកម្ទិលខ្សាច់ពួន



www.elibraryofcambodia.org

ភ្នំខ្សាច់ដូច្នេះ ក៏ចាត់ឱ្យនាងទេពធីតា ១ អង្គចុះមកធ្វើជាប្រពន្ធចៅកម្ទិលខ្សាច់ ។ ដំបូងចៅកម្ទិលខ្សាច់ប្រកែកមិនព្រមយក ដោយថ្លែងថាខ្លួននៅក្មេងណាស់មិនចេះរកស៊ីចិញ្ចឹម ។ នាងទេពធីតាទើបទៅរកម្ដាយ ឪពុកចៅកម្ទិលខ្សាច់ ថ្លែងប្រាប់ថា ខ្លួនជាទេពធីតាព្រះឥន្ទប្រើឱ្យចុះមកធ្វើជាប្រពន្ធចៅកម្ទិលខ្សាច់ ។ មាតាបិតាឃើញនាងទេពធីតាក៏ពេញចិត្តដោយនាងមានរូបឆោមល្អ ទើបសំណេះសំណាលលួងលោមចៅកម្ទិលខ្សាច់ទាល់តែព្រមយក ។ ចៅកម្ទិលខ្សាច់ តាំងពីបាននាងទេពធីតាជាប្រពន្ធហើយ ខ្លួនប្រាណក៏ស្អាតបាតផូរផង់ល្អ ជាងពីមុនមកឆ្ងាយណាស់ ដោយនាងទេពធីតាជួយថែសម្អាតទាំងសមរម្យគ្នា នឹងប្រពន្ធនោះណាស់ ទាល់តែល្បីកើរ្តិ៍ឈ្មោះទៅថា ចៅកម្ទិលខ្សាច់បាននាងទេពធីតាជាភរិយាល្អសមគ្នាណាស់ ។ គ្រានោះពួកមន្ត្រីមានសេនាបតីជាដើម ក៏បានទៅពិនិត្យមើលឃើញពិតដូចពាក្យគេដំណាលមែន ។ ទទួលវេលានោះ ស្ដេចម្ចាស់ផែនដីសុគតគ្មានអ្នកទទួលរាជសម្បត្តិគ្រប់គ្រងផែនដី គេគិតឃើញថា ចៅកម្ទិលខ្សាច់សមគួរជាព្រះរាជាម្ចាស់ផែនដីបុស្សុក ក៏ទៅត្រូវលើចៅកម្ទិលខ្សាច់ ទើបគេនាំគ្នាអញ្ជើញទៅសោយរាជ្យ ព្រមទាំងនាងទេពធីតា ។



www.elibraryofcambodia.org

ដោយអាងលើរឿងដែលបានតែងទុកមកទាំង៣ ខាងលើនេះជាហេតុដើម ហើយទើបបុរាណលោកយកបវេណីនេះជាទិដ្ឋានុគតិត១គ្នារហូតមកទល់បច្ចុប្បន្ន ។ ក៏ប៉ុន្តែបច្ចុប្បន្នមានកន្លែងខ្លះពុំសូវឃើញធ្វើទេ ។ ដោយឡែកមានកន្លែងខ្លះទៀត គេច្រើនតែបែកគំនិតថ្មី គេមិនយកខ្សាច់ពូនដូចពេលមុនទេ គឺគេយកអង្ករ ឬ ស្រូវនោះប្រគេនព្រះសង្ឃ ឬ លក់យកលុយកសាងថាវរវត្ថុផ្សេង១ដល់ជាតិ ឬ សាសនាបាន ។

## អានិសង្សវាលុកចេតិយ

ការសាងនូវវាលុកចេតិយ ដែលភាគខ្លះ គេនិយមហៅថាភ្នំខ្សាច់ដោយហេតុគេយល់ឃើញថា គំនរខ្សាច់ដែលគេគរនោះមានសភាពដូចភ្នំបើពោលតាមដោយអានិសង្ស តាមគតិបុរាណបណ្ឌិត ឃើញថាមានផលច្រើន ។ ដូចយើងបានដឹងរួចមកខ្លះ១ហើយ អំពីអត្ថន័យរបស់ចេតិយប្រភេទនេះ គឺគេសាងឧទ្ទិសថ្វាយចំពោះព្រះចូឡាមណីចេតិយ នៅឋានតាវតឹង្សដែលបញ្ចុះព្រះកេសធាតុ(សក់) និងក្រោយពុទ្ធបរិនិព្វានពួកទេវតាយកព្រះ បាថាធាតុ(ព្រះចង្កូមកែវ)បញ្ចុះបន្ថែមទៀត ។

ការអធិដ្ឋាន និង ការថ្វាយបង្គំនូវវាលុកចេតិយជាដើមនេះ ថ្វីត្បិតតែវាមិនអាចជួយបំបាត់នូវអវិជ្ជាឱ្យជ្រះស្រឡះចេញពីខន្ធសន្តានយើងគេបាន



www.elibraryofcambodia.org

កំដោយ តែការសន្ទតិធ្វើជាបូជនីយវត្ថុដ៏ប្រសើរទាំងនេះ អាចនាំឱ្យយើងយល់ពីសភាវៈវត្ថុផ្សេងៗនៅក្នុងលោកនេះថាជា **អនិច្ចំ ទុក្ខំ** និង **អនត្តា** ជាដើមបានហើយថែមទាំងធ្វើឱ្យយើងកាន់តែដឹងច្បាស់នូវអ្វីជាហេតុ នូវអ្វីជាផល ដែលព្រះពុទ្ធលោកសម្ដែងទុកមក។ ដូចយើងបានដឹងរួចមកហើយ ក្នុងមហាបរិនិព្វានសូត្រ ទ្រង់ត្រាស់ថា បុគ្គលណាមួយយកវត្ថុផ្សេងៗបូជាព្រះចេតិយ ឬ ចិត្តបានជ្រះថ្លាក្ដី សេចក្ដីល្អទាំងនេះអាចឱ្យសម្រេចបាននូវប្រយោជន៍ និង សេចក្ដីសុខផ្សេងៗបាន ។

ដោយឡែកនៅក្នុងមហាសំការសូត្រ ក្នុងគម្ពីរ សុត្តជាតក និទាន-និសង្សដែលតែងជាភាសាមគធ សម័យក្រោយ ខ្មែរយើងបានប្រែជាខេមរភាសា មានជានិទានបញ្ជាក់ ទុកជាអានិសង្សមកថា :

មានពតិមានថា នាសម័យមួយសម្ដេចព្រះបរមសាស្ដា គង់នៅវត្តជេតពន ក្នុងនគរសាវត្ថី ។ គ្រានោះ ជាវេលាសង្ក្រាន្តដាច់ឆ្នាំចាស់ចូល ឆ្នាំថ្មីវេលារសៀល ព្រះបាទបសេនទិកោសលព្រមដោយរាជបរិពារ ស្ដេចព្រះរាជដំណើរ.ទាមាត់ស្ទឹង ទ្រង់ឱ្យជម្រះទីមួយអន្លើស្អាតហើយឱ្យធ្វើ បារាំបិទបាំងដោយវាំងនន និងតែងតាំងអាសនៈសម្រាប់ព្រះពុទ្ធជាម្ចាស់ និងព្រះសាវ័កទាំងឡាយនៅខាងក្នុងបារាំស្រេចហើយ ទ្រង់ឱ្យមនុស្សនៅចាំរក្សាស្ដេចក៏



www.elibraryofcambodia.org

ត្រឡប់ចូលព្រះរាជវាំងវិញ។ លុះព្រឹកឡើង ស្តេច ព្រមដោយរាជបរិពារ ទៅគាល់ព្រះដ៏មានព្រះភាគក្រាបទូលថា បពិត្រព្រះអង្គជាលោក នាយក សូមព្រះអង្គសង្គ្រោះដល់ខ្ញុំព្រះអង្គ ព្បិតវេលានេះ ជាឱកាសចូលឆ្នាំថ្មី ខ្ញុំព្រះអង្គសូមនិមន្តព្រះសាស្តា ព្រមទាំងព្រះសាវ័កទៅឯឆ្នេរដែលទ្រង់ឱ្យរៀបចំទុកពីថ្ងៃមុន។ ទ្រង់និមន្តឱ្យចុះស្រង់ក្នុងស្ទឹង លុះស្រង់ស្រេចហើយ ទ្រង់និមន្តឱ្យទៅគង់នៅព្រះបារាំ ហើយទ្រង់ឱ្យអង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន។ កាលព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ព្រះរាជា ព្រមដោយមហាជនបានបរិច្ចាគយ៉ាងធំ និងទ្រង់រក្សាសីល៥ ទ្រង់ព្រះសណ្តាប់ធម៌ទេសនាថែមទៀត ។

គ្រានោះព្រះរាជាក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គជាលោកនាយក កាលព្រះអង្គបរិនិព្វានទៅហើយ ដល់រដូវសង្ក្រាន្តចូលឆ្នាំថ្មី (ម្តង១) នោះតើខ្ញុំព្រះអង្គគួរគប្បីនឹងបំពេញកុសលអ្វី? ត្រាស់តបថា កាលព្រះតថាគតបរិនិព្វានទៅហើយ ក្នុងឱកាសដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីនោះ ចូរទ្រង់សាងវាលុកចេតិយនៅទីឆ្នេរស្ទឹង ទន្លេ ហើយនាំយកគ្រឿងសក្ការៈមានទៀនធូប គ្រឿងក្រអូប និងផ្កាជាដើមមកបូជាចុះ។ ព្រះរាជាក្រាបទូលសួរតទៅថា បពិត្រព្រះអង្គលុះបុគ្គលអ្នកដែលបានកសាងកុសលឯណា



www.elibraryofcambodia.org

នីមួយ ដូចយ៉ាងសាងវាលុកចេតិយក្តី សាងសីមាក្តី ដាំដើមពោធិព្រឹក្សក្តី សាងព្រះវិហារក្តី តើនឹងមានផលានិសង្សដូចម្តេចដែរឬទេ? ត្រាស់ថាម្ដេច ទ្រង់ត្រាស់ដូច្នេះ បុគ្គលនីមួយៗទោះជាស្ត្រីក្តី ជាបុរសក្តី ជាព្រាហ្មណ៍ក្តី ជាគហបតីក្តី ជាវេស្សក្តី ជាសូទ្រក្តី ជាក្សត្រក្តី ជាភិក្ខុក្តី ជាអ្នកទុគ៌តក្តី ជាអ្នកស្តុកស្តម្ភក្តី ជាបណ្ឌិតក្តី ជាពាលក្តី បានកសាងវាលុកចេតិយក្តី សាងសីមាក្តី ដាំដើមពោធិព្រឹក្សក្តី សាងព្រះវិហារក្តី ឬយកដីខ្សាច់ទៅរោយរាយនៅលានព្រះចេតិយក្តី បុគ្គលអប្បាលនោះ នឹងបានប្រាសាទកែវនៅជាផលានិសង្ស ។ ព្រះរាជាក្រាបទូលសួរតទៅទៀតថា បពិត្រព្រះអង្គជាលោកនាយកជនទាំងពួងដែលនាំគ្រឿងឧបករណ៍ សម្រាប់បូជាមកបូជា និងដោះលែងសត្វតិរច្ឆានទាំងឡាយ មានម្រឹគ និងត្រី អណ្តើកជាដើម និងរក្សាបញ្ចសីល នោះតើនឹងបានផលានិសង្សដូចម្តេច? ត្រាស់តបថា បុគ្គលបានដោះលែងសត្វដែលត្រូវទុក្ខទោសស្លាប់ឱ្យត្រឡប់បានសុខវិញ ឬរក្សាបញ្ចសីលក្តី រមែងបានផលានិសង្សច្រើន។ មហាបពិត្រ បុគ្គលណានីមួយបាននាំយកគ្រឿងឧបករណ៍ មានបាយទឹក សំពត់ ប្រទីប ទៀន ធូប គ្រឿងក្រអូប និងផ្កាជាដើមទៅបូជាវាលុកចេតិយបុគ្គល អម្បាលនោះ រមែងបានផលច្រើន បានអានិសង្សច្រើន ដូច្នេះហើយត្រាស់ ព្រះគាថានេះថា ៖



www.elibraryofcambodia.org

**វាលុកចេតិយំ កត្វា យេ នរា អថ នារិយោ អន្នំ បានំ វត្ថំ បុប្ផំ គន្ធវិលេបនាទីនិ អាហរិត្វា ចេតិយំ បូជំ កត្វា សទ្ធាយ ច អានិសង្សំ មហប្ផលំ ទ្វេ កុលេ ឧប្បជ្ជន្តិ ខត្តិយេ ចាបិ ព្រាហ្មណេ ហីនេ កុលេ ន ជាយន្តិ វាលុកស្ស ឥទំ ផលំ ។ សំក្រាន្តមារុយ្ហ គច្ឆតិ នវសំវច្ឆរេ យេ ច តិរច្ឆានេ សត្តេ មោចេន្តិ ទីឃាយុកា សុខវឌ្ឍាតិ ។**

នរនារី អ្នកដែលបានសាងវាលុកចេតិយហើយយកបាយទឹក សំពត់ នូវផ្កា គ្រឿងក្រអូប គ្រឿងលាបជាដើម ទៅបូជាព្រះចេតិយនោះ ដោយសទ្ធា នរជនពួកនោះ រមែងបានផលានិសង្សច្រើន រមែងទៅកើតចំពោះក្នុងត្រកូលពីរ គឺក្នុងត្រកូលក្សត្រ ឬក៏ក្នុងត្រកូលព្រាហ្មណ៍ រមែងមិនទៅកើតក្នុងត្រកូលថោកទាបឡើយ នេះជាផលនៃការសាងវាលុកចេតិយ ។

ចំណែកអ្នកដែលបានដោះលែងសត្វទាំងឡាយ ក្នុងឱកាស សង្ក្រាន្តចូលឆ្នាំថ្មីនោះ រមែងមានអាយុយឺនយូរ រមែងបានសេចក្តីសុខច្រើន ។

មហាបពិត្រអ្នកឯណាបានផ្ងូតទឹកឱ្យមាតាបិតាក្តីឱ្យ គ្រូឧបជ្ឈាយាចារ្យក្តី បានរក្សាសីលក្តី បានឱ្យទានក្តី បានអុជប្រទីបបូជាព្វដ៍អាកាសក្តី បានលើកទង់បូជាក្តី បានជីកស្រះក្តី បានសង់ស្ពានក្តី បានធ្វើផ្លូវថ្នល់ក្តី បានធ្វើ



www.elibraryofcambodia.org

ទង់ឆត្របូជាក្តី ឬបានឱ្យបាយទឹក យាគូជាទានក្តី ព្រះចតុលោកបាល (ស្តេចទេវតាទាំង៤អង្គដែលនៅប្រចាំក្នុងលោក) នឹង កត់នាមរបស់អ្នកធ្វើបុណ្យអម្បាលនោះទុកនឹងផែនមាសហោង។ បើអ្នកឯណាមិនធ្វើបុណ្យកុសល មិនស្គាល់គុណនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើតែបញ្ចវេរា (មានសម្លាប់សត្វជាដើម) ព្រះចតុលោកបាល នឹងកត់ឈ្មោះនៃអ្នកធ្វើបាប អម្បាលនោះទុកនឹងស្បែកឆ្កែហោង ។

មហាបពិត្រកាលតថាគត កើតជាពោធិសត្វនៅឡើយ បានដោះលែងសត្វទាំងឡាយឱ្យរួចទៅ ពួកសត្វតិរច្ឆានដែលបានសោយទុក្ខ ទៀបអស់ជីវិតហើយ រមែងត្រឡប់បានសោយសុខវិញ ។

តថាគតរមែងមានប្រាថ្នានៅជានិច្ចថា សត្វទាំងឡាយ ដែលដល់នូវទុក្ខហើយចូរប្រាសចាកទុក្ខចុះ សត្វទាំងឡាយដែលដល់នូវភ័យហើយចូរប្រាសចាកភ័យចុះ! សត្វទាំងឡាយដែលដល់នូវសោកហើយចូរប្រាសចាកសោកចុះ ! ដូច្នេះតថាគត ប្រាថ្នាយ៉ាងណាៗ សត្វទាំងឡាយក៏ បានសម្រេចយ៉ាងនោះៗ ក្នុងកាលដែលទៀបដល់នូវ សេចក្តីស្លាប់ដ៏សម្បើមនោះ ។

**រួមអានិសង្ស**

ព្រះបរមសាស្តាកាលនឹងសម្តែងអានិសង្ស ដែលបានកសាងបុណ្យ



www.elibraryofcambodia.org

កុសលក្នុងឱកាសដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីដោយពិស្តារ ទើបត្រាស់ព្រះគាថានេះថា៖

**សុណាថ ទិន្នានេ បុញ្ញំ សំក្រាន្តសំវច្ឆរេសីលំ នហានផលេ នេវ រាជា ហោតិ មហិទ្ធិកោ សត្តរតនសម្បន្នោ នារីវរគណាកិណ្ណោ ចតុរង្គេន សម្បន្នោ សព្វសុខោ លព្ភន្តសេ ។ សំក្រាន្តសំវច្ឆរេ យេ តិរច្ឆានេ មោចេន្តិ កុក្កុដា អាកុច្ឆា ច ឆិជា មច្ឆាកច្ឆបព្យាតិរច្ឆាន ផលេនេវ ទីឃាយុកា សុខាវហា អរោគា ច សទា ហោន្តិ សព្វភយា (១) បមុត្តា ។ សព្វសុខា លភិស្សន្តិ សីសនហាបនសច្ចស្ស យត្ថ យត្ថ គតេ ជាតា អភិរូបា បាសាទិកា វិសុទ្ធិកាយសម្បន្នា ឧស្សនបិយា មនាបាតិក្ខប្បញ្ញា វិសារទា សុត្តន្តវិនយធរា បិដកធរា បារគូ ទីឃាយុកា សទាហោន្តិ បុត្តទារា ច ឧត្តមា ញាតិកា ឧត្តមាវរា សីសនហានស្សិទំ ផលន្តិ ។**

សូមមហាបពិត្រ ចូរទ្រង់ព្រះសណ្តាប់រឿងអានិសង្សនៃបុណ្យកុសលដោយពិស្តារ អ្នកដែលបានផ្ងូតទឹកឱ្យមាតាបិតា គ្រូឧបជ្ឈាយ៍ អាចារ្យ ឬ



www.elibraryofcambodia.org

ព្រះសង្ឃក្នុងឱកាសសង្ក្រាន្តនោះ រមែងបានជាស្តេចម្ចាស់ ផែនដី មានឫទ្ធិ ដ៏មហិមា សម្បូណ៌ដោយរតនៈ ៧ ប្រការ ដេរដាស ដោយពួកនាងនារី សឹង មានរូបឆោមដ៏ល្អ និង សម្បូណ៌ដោយចតុរង្គសេនា ជាអ្នកបាននូវសេចក្តី សុខគ្រប់យ៉ាង ។

អ្នកដែលបានលែងសត្វតិរច្ឆាន ដូចយ៉ាង មាន់ ទន្សង បក្សី ត្រី អណ្តើក (ជាដើម) ដោយអំណាចផលដែលបានលែងសត្វអម្បាលនោះ អ្នក នោះរមែងជាអ្នកមានអាយុយឺនយូរ ជាអ្នកបានសុខច្រើនឥតមានរោគភ័យ មកបៀតបៀនក្នុងកាលទាំងពួង រមែងបានសោយតែសុខ ដោយផលានិសង្ស ដែលបានស្រង់ទឹកព្រះសង្ឃ អ្នកនោះទោះទៅកើត ក្នុងភពណា១ក្តី រមែង មានរូបឆោមល្អជាទីជ្រះថ្លាដល់អ្នកបានឃើញ ជាអ្នកមានសម្បុរកាយផូរផង់ ជាទីគាប់ចិត្តជាទីគួរឱ្យមើល ជាអ្នកមានប្រាជ្ញាស្រួច ជាអ្នកក្លាហាន ជាអ្នក ទ្រទ្រង់នូវព្រះសូត្រ និង ព្រះវិន័យ ជាអ្នកទ្រទ្រង់ និង ចេះចប់ព្រះត្រៃបិដក ជាអ្នកមានអាយុយឺនយូរ រាល់១ជាតិជាអ្នកមានបុត្រ ភរិយា នូវគណញាតិ សុទ្ធតែជាអ្នកឧត្តមថ្លៃថ្លា ។ ទាំងនេះជាផល្លានិសង្ស នៃការផ្ងូតទឹកក្នុង ឱកាសចូលឆ្នាំ ។



www.elibraryofcambodia.org

ព្រះដ៏មានព្រះភាគអ្នកតែងសង្គ្រោះ លោកបានទ្រង់សម្តែងនូវធម៌ដ៏ប្រសើរដល់ទេវតា និង មនុស្សទាំងឡាយ ដោយប្រការដូច្នេះ ។ អំពីកាលនោះមក តែដល់រដូវចូលឆ្នាំ មនុស្សទាំងឡាយតែងនាំគ្នាដោះ លែងសត្វផ្សេងៗ តែងនាំគ្នាធ្វើបុណ្យផ្សេងៗ មនុស្សអម្បាលនោះ រមែងបានទទួលផលានិសង្សដ៏ច្រើន ។ មហាជនអ្នកបានស្តាប់ព្រះធម្មទេសនានេះរមែងកើតបីតិសោមនស្សរមែងផ្សព្វផ្សាយដោយបីតិ ដោយអំណាចព្រះគាថា របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ដោយប្រការដូច្នេះ ។ កាលចប់ព្រះធម្មទេសនាហើយ មហាជនដ៏ច្រើនបានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

អានិសង្សវាលុកចេតិយ ឬ ភ្នំខ្សាច់ដែលមាននៅក្នុងមហាសំការ-សូត្រ ដូចបានសរសេរនៅខាងលើនេះ ទោះបីក្នុងសូត្រទាំងមូល ជាការតែងក្រោយពុទ្ធកាលក៏ដោយ តែលោកអ្នកតែង លោកពោលសរសើរជាខ្លាំងនូវបុណ្យដែលបានអធិដ្ឋានដីខ្សាច់ធម្មតាទៅជាវាលុកចេតិយនៅឋានតាវតឹង្សពិភពនោះ ។ នៅក្នុងធម្មបទដ្ឋកថា ត្រង់ ពុទ្ធវគ្គ មានសម្តែងអំពីការថ្វាយបង្គំពុទ្ធចេតិយនៅឋានទេវតាលោកសួគ៌ ដូចក្នុងសំការសូត្រដែរ ក៏ប៉ុន្តែខុសគ្នាត្រង់ការមិនធ្វើជាវាលុកចេតិយ ឬ ភ្នំខ្សាច់ គឺលើកដៃថ្វាយបង្គំឧទ្ទិសឆ្ពោះទៅកាន់ចេតិយក្នុងឋានទេវលោកនោះតែម្តង ។ ព្រះពុទ្ធជាម្ចាស់



www.elibraryofcambodia.org

ទ្រង់ត្រាស់សរសើរ ចំពោះការគោរពសំពះដូច្នេះថា ជាការប្រពៃ ។ សេចក្តីក្នុងរឿងនោះ មានដូចតទៅ :

ព្រះបរមសាស្តា ទ្រង់បានយាងចេញពីក្រុងសាវត្ថី ទៅកាន់ក្រុងពារាណសី ព្រមជាមួយនឹងភិក្ខុសង្ឃជាច្រើនអង្គ លុះព្រះអង្គយាងមកដល់សាលាមួយនៅពាក់កណ្តាលផ្លូវក្បែរផ្ទះព្រាហ្មណ៍ម្នាក់ឈ្មោះ តោទេយ្យៈ ទ្រង់បានឈប់សម្រាកនៅក្នុងទីនោះ ហើយទ្រង់ត្រាស់ឱ្យ អានន្ទហៅព្រាហ្មណ៍ ដែលកំពុងតែភ្ជួរស្រែឱ្យគាត់មករកព្រះអង្គ ។

ព្រាហ្មណ៍នោះ មកដល់ហើយមិនបានថ្វាយអភិវាទចំពោះព្រះសាស្តា តែថ្វាយចំពោះទេវស្ថានប៉ុណ្ណោះ ស្រេចហើយក៏ឈរនៅស្ងៀម ។ ព្រះសាស្តាត្រាស់សួរថា "ព្រាហ្មណ៍ ! អ្នកសម្គាល់ទេវស្ថាននេះថាជា អ្វី?" ព្រាហ្មណ៍ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ! ទូលព្រះបង្គំ ស្គាល់ថា ជាចេតិយស្ថាន តាមប្រពៃណីរបស់ពួកទូលបង្គំទាំងឡាយ ។" ពេលនោះព្រះអង្គទ្រង់បានត្រាស់សរសើរថា "ព្រាហ្មណ៍ ! អ្នកគោរព សំពះនូវទេវស្ថាននេះ គឺជាការប្រពៃហើយ ។

ពួកភិក្ខុទាំងឡាយ បានឮហើយ ក៏កើតសេចក្តីសង្ស័យឡើងថា "ព្រោះហេតុអ្វីហ្ន៎? បានជាព្រះសាស្តាទ្រង់ត្រាស់សរសើរការអភិវាទទេវស្ថាន



www.elibraryofcambodia.org

នេះវិញ ។

ព្រះសាស្តាកាលទ្រង់ដោះស្រាយនូវសេចក្តីសង្ស័យរបស់ពួកភិក្ខុទាំងនោះ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! ទេវស្ថាននេះ ជាចេតិយមាសរបស់ព្រះពុទ្ធ "ហើយទ្រង់ត្រាស់សម្តែងនូវពុទ្ធានុភាព ដើម្បីឱ្យចេតិយមាសនោះប្រាកដដល់ភិក្ខុទាំងឡាយ និងប្រជាជនទាំងអស់ក្នុងទីនោះ ។ ពួកប្រជាជនបាននាំគ្នាធ្វើនូវសក្ការបូជាចំពោះ ចេតិយមាសនោះ ដោយសេចក្តីជ្រះថ្លាជាទីបំផុត ។

ព្រះសាស្តាទ្រង់សម្តែងផលានិសង្សនៃការធ្វើសក្ការបូជាដោយ ព្រះគាថាទាំងនេះថា "**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេតេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ នសក្កា បុញ្ញំ សង្ខាតុំ ឥមេត្តម្បិ កេនចិ**" ។

អ្នកណាក៏មិនអាចរាប់នូវបុណ្យរបស់អ្នកដែលបូជាដល់បុគ្គល ដែលគួរបូជា គឺព្រះពុទ្ធ និង សាវ័ករបស់ព្រះពុទ្ធទាំងឡាយផង ជាអ្នកកន្លងនូវបបញ្ចធម៌ គ្រឿងយឺតយូរបានហើយ ជាអ្នកមានសេចក្តីសោកសៅ និងសេចក្តីខ្សឹកខ្សួលអស់ហើយ ឬ របស់បុគ្គលដែលបូជានូវបុគ្គលដែលគួរ បូជា



www.elibraryofcambodia.org

ទាំងនោះដែលបានបរិនិព្វានទៅហើយ ជាអ្នកមិនមានភ័យអំពីទីណា១ ដោយការរាប់វិធីណាមួយក៏ដោយថា "បុណ្យនេះ មានប្រមាណប៉ុណ្ណេះ" ។

រឿង សុវណ្ណចេតិយដែលមាននៅក្នុងធម្មបទដ្ឋកថា ត្រង់ពុទ្ធវគ្គដូចបានលើកមកសរសេរនៅខាងលើនេះឃើញថា ក្នុងសម័យពុទ្ធកាលក៏មានគេនិយមថ្វាយបង្គំនូវទេវស្ថានចេតិយ ដូចក្នុង **មហាសំការសូត្រ** ដែលបុរាណតែងទុករហូតមកដល់បច្ចុប្បន្ននេះដែរ តែខុសត្រង់ថាមិនបានធ្វើវាំលុកចេតិយ ឬភ្នំខ្សាច់។ ពួកបុរាណាចារ្យ លោកបង្កើតការធ្វើវាំលុកចេតិយ ឬភ្នំខ្សាច់ទុកជាបវេណីមកនេះ គោលបំណងដើម្បីអធិដ្ឋានឱ្យទៅជាទេវស្ថានចេតិយ ដូចសម័យពុទ្ធកាលដែរ។ ដូច្នេះការធ្វើជាវាំលុកចេតិយ ឬភ្នំខ្សាច់ហើយថ្វាយបង្គំតែម្តងក្តី គឺបានផលស្មើគ្នាទាំងអស់ ព្រោះចិត្តបាន ឧទ្ទិសត្រង់ស្មោះចំពោះព្រះចេតិយនៅក្នុងតាវតឹង្សពិភពនោះដូច១គ្នា ។

ក៏ប៉ុន្តែការបានធ្វើជាវាំលុកចេតិយ ឬភ្នំខ្សាច់ បើគិតពិចារណា ទៅដូចជាគួរម្យ៉ាងដែរ បែបនេះទុកដូចជាកសិណសម្រាប់ចងចិត្តដើម្បី មិនឱ្យចិត្តរវើរវាយទៅក្នុងទីផ្សេង១ គឺឱ្យចិត្តនោះឆ្ពោះទៅរកទេវស្ថានចេតិយតែមួយ។ បែបនេះជាការអប់រំចិត្តដែលគ្មានទីបំផុត ឱ្យមូលតែមួយទៅលើព្រះចេតិយនោះ ដោយមានវាំលុកចេតិយ ឬភ្នំខ្សាច់ នៅចំពោះមុខជាទីតាំង



www.elibraryofcambodia.org

នៃចិត្ត ។

## ៤. ការប្រែក្លាយនៃពុទ្ធចេតិយ

ពុទ្ធសករាជកន្លងទៅបាន ២៣៤ ឆ្នាំ ព្រះពុទ្ធសាសនា បានបែកទៅជានិកាយពីរគឺ : ហីនយាន១ មហាយាន១ ជាក់ប្រាកដក្នុងពេលធ្វើតតិយ-សង្គាយនារួច (ព.ស ២៣៤) ។ ទោះបីដូច្នេះក្តី ក៏នៅតែមានឥទ្ធិពលទៅកាន់ប្រទេសនានាក្នុងពិភពលោកបានដែរ គឺតាមរយៈអ្នកកាន់នូវលទ្ធិទាំងពីរនេះនាំទៅផ្សាយរៀងៗខ្លួន។ តែបែបនេះចែកជាមុខសញ្ញាខុសៗគ្នាគឺហីនយាន១ មហាយាន ១ ។

### ក. ហីនយាន

ព្រះពុទ្ធសាសនា ខាងហីនយាន មានព្រះសង្ឃមួយព្រះអង្គ ព្រះនាមមោគ្គលីបុត្រតិស្សត្ថេរ ជានាយក។ មានព្រះរាជាមួយព្រះអង្គនាមធម្មាសោករាជ ជាអ្នកឧបត្ថម្ភសាសនាខាងហីនយាន មានជួយឧបត្ថម្ភការធ្វើតតិយសង្គាយនា អស់រយៈពេល ៧ខែ ជាដើម ។

ក្នុងការផ្សាយព្រះពុទ្ធសាសនាផ្នែកនិកាយ ហីនយាននេះ ព្រះបាទធម្មាសោក បានបញ្ជូននូវសមណទូតឱ្យនិមន្តទៅគ្រប់តំបន់ ទាំងឡាយក្នុងពិភពលោកដើម្បីទៅផ្សព្វផ្សាយព្រះពុទ្ធសាសនាក្នុង តំបន់ខ្លះៗ ដែលព្រះពុទ្ធ



www.elibraryofcambodia.org

សាសនាពុំទាន់ចូលទៅដល់ និងទៅកាន់បច្ចឹមប្រទេសក្នុងដែនដីក្រិក និង បណ្ដាប្រទេសជាច្រើនទៀតដូចជា អាស៊ី ភាគអាគ្នេយ៍ ឬសុវណ្ណភូមិជាដើម ។

ចំណេរកាលខាងក្រោយមកទៀត នៅក្នុងរជ្ជកាលព្រះបាទ កនិស្កៈ រវាងសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ ព្រះពុទ្ធសាសនាបែប ហីនយាន កាន់តែធំទូលំទូលាយឡើងទៅទិសនានា ដូចជាដល់អាណាចក្រក្រិក ដល់ទ្វីបអាហ្វ្រិក ភាគឧត្តរ ។ ខាងអាស៊ី កណ្ដាលគឺដល់ ប្រទេសចិន ប្រទេសម៉ុងហ្គោល ប្រទេសកូរ៉េ ប្រទេសជប៉ុន ។ ខាង ទិសឧត្តរ គឺដល់ប្រទេសទីបេត៍ ។ ខាង ទិសទក្សិណ គឺដល់កោះលង្កា និងឆ្លាយហួសដល់សុវណ្ណភូមិផងទៀត ។

## ខ. មហាយាន

ចំណែកព្រះពុទ្ធសាសនា ខាងមហាយានវិញ មានអាចារ្យជាចំឈ្មោះ អរិយមុដ្ឋិ ដែលជាអ្នកកាន់នូវធម្មវិន័យធូរ ហើយយកព្រះពោធិសត្វជាធំ ដូចជា លោកេតិស្វរៈ ឬអវលោកេតិស្វរៈ, មញ្ជុស្រី, សមន្តមុខ។ល។ និកាយនេះ ផ្សាយព្រះពុទ្ធសាសនា ចូលទៅកាន់ប្រទេសជប៉ុនមុនគេ ក្នុងសតវត្សរ៍ទី ៦ ឆ្នាំ ៥៣៨ ។ ប្រទេសទីបេត៍ក្នុង គ.ស ទី ៨ ។ ប្រទេសចិន ក្នុង គ.សទី ៦៧ ។



www.elibraryofcambodia.org

ប្រទេសនានា ដែលបានទទួលយកវប្បធម៌ព្រះពុទ្ធសាសនាពីប្រទេសឥណ្ឌាមក មិនថាប្រទេសកាន់ខាងមហាយាន ឬហីនយាន បាននាំគ្នាធ្វើជាវត្ថុគោរពបូជា គឺពុទ្ធចេតិយរៀង១ខ្លួន ។

ក៏ប៉ុន្តែពុទ្ធចេតិយដែលធ្វើនោះ ដោយយកលំនាំតាមប្រទេសឥណ្ឌា ព្រោះប្រទេសឥណ្ឌាគេបានធ្វើពុទ្ធចេតិយ ក៏ដូចជាចេតិយផ្សេង១ ពីនេះទៀតមុនគេ តែចេតិយនានាប្រទេសដែលបានធ្វើនោះមិនដូចចេតិយដែលគេធ្វើនៅប្រទេសឥណ្ឌាទាំងអស់នោះទេ គឺគេធ្វើទៅតាមការច្នៃប្រឌិតរបស់សិល្បករនៅក្នុងប្រទេសរបស់គេរៀង១ខ្លួន។ គោលពុទ្ធចេតិយ ដែលនានាប្រទេសធ្វើឡើង ដោយយកលំនាំតាមប្រទេសឥណ្ឌានោះ មានជាគោលធំ១ ៤ យ៉ាងគឺ :

ក. រូបព្រះពុទ្ធ

ខ. រូបព្រះពោធិសត្វ

គ. ព្រះស្តូប ( ចេតិយ)

ឃ. ព្រះប្រាង្គ( ប្រាសាទ) ។



www.elibraryofcambodia.org

## អធិប្បាយអំពីការប្រែក្លាយ

### ក. ព្រះពុទ្ធរូប

ព្រះពុទ្ធរូបដែលគេធ្វើដំបូងគឺពួកយោនកៈ ប្រទេសគន្ធារៈ ក្នុងរវាងពុទ្ធសករាជ ៤០០ ។ ពេលដែលពួកយោនក ធ្វើដំបូងនោះ មិនដូចរូបពិតរបស់ព្រះអង្គទេ ព្រោះលោកបរិនិព្វានទៅយូរហើយ គ្មាននរណាស្គាល់។ តែលក្ខណៈរបស់ព្រះពុទ្ធមានបែបណា ខ្លះពួកនោះ ធ្វើតម្រូវតាមគម្ពីរដែលមានពោលទុកមក ។ ដូច្នេះទោះបីមិនដូចរូបឆោមពិតរបស់ព្រះពុទ្ធអង្គក៏ដោយ តែពេលពួកមហាជនឃើញហើយ អាចស្គាល់ថាជារូបព្រះពុទ្ធ ។

តាមប្រទេសនានា ដែលបានកាន់ព្រះពុទ្ធសាសនាដែរនោះ ក្នុងការធ្វើវត្ថុគោរពបូជាមានព្រះពុទ្ធរូបជាដើម ក៏យកលំនាំតាមបែបប្រទេសនេះ។ ក៏ប៉ុន្តែក្នុងការធ្វើឱ្យមានលក្ខណៈផ្សេងៗគ្នាទៅតាមការនិយមរូបឆោម ដែលប្រទេសនោះៗ យល់ថាបែបនេះ ឬបែបនោះទើបស្អាត ហើយក៏ធ្វើព្រះពុទ្ធរូបអនុលោមទៅតាមនោះទៅ។ តែចំពោះគ្រឿងសម្គាល់ របស់ព្រះពុទ្ធដូចជាព្រះឧណ្ណាលោម (រោមប្រជុំចិញ្ចើម) ព្រះកេតុមាលា (របៀបរស្មី) និង ចីវរជាដើមគឺគេធ្វើតាមបែបព្រះពុទ្ធ ដែលមានក្នុងគម្ពីរជាធំ ។



www.elibraryofcambodia.org

ដោយឡែកផ្នែកខាងចីវរ លុះពេលក្រោយមកទៀត នៅប្រទេសចិន និងប្រទេសជប៉ុន បានកែធ្វើដូចជាអាវ មានព្រះពុទ្ធរូបខ្លះ គេធ្វើដូចអាវតែម្តង ដោយតម្រូវឱ្យត្រូវតាមបញ្ញតិរបស់គេដែលកាន់ខាងមហាយាន ។

**ខ. រូបព្រះពោធិសត្វ**

រូបព្រះពោធិសត្វនេះ គឺមានប្រភពចេញមកពីពួកមហាយាន តែខ្ញុំពុំទាន់ឃើញមានគម្ពីរណា បញ្ជាក់ថា កើតចេញពីប្រទេសណាមួយឱ្យច្បាស់ដូចប្រភពដើមព្រះពុទ្ធរូបទេ។ ក្នុងការសាងនេះ ក៏មិនដូច រូបព្រះពោធិសត្វ មានព្រះអរិយមេត្រីដោយពិតដែរ ព្រោះធ្វើក្រោយៗមិនអាចដឹងរូបពិតរបស់ព្រះអង្គបាន ។

ដូច្នេះហើយ រូបព្រះពោធិសត្វដែលពួកមហាយាន ធ្វើតាមប្រទេសនានា ក៏ដូចរូបព្រះពោធិសត្វដែលពួកហីនយានខ្លះៗដែរ។ រូបព្រះពោធិសត្វខ្លះមានលក្ខណៈខុសគ្នាទៅតាមការនិយមតាមប្រទេសក៏ដូចតាមយាននោះៗដែរ។ រូបព្រះពោធិសត្វខ្លះមានលក្ខណៈដូចរូបមនុស្សធម្មតា រូបពោធិសត្វខ្លះប្លែកពីមនុស្ស មានមុខមាត់ដៃច្រើនៗ ទៅជាយក្ខទៅជាសត្វសីហៈ ខ្លះមានទាំងប្រុស មានទាំងស្ត្រី ដូចជារូបព្រះនាងគង់ស៊ីអីម របស់ពួកចិនជាដើម ។



www.elibraryofcambodia.org

នៅមានព្រះពោធិសត្វមួយបែបទៀត ដែលពួកសិល្បករខ្មែរសាងឡើង យកលំនាំតាមបែបមហាយាន គឺរូបព្រះពុទ្ធទ្រង់គ្រឿង (ខ្មែរហៅ) ។ ចំពោះលក្ខណៈរូបនេះមានទ្រង់ មកុដ សង្វារ ខ្សែសុវង និងចិញ្ចៀនជាដើម ដូចជារូបស្តេចទ្រង់មកុដ ឬរូបស្រីល្ខោន។ ក៏ប៉ុន្តែ តាមពិតព្រះពុទ្ធរូបទ្រង់គ្រឿងនេះគឺជារូបស្តេចចក្រ ឬជារូបព្រះអរិយ មេត្រីពោធិសត្វ ។

**គ. ព្រះស្តូប[1]-ចេតិយ**

ការសាងព្រះស្តូបជាពុទ្ធចេតិយ សម្រាប់ដាក់អដ្ឋិធាតុព្រះពុទ្ធជាដើម គឺយកលំនាំតាមបែបមជ្ឈិមប្រទេស ដែលមានបរិវេណតាំងតែពីសម័យពុទ្ធកាល។ ក៏ប៉ុន្តែ ព្រះស្តូបជាពុទ្ធចេតិយ ដែលមានបរិបូរណ៍ឡើងក្រោយសម័យពុទ្ធកាល ក្នុងរាជ្យព្រះបាទធម្មាសោក ទ្រង់បានចែកនូវព្រះបរមសារីរិកធាតុឱ្យយកទៅប្រតិស្ឋានក្នុងទីផ្សេង។

ព្រះស្តូបជាពុទ្ធចេតិយ ដែលធ្វើក្នុងទីផ្សេងៗនោះ មានលក្ខណៈដោយឡែកពីគ្នាដូចជាប្រទេសខ្លះ ដែលកាន់លទ្ធិហីនយានមានប្រទេស លង្កា មានប្រទេសភូមា ប្រទេសមន និងប្រទេសសៀមជាដើមច្រើន ធ្វើព្រះស្តូប

---

[1] ពាក្យថា "ស្តូប" (សំ)-(បា) ថា "ថូប" ប្រែថាគ្រឿងចំណាំ ទីកន្លែង សម្រាប់ដាក់អដ្ឋិធាតុគោរពបូជា ។



www.elibraryofcambodia.org

ជាធាតុចេតិយ ជូនកាលធ្វើទំហំធំៗ ។ ក៏ប៉ុន្តែចំពោះប្រទេស ដែលកាន់លទ្ធិមហាយាន ដូចជាប្រទេសទីបេត៍ ប្រទេសចិន និងប្រទេស ជប៉ុន (រួមទាំងប្រទេសខ្មែរ និងប្រទេសថ្ងៃ ដែលកាន់ពីបុរាណផងដែរ) ច្រើនធ្វើជា ឧទ្ទេសិកចេតិយវិញ ។

ខាងមហាយាន បានជាច្រើនតែធ្វើជាឧទ្ទេសិកចេតិយដូច្នេះ ដោយហេតុថា ប្រទេសដែលកាន់នូវយាននេះ បានបែកក្នុងកាល ក្រោយមកជាច្រើនរយឆ្នាំ (២៣៤) ហើយក៏មិនបានព្រះបរមសារីរិកធាតុទៅសាងព្រះស្តូបជាពុទ្ធចេតិយប្រតិស្ឋានទុក។ ហេតុនេះ ការសាងព្រះស្តូបគ្រាន់តែជាឧទ្ទេសិកចេតិយ។ ហីនយាន ដោយហេតុថា ជាលទ្ធិមានជាយូរមក ដូច្នេះក្នុងរាជ្យព្រះបាទធម្មាសោក ទ្រង់បានចែកព្រះបរមសារីរិកធាតុឱ្យទៅធ្វើព្រះស្តូប ជាពុទ្ធចេតិយបញ្ចុះជាច្រើនកន្លែងតាមប្រទេសតូចធំ ដែលកាន់លទ្ធិហីនយាន។

### ឃ. ព្រះប្រាង្គ[1] ~ប្រាសាទ[2]

---

[1] ពាក្យថា "ប្រាង្គ" (សំ) ប្រែថាសេនាសនៈ ។

[2] ពាក្យថា "ប្រាសាទ" (សំ)-(បា) ថា "បាសាទ" ប្រែថា គ្រឹះស្ថានជាទីញ៉ាំងចិត្តឱ្យជ្រះថ្លា, គ្រឹះស្ថានគួរឱ្យសប្បាយ ។



www.elibraryofcambodia.org

ប្រាង្គនោះ បែបមកអំពីប្រាសាទ គឺផ្ទះច្រើនជាន់សម័យដើមគេធ្វើអំពីឈើ ជាទីលំនៅរបស់ពួកអ្នកមានដូចជាសេដ្ឋី ហើយព្រមទាំងព្រះមហាក្សត្រផងដែរ។ តែមនុស្សធម្មតាគេធ្វើមួយជាន់ លុះពេលក្រោយមកប្រាសាទគេធ្វើជាផ្ទះតែមួយជាន់ជាទូទៅ តែគេធ្វើសណ្ឋានទ្រង់ទ្រាយឱ្យសក្តិសមដូចជាកែធ្វើជាន់ក្រោម ឱ្យធំទូលាយខាងលើ បន្ថយស្ទួនឱ្យតូចចុះដោយលំដាប់ ។

លុះមកដល់ពេលក្រោយមកទៀត ព្រះប្រាង្គ-ប្រាសាទ ដែលធ្លាប់ធ្វើអំពីគ្រឿងឈើ គេផ្លាស់ធ្វើអំពីឥដ្ឋ និងសិលាវិញ ។ ក៏ប៉ុន្តែ ប្រាង្គ-ប្រាសាទដែលធ្វើក្នុងពេលក្រោយនេះគេធ្វើសម្រាប់ដាក់អដ្ឋិធាតុ ឬ ពុទ្ធរូប ឬក៏ទេវរូបវិញ លែងនៅជាផ្ទះដូចមុនទៀត ។ លក្ខណៈព្រះប្រាង្គ ក្នុងសម័យជាន់ដើម គេធ្វើមានគ្រឿងសម្គាល់ខុសគ្នា តាមការនិយមរបស់សាសនា ។ បើជាព្រះប្រាង្គខាងព្រះពុទ្ធសាសនា កំពូលធ្វើជាព្រះស្តូប បើព្រះប្រាង្គក្នុងព្រហ្មញ្ញសាសនា កំពូលធ្វើជាត្រីសូល៍ ឬ ជានពសូល៍ ។

រូមអត្ថន័យដោយខ្លីមកព្រះពុទ្ធរូបក្តី រូបព្រះពោធិសត្វក្តី ព្រះស្តូបក្តី ព្រះប្រាង្គក្តី ទោះបីប្រភពដើមចេញពីប្រទេសឥណ្ឌាក៏ដោយ លុះពេលក្រោយមកទៀតនៅតាមប្រទេសនីមួយៗ បានកែប្រែនូវរូបរាង ទ្រង់ទ្រាយ



www.elibraryofcambodia.org

ផ្សេងពីប្រទេសឥណ្ឌាតម្រូវទៅតាមការនិយម ក៏ដូចវប្បធម៌ផងដែរ របស់ប្រទេសខ្លួនវិញ ។ បច្ចុប្បន្នក្នុងការធ្វើវត្ថុគោរពបូជាដូចខាងលើ គឺជាបែបនានាប្រទេសរៀងៗខ្លួនសុទ្ធសាធ ។

### ៥. សាមញ្ញជនចេតិយ

ដោយជាប់ទំនៀមសាងចេតិយបញ្ចុះអដ្ឋិធាតុព្រះពុទ្ធ គឺដូចជាបុគ្គលបីពួកទៀត មានព្រះបច្ចេកពុទ្ធ ព្រះអរហន្ត និងស្តេចចក្រពត្តិជាដើម ដូច្នេះក៏បែកគំនិតសាងនូវចេតិយជាច្រើនប្រភេទផ្សេងទៀត សម្រាប់បញ្ចុះអដ្ឋិធាតុបុគ្គលផ្សេង ក្រៅពីបុគ្គល ៤ ពួកខាងលើ មានស្តេច គ្រូឧបជ្ឈាយាចារ្យ និង មាតាបិតាជាដើម ទុកធ្វើសក្ការបូជាដែរ។ ដោយហេតុថា សម័យក្រោយៗនេះ មិនអាចនឹងស្វែងរកព្រះ អដ្ឋិធាតុបុគ្គលជាន់ខ្ពស់ទាំងបួនពួកនោះមកបញ្ចុះក្នុងចេតិយដោយងាយឡើយ ដូច្នេះមានតែអដ្ឋិធាតុបុគ្គលក្រៅពីនោះ ដូចជា ស្តេច គ្រូឧបជ្ឈាយាចារ្យ និងមាតាបិតា ជាដើម នេះឯងបញ្ចុះទុកគោរពបូជា ។

ដោយឡែក ចេតិយទោះបីគេធ្វើដាក់អដ្ឋិធាតុរបស់សាមញ្ញជនក្រៅពីបុគ្គល៤ពួកខាង លើនេះក៏ដោយ តែបើតាមការសង្កេតនូវ ចេតិយទាំងនោះឃើញថាមាន ២ ផ្នែកធំៗ ដែលគួរកត់សម្គាល់គឺ :



www.elibraryofcambodia.org

ក. ផ្នែកខាងលើនៃចេតិយ (កំពូល) : គេធ្វើជាពុទ្ធបដិមាបញ្ចុះនៅផ្នែកនោះ (តម្កល់) ។ ក៏ប៉ុន្តែមានចេតិយខ្លះ គេតម្កល់បដិមាពោធិសត្វ (ព្រះអរិយមេត្រី) ឬស្តេចចក្រពត្តិវិញ។ ទោះបីដូច្នេះក្តី ការតម្កល់នូវរូបផ្នែកខាងលើនេះ គឺមានជាទូទៅទាំងអស់ គ្រាន់តែការតម្កល់នោះទៅតាមការស្រឡាញ់ ។

ខ. ផ្នែកខាងក្រោមនៃចេតិយ : គេបញ្ចុះអដ្ឋិធាតុ ឬសព របស់សាមញ្ញជន មានស្តេច គ្រូឧបជ្ឈាយាចារ្យ និងមាតាបិតាជាដើម។

## ចេតិយ និងប្រាសាទនៅប្រទេសខ្មែរ

ប្រទេសខ្មែរ គឺជាប្រទេសមួយ ដែលមានប្រវត្តិសាស្ត្រជាច្រើន ឆ្នាំមកហើយក្នុងដែនដី **សុវណ្ណភូមិ** ភាគអាគ្នេយ៍ (អាស៊ីអាគ្នេយ៍)។ កាលទើបកកើតទឹកដីជាដំបូង ក៏ដូចជាច្រើនឆ្នាំក្រោយមកទៀត អ្វីៗទាំងអស់គឺជាការច្នៃប្រឌិតរបស់បុព្វបុរសខ្មែរដោយផ្ទាល់។ ក្នុងរវាង សតវត្សរ៍ទី១ វប្បធម៌បរទេស (ប្រទេសឥណ្ឌា) ក៏បាននាំចូលមកកាន់ ប្រទេសខ្មែរ។ ក្នុងនោះដែរ ព្រហ្មញ្ញសាសនា នាំចូលមកក្នុងរវាង សតវត្សរ៍ទី១-៦ ព្រះពុទ្ធសាសនាបែបមហាយាន នាំចូលក្នុងរវាង សតវត្សរ៍ទី ១២ ។



www.elibraryofcambodia.org

ដោយអាស្រ័យនូវវប្បធម៌បរទេសចូលមកក្នុងប្រទេសដូច្នេះហើយ ប្រជាជនក៏ដូចជាស្តេច មន្ត្រីតូចធំ បាននាំគ្នាកាន់នូវទំនៀមទម្លាប់ធ្វើព្រះចេតិយ ឬប្រាសាទ ឧទ្ទិសចំពោះបុគ្គលដ៏ខ្ពង់ខ្ពស់ដូច ប្រទេសឥណ្ឌាដែរ ។ ក៏ប៉ុន្តែប្លង់ ឬលក្ខណៈទ្រង់ទ្រាយនៃចេតិយ ឬប្រាសាទនោះ គឺសិល្បករខ្មែរធ្វើតាមការបច្ចេកទេសដ៏ខ្ពស់របស់ខ្លួនដោយផ្ទាល់ ។ ក្រៅពីធ្វើឧទ្ទិសចំពោះបុគ្គលដ៏ខ្ពង់ខ្ពស់នោះៗទៅ ក៏មានចេតិយ ឬប្រាសាទជាច្រើនទៀត ដែលសិល្បករខ្មែរយើងធ្វើឧទ្ទិស ចំពោះសាមញ្ញជន មានស្តេចជាដើមដែរ ។

បើតាមប្រវត្តិសាស្ត្រជាច្រើនបានបញ្ជាក់ទុកមកថា ចេតិយ ឬប្រាសាទនៅប្រទេសខ្មែរដែលបានកសាងឡើងតាំងពីទទួលវប្បធម៌ បរទេស (ឥណ្ឌា) រហូតមកដល់សតវត្សរ៍ទី ១២ ឬក្រោយសតវត្សរ៍ទី ១២ សរុបមាន ១០៨០ចេតិយ ឬប្រាសាទ។ ក្នុងនោះដែរមានចេតិយ ឬប្រាសាទខ្លះ គេធ្វើឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ខ្លះគេឧទ្ទិសចំពោះព្រះពុទ្ធសាសនា បែបមហាយាន ឬហីនយាន និងខ្លះទៀតគេឧទ្ទិស ចំពោះស្តេច ឬមន្ត្រី ឬក៏បុព្វបុរសដែលមានគុណសម្បត្តិខ្ពស់នៅក្នុងមាតុប្រទេស ។ ក៏ប៉ុន្តែមានចេតិយ ឬប្រាសាទខ្លះគេឧទ្ទិសចំពោះ ព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនា



www.elibraryofcambodia.org

ជានិមិត្តរូបធំ ហើយគេដាក់សព ឬអដ្ឋិធាតុសាមញ្ញជន មានស្តេច មន្ត្រី ជាដើម ក្នុងនោះផងដែរ ។

ជាការជាក់ស្តែង សូមលើកយកចេតិយ ឬ ប្រាសាទខ្លះៗ ដែលបុព្វបុរសខ្មែរយើងបានធ្វើឧទ្ទិសចំពោះបុគ្គលខ្ពស់ៗ ក្រៅប្រទេស និងសាមញ្ញជនជាច្រើនមាន ស្តេច មន្ត្រីជាដើម នៅក្នុងប្រទេសមក ដាក់ជាភស្តុតាងដូចខាងក្រោម ។

-ប្រាសាទនគរវត្ត កសាងដោយ **ព្រះបាទសូរ្យវរ្ម័នទី២** ក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព.ស ១៦៩៣) ដើម្បីឧទ្ទិសថ្វាយចំពោះព្រះវិស្ណុ លុះដល់ស្តេចចូលទីវង្គតទៅ គេថ្វាយព្រះនាមព្រះអង្គថា **ព្រះបរមវិស្ណុលោក** ។

-ប្រាសាទតាព្រហ្មកិល : កសាងឧទ្ទិសថ្វាយព្រះពុទ្ធសាសនាលទ្ធិមហាយាន ដោយមានរូបចម្លាក់នៅហោជាងទាំងបួនទិស សុទ្ធសឹងជារឿងក្នុងព្រះពុទ្ធសាសនា ។

-ប្រាសាទបាខែង (ឥន្ទ្រាទ្រិ ប្រែថា "ភ្នំធំសម្រាប់បូជាទេវតាធំៗ) កសាងដោយ **ព្រះបាទយសោវរ្ម័នទី១** ក្នុងរវាងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស.១៣៤៤) ដើម្បីឧទ្ទិសថ្វាយដល់ព្រះឥសូរ ។



www.elibraryofcambodia.org

-ប្រាសាទបក្សីចាំក្រុង : កសាងដោយ **ព្រះបាទរាជេន្ទ្រវរ្ម័នទី២** កសាងក្នុងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស ១៤៩) ដើម្បីឧទ្ទិសថ្វាយព្រះឥសូរ តែក្រោយមក គេសាងពុទ្ធរូបទ្រង់ចូលបរិនិព្វានដាក់វិញ ។

-ប្រាសាទនគរធំ : កសាងដោយ **ព្រះបាទយសោវរ្ម័នទី១** ដែលជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័នទី១ ក្នុងរវាងសតវត្សទី១៥ នៃពុទ្ធសករាជ (ព.ស ១៤៣២-១៤៥៣) ដើម្បីឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនា ដោយមានកំពូលជាក្បាលលោកេស្វរពោធិសត្វ បែរមុខទៅទិសទាំងបួន (ខាងព្រហ្មញ្ញសាសនា គេហៅថា រូបព្រះព្រហ្ម)

-ប្រាសាទបាយ័ន : កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៧** ក្នុងរវាងសតវត្សរ៍ទី១៨ នៃពុទ្ធសករាជ (ព.ស ១៧២៤-១៧៤៤) ដើម្បីឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនា ក្រោយមកទៀតព្រះបាទយសោវរ្ម័នកសាងបន្ថែមហើយក៏ឧទ្ទិសចំពោះព្រហ្មញ្ញសាសនាវិញ ។

-ប្រាសាទបាពួន : កសាងដោយ **ព្រះបាទឧទយាទិត្យវរ្ម័នទី២** ក្នុងសតវត្សរ៍ទី ១៧ នៃពុទ្ធសករាជ (ព.ស ១៦០៣) ដើម្បីឧទ្ទិស ថ្វាយចំពោះទេវតា ឈ្មោះហេមស្រីន្ដេស្វរៈ (ទេវតាធំ មានស្នែងមាស) ខាងលទ្ធិព្រហ្មញ្ញសាសនា ។



www.elibraryofcambodia.org



www.elibraryofcambodia.org

-ប្រាសាទវិមានអាកាស : កសាងដោយ **ព្រះបាទសូរ្យវរ្ម័នទី១** ក្នុងឆ្នាំ១៥៥៤ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ (ព.ស ១៤៥៣) ។

-ប្រាសាទទេពប្រណម្យ : កសាងដោយព្រះបាទ **យសោវរ្ម័ន** រវាងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនា ។

-ប្រាសាទបាលិលៃ : កសាងបន្ថែមដោយ**ព្រះបាទជ័យវរ្ម័នទី៧** រវាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា។

-ប្រាសាទពិធូរ : កសាងឡើងដើម្បីឧទ្ទិសថ្វាយព្រហ្មញ្ញសាសនាខ្លះ និងព្រះពុទ្ធសាសនាខ្លះ ដោយហេតុថា ក្នុងប្រាសាទនេះ មានសិវលិង្គព្រះឥសូរខ្លះ មានរូបព្រះពុទ្ធខ្លះ ។

-ប្រាសាទមង្គល : កសាងឡើងក្នុងសតវត្សរ៍ទី ២០ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ។

-ប្រាសាទធម្មានន្ទ និងប្រាសាទចៅសាយ : ប្រាសាទ ធម្មានន្ទ កសាងដើម្បីឧទ្ទិសថ្វាយចំពោះព្រហ្មញ្ញសាសនា។ ប្រាសាទ ចៅសាយ កសាងឡើងដើម្បីឧទ្ទិសថ្វាយព្រហ្មញ្ញសាសនាដែរ កសាងក្នុងសតវត្សរ៍ទី១៧ នៃពុទ្ធសករាជ ។



www.elibraryofcambodia.org




www.elibraryofcambodia.org

-ប្រាសាទតាកែវ : កសាងដោយ **ព្រះបាទសុរ្យវរ្ម័នទី១** រវាងសតវត្សរ៍ទី១១ នៃពុទ្ធសករាជ (ព.ស ១៥៤៣) ដើម្បីឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា ។

-ប្រាសាទតាព្រហ្ម : កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៧** រវាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ (ព.ស ១៧២៩) ដើម្បីឧទ្ទិសថ្វាយ ចំពោះវិញ្ញាណក្ខន្ធព្រះមាតាបិតារបស់ព្រះអង្គ ទ្រង់កសាងបដិមាព្រះនាងប្រាជ្ញាបារមីតា ជាតំណាងមាតា ។

-ប្រាសាទបន្ទាយក្តី : កសាងឡើងដោយ **ព្រះបាទជ័យវរ្ម័នទី ៧** រវាង សតវត្សរ៍ទី១៨ នៃពុទ្ធសករាជ (ព.ស ១៧២៤-១៧៤៤) ដើម្បីឧទ្ទិសថ្វាយ ចំពោះព្រះពុទ្ធសាសនា ។

-ប្រាសាទក្រវ៉ាន់ : កសាងដោយ **ព្រះបាទហស៌្សវរ្ម័ន** រវាងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស ១៤៥៣-១៤៦៥) ដើម្បីឧទ្ទិសថ្វាយចំពោះ ព្រហ្មញ្ញសាសនា ។

-ប្រាសាទប្រែរូប : កសាងដោយព្រះបាទ **រាជេន្ទ្រវរ្ម័នទី២** រវាងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស ១៤៩៤) ដើម្បីឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា ។



www.elibraryofcambodia.org

- ប្រាសាទមេបុណ្យ ៖ កសាងដោយ **ព្រះបាទរាជេន្ទ្រវរ្ម័នទី២** រវាងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស ១៤៨៥) ដើម្បីឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា។ កន្លែងខ្លះថា ឧទ្ទិសដល់មាតាបិតារបស់ព្រះអង្គ។

-ប្រាសាទតាសោម ៖ កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៧** រវាងសតវត្សរ៍ទី ១៨ នៃពុទ្ធសករាជ(ព.ស ១៧២៤-១៧៤៤) ដើម្បីឧទ្ទិស ថ្វាយចំពោះព្រះពុទ្ធសាសនា ។

-ប្រាសាទនាគព័ន្ធ ៖ កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៧** រវាងសតវត្សទី ១៨ នៃពុទ្ធសករាជ (ព.ស ១៧២៤-១៧៤៤) ដើម្បីឧទ្ទិស ថ្វាយចំពោះព្រះពុទ្ធសាសនា (លោកេស្វរពោធិសត្វ) ។

-ប្រាសាទព្រះខាន់ ៖ កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៧** រវាងពាក់កណ្តាលសតវត្សរ៍ទី១៨ នៃពុទ្ធសករាជ(ព.ស ១៧២៤-១៧៤៤) ដើម្បីឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនា (លោកេស្វរពោធិសត្វ)។ ក្នុងនោះដែរ ព្រះអង្គកសាងរូបព្រះបាទធរណិន្ទ្រវរ្ម័ន ជាព្រះបិតា និងរូប ព្រះវររាជជននី ជាព្រះមាតាតម្កល់នៅក្នុងនោះដែរ ។

-ប្រាសាទលលៃ ៖ កសាងដោយ **ព្រះបាទយសោវរ្ម័នទី១** រវាងសតវត្សរ៍ទី ១ នៃពុទ្ធសករាជ (ព.ស ១៤៣៦) ដើម្បីឧទ្ទិសថ្វាយចំពោះ



www.elibraryofcambodia.org

ព្រហ្មញ្ញសាសនា។ ក្នុងនោះដែរ ព្រះអង្គបានតម្កល់ព្រះរូបមាតាបិតា អយ្យកោ អយ្យកា ខាងព្រះមាតា ។

-ប្រាសាទព្រះគោ : កសាងដោយ **ព្រះបាទឥន្ទ្រវរ្ម័នទី១** រវាងសតវត្សរ៍ទី១៥ នៃពុទ្ធសករាជ (ព.ស ១៤២៤) ដើម្បីឧទ្ទិសថ្វាយ ចំពោះព្រហ្មញ្ញសាសនា។ ក្នុងនោះដែរ ព្រះអង្គតម្កល់រូបបដិមារបស់ព្រះមាតាបិតា ព្រះអយ្យកោ ព្រះអយ្យកា ខាងព្រះមាតា និងព្រះរាជាអង្គមុន គឺព្រះបាទជ័យវរ្ម័នទី២ ។

-ប្រាសាទបាគង : កសាងដោយ **ព្រះបាទឥន្ទ្រវរ្ម័នទី១** រវាងសតវត្សរ៍ទី ១៥ នៃពុទ្ធសករាជ (ព.ស ១៤២២) ដើម្បីឧទ្ទិសថ្វាយចំពោះព្រហ្មញ្ញសាសនា ខាងក្រោយមកទៀត គេឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនាបែបមហាយានវិញ ។

-ប្រាសាទបន្ទាយស្រី : កសាងដោយ **ព្រះបាទជ័យវរ្ម័នទី៥** រវាងសតវត្សរ៍ទី១៦ នៃពុទ្ធសករាជ (ព.ស ១១០) ដើម្បីឧទ្ទិសចំពោះ ពហ្មញ្ញ-សាសនា ។

នៅមានចេតិយ និងប្រាសាទជាច្រើនទៀតដែលបុព្វបុរសយើង បានកសាងឡើងដើម្បីឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនា ឬក៏



www.elibraryofcambodia.org

សាមញ្ញជននៅក្នុងប្រទេស មានស្តេចជាដើម ។ ដូច្នេះតាមរយៈ គោលនៃការលើកយកចេតិយ ឬប្រាសាទមកដាក់ខាងលើនេះ យើងអាចយល់បានថា ចេតិយ ឬប្រាសាទនៅប្រទេសខ្មែរ ក្រៅពីឧទ្ទិសចំពោះបុគ្គលខ្ពស់ៗ នៅក្នុងសាសនាទៅ ក៏មានចេតិយ ឬប្រាសាទខ្លះ គេឧទ្ទិសចំពោះសាមញ្ញជន មានស្តេចជាដើមផងដែរ ។ ហើយនៅមានចេតិយ ឬប្រាសាទខ្លះទៀត គេធ្វើឧទ្ទិសព្រមគ្នា គឺឧទ្ទិសចំពោះព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាហើយឧទ្ទិសចំពោះសាមញ្ញជននៅក្នុងប្រទេស នៅក្នុងនោះទៀត ។

លក្ខណៈបែបនេះ សឱ្យឃើញច្បាស់ថា ការធ្វើចេតិយ ឬប្រាសាទឧទ្ទិសចំពោះសាមញ្ញជន មានស្តេចជាដើម ឬឧទ្ទិសចំពោះបុគ្គលខ្ពស់ៗក្នុងសាសនាផង ឧទ្ទិសចំពោះសាមញ្ញជនផង(រួមគ្នា) គឺជាការច្នៃប្រឌិតចេញពីការធ្វើចេតិយ ឬប្រាសាទ ឧទ្ទិសចំពោះ បុគ្គលខ្ពស់ៗ ក្នុងសាសនា។ ដូច្នេះហើយ ទើបជាប់ទំនៀមសាងសាមញ្ញជនចេតិយ ឬប្រាំសាទ ជាហូរហែតៗគ្នា រហូតមកដល់សព្វថ្ងៃ ។

## ការធ្វើសាមញ្ញជនចេតិយបច្ចុប្បន្ន

សព្វថ្ងៃការធ្វើសាមញ្ញជន ចេតិយសម្រាប់ដាក់សព ឬអដ្ឋិធាតុសាមញ្ញជនក្នុងប្រទេស មានស្តេច មន្ត្រី គ្រូឧបជ្ឈាយាចារ្យ ។ល។ គឺមានគេនិយមធ្វើច្រើនជាទីបំផុត ។ គ្រឿងសំភារៈដែលធ្វើនោះ មិនមែនធ្វើអំពីថ្ម



www.elibraryofcambodia.org

ដូចសម័យជាន់ដើមទេ គឺគេធ្វើអំពីស៊ីម៉ង់ត៍។ ទំហំទ្រង់ទ្រាយគឺមានច្រើនបែប ទៅតាមការស្រលាញ់ និងសមត្ថភាពអ្នកធ្វើផងដែរ ។

ចំពោះទីតាំងដែលគេធ្វើ ដោយគេយល់ឃើញថា វាមិនមែនជាពុទ្ធចេតិយ ឬចេតិយ បុគ្គលសំខាន់ៗ ជាច្រើនទៀត ដូច្នេះមិនសូវធ្វើតម្រូវឱ្យចំផ្លូវបែកជាបួន ដែលជាទីប្រជុំក្នុងទិសទាំងបួន ដូចពុទ្ធដីកា ទ្រង់សម្ដែងទៅកាន់ព្រះអានន្ទ ក្នុងមហាបរិនិព្វានសូត្រឡើយ ។ បើតាមការសង្កេតនូវសាមញ្ញជនចេតិយច្រើន ដែលខ្មែរយើងបានធ្វើឡើងក្នុងពេលក្រោយៗនេះមាន ចំណុចសម្គាល់ពីរគឺ :

១-វត្តអារាមជាទីលំនៅនៃសង្ឃ ហើយវាក៏ជាកន្លែងដែលពោរពេញទៅដោយភាពស្ងប់រម្ងាប់ផងដែរ ។ ចំណុចនេះហើយ បានញ៉ាំងជនភាគច្រើន ឱ្យមានចិត្តជ្រះថ្លា ហើយជាពិសេសទៀត ក៏បានធ្វើចេតិយបញ្ចុះសព ឬអដ្ឋិធាតុអ្នកមានគុណរបស់ខ្លួន ក៏ដូចទុកសម្រាប់ខ្លួនផងដែរនៅក្នុងទីវត្ត ។ បែបនេះ គេមានជំនឿតៗគ្នាមកពីរយ៉ាងគឺ:

ក- ធ្វើចេតិយនៅក្នុងវត្ត អាចឱ្យអ្នកមានគុណ បានស្ដាប់ធម៌អំពីព្រះសង្ឃ ឬបានទទួលនូវភាគផលខ្លះៗ អំពីព្រះសង្ឃឧទ្ទិសឱ្យ ឬក៏បាន



www.elibraryofcambodia.org

សេចក្តីស្ងប់រម្ងាប់ជាមួយព្រះសង្ឃដែរ ។

ខ- ធ្វើចេតិយនៅក្នុងវត្ត ងាយស្រួលដល់កូនចៅដែលរស់នៅធ្វើបុណ្យឧទ្ទិសទៅឱ្យ ។ ដូចជាក្នុងពេលដល់ហែមន្តសន្តរជូវម្តងម្កាល កូនចៅនាំគ្នាទៅបង្សុកូលនៅទីនោះ ហើយបានធ្វើទានជាមួយព្រះសង្ឃ ឬសីលវន្ត សីលវតី មិនបាច់ចាំឱ្យលោកនិមន្តឆ្ងាយ ឬពិបាកទៅនិមន្តលោក គឺនៅក្នុងវត្តនោះស្រាប់ ។

ដូច្នេះនៅក្នុងវត្តអារាមនីមួយៗភាគច្រើន សម្បូរចេតិយជា អ្វីៗទាំងអស់។ ក្នុងវត្តខ្លះមិនថានៅទីក្រុង ឬជនបទនោះឡើយ ចេតិយគេធ្វើជុំវិញព័ទ្ធព្រះវិហារ មើលទៅបាត់សោភណភាពនៃព្រះវិហារជាងពាក់កណ្តាល ។ វត្តអារាមខ្លះគេធ្វើជុំវិញអាវាសវត្ត និងវត្ត អារាមខ្លះទៀត គេធ្វើស្អេកស្កះស្ទើរពេញដីវត្ត ធ្វើឱ្យបាត់សណ្តាប់ធ្នាប់ បរិស្ថានវត្តអារាមអស់ ។ ការធ្វើបែបនេះ មានហេតុធំៗពីរបែបគឺ :

ក. ដោយអាចារ្យ គណៈកម្មាធិការ ឬអ្នកធ្វើដោយផ្ទាល់មិនបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ ឬរៀបចំប្លង់ឱ្យបានស្អាតធ្វើទៅតាមតែអំពើចិត្ត ។



www.elibraryofcambodia.org



ចេតិយបុរាណ១បែបនៅខាងមុខច្រកចូលខាងកើត ប្រាសាទអង្គរវត្ត កសាង ១៦២៣ គ.ស

www.elibraryofcambodia.org

១. កន្លែងខ្លះដោយជាប់ខ្សែពួកហុងស៊ុយ ឬតម្រាជយភូមិ មើលយល់ឃើញត្រង់ណាល្អ ក៏ធ្វើត្រង់នោះទៅ ដោយមិនគិតអាក្រក់សណ្ដាប់ធ្នាប់វត្តអារាម ។

២. ក្រៅពីវត្តអារាម មានចេតិយខ្លះគេធ្វើនៅតាមផ្ទះ ឬតាមទីដីព្រៃ ស្មសានជិតភូមិ ឬក្រៅភូមិដាច់ស្រយាល។ ការធ្វើនៅទីក្រៅវត្ត ដូច្នេះមិនដឹងជាគេមានគោលបំណងដូចម្ដេចខ្លះទេ តែបើតាមការយល់ ប្រហែលជាគេគិតឃើញថា ធ្វើនៅតាមផ្ទះ ឬទីដីផ្សេងៗរបស់ខ្លួន ងាយស្រួលគោរពបូជា ថែរក្សា ព្រោះនៅជិតខ្លួន ឬនៅក្នុងដីខ្លួនស្រាប់ (ខ្លះគេយល់ថាកុំឱ្យប៉ះពាល់ដល់ដីវត្ត ជាដីសង្ឃក្រែងលោកកសាងអ្វី មួយនៅពេលខាងក្រោយ) ។

## កិច្ចខ្លះក្នុងចេតិយ

ចេតិយដែលគេធ្វើបច្ចុប្បន្ន ទោះបីនៅក្នុងវត្តអារាមក្ដី ក្រៅវត្តអារាមក្ដី ឃើញថា ក្នុងនោះមានទំនៀមខ្លះៗ គេធ្វើចំពោះចេតិយនោះ ដូចជាតម្កល់ទឹកមួយក្ងួនពាង ឬមួយក្រឡដាក់នៅក្នុងចេតិយនោះជាដើម។ មានចេតិយខ្លះ គេមិនតម្កល់ទឹកដាក់ក្នុងនោះទេ តែនៅទីលានមុខចេតិយ គេជីកស្រះអម ឬមានស្រះនៅពីមុខស្រាប់ បែបនេះ គេចាត់ទុកថាហាក់ដូចបានតម្កល់ទឹកនៅក្នុងចេតិយនោះដែរ ។



www.elibraryofcambodia.org

ទំនៀមបែបនេះ បើតាមការស្រាវជ្រាវក្នុងឯកសារប្រវត្តិសាស្ត្រជាច្រើន ឃើញថាមិនមែនទើបតែមានក្នុងពេលបច្ចុប្បន្ននេះទេ គឺមានតាំងពីបុរាណមកម្ល៉េះ ។ នៅក្នុងប្រវត្តិសាស្ត្រមួយមានចំណង ជើងថា "ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ" ដោយលោក ហ្សក សឺដែស (ជនជាតិបារាំង) ប្រែជាភាសាខ្មែរដោយលោក ម៉ុញ សារី មានជា សេចក្តីហូរហែ ក្នុងបញ្ហានេះថា :

នៅថ្ងៃមួយ ពួកអភិរក្សអង្គរនៅប្រទេសខ្មែរ បាននាំគ្នាជីកគាស់កកាយក្រោមប្រាសាទដែលគេឧទ្ទិសចំពោះបុគ្គលខ្ពស់ៗ ក្នុងសាសនា ឬដូចជាឧទ្ទិសចំពោះសាមញ្ញជនផងដែរ បានរកឃើញនូវពាងចំនួនដប់ ។ ក្នុងនោះបានមកពីប្រាសាទបន្ទាយសំរែខ្លះ ពីប្រាសាទភ្នំបាខែងខ្លះ និងពីប្រាសាទអង្គរវត្តខ្លះ ។ ដែលគួរឱ្យកត់សម្គាល់នោះ មានពាងមួយមានគម្របសម្រាប់គ្របត្រឹមត្រូវ គេគាស់បានពីប្រាសាទបន្ទាយសំរែ ។ ពួកក្រុមអ្នកស្រាវជ្រាវគេសន្និដ្ឋានថា ពាងនោះគឺ សម្រាប់ដាក់ទឹកថ្លាយង់នៅក្នុងប្រាសាទនោះ ។ ការសន្និដ្ឋានដូច្នេះ ដោយគេសម្គាល់ឃើញពាងខ្លះមានទឹកនៅក្នុងពាងនោះស្រាប់តែម្តង។ ដោយឡែកមានមតិខ្លះគេសន្និដ្ឋានផ្សេងថាវាមិនមែនជាពាងសម្រាប់ដាក់ទឹកដ៏ថ្លាទេ គឺជាពាងសម្រាប់ដាក់សព (មឈូស) ឬ សម្រាប់ដាក់អដ្ឋិធាតុ។ គេធ្វើការវិភាគថា លក្ខណៈរបស់ពាងនោះ មានសណ្ឋានដូច



www.elibraryofcambodia.org

កោដ្ឋសម្រាប់ដាក់សពព្រះមហាក្សត្រខ្មែរ និងថៃ ក្នុងបច្ចុប្បន្ននេះ ដាក់ដោយធ្វើឱ្យព្រះអង្គអង្គុយពែនភ្នែន( ទំហំកោដ្ឋមានបន្ទាត់កាត់ផ្ចិត ១.២ x ០.៦ ) ។ ដូច្នេះ គេយល់ថាពាងនោះជាមឈូសវិញ ដោយគេវិភាគនូវចំណុច សំខាន់ៗពីរបែបរបស់ពាងនោះគឺ :

១. ពាងខ្លះដែលបាតក្រោមមានរន្ធនោះ គឺសម្រាប់បង្ហូរទឹក ដែលហូរចេញពីសាកសពដែលគេដាក់សពមុនយកទៅបូជា ។ រន្ធដែល គេចោះកណ្តាលគម្របពាង គឺសម្រាប់បញ្ចេញឧស្ម័ន ឬ ដើម្បីបញ្ចូលខ្សែអំបោះសឬសាច់កំណាត់ស សម្រាប់ជាការទំនាក់ទំនងគ្នារវាងអ្នក ស្លាប់ និងអ្នករស់ ។ គេធ្វើដូច្នេះសម្រាប់សម្ងួតសាកសព ។ បន្ទាប់មក សាកសពគេបូជាដោយភ្លើង ឆ្អឹងគេយកដាក់កោដ្ឋ ហើយពាងនោះគេ យកទៅបញ្ចុះក្រោមប្រាសាទឧទ្ទិសចំពោះសាកសព ។

២. ពាងទាំងអស់គេសម្រាប់ដាក់សាកសពដែលគេផ្សួតយកសាច់ចេញអស់ ។ រន្ធដែលគេចុះនៅមាត់ពាង គឺសម្រាប់ចាក់ទឹកបង្ហូរ ចូលទៅ ។

**បទវិភាគ**

មតិដែលយល់ថាពាងទាំងអស់នោះ មិនមែនជាពាងសម្រាប់ ដាក់សព ឬ អដ្ឋិធាតុវិញឃើញថា គឺជាមឈូសសម្រាប់ដាក់សព ឬអដ្ឋិធាតុវិញ



www.elibraryofcambodia.org

ឃើញថា គឺជាការសន្និដ្ឋានមិនប្រាកដច្បាស់លាស់ទេ សូមបណ្ឌិតសិក្សាស្រាវជ្រាវបន្ថែមទៀតចុះ ។ ក៏ប៉ុន្តែចំណុចទាំងពីរខាងលើ នេះយើងឃើញថា ដូចជាខ្វះនូវហេតុផលច្រើន។ ព្រោះថាស្មើត្រឹម មឈូសតម្កល់សពនៅក្នុងសម័យបុរាណ ខ្មែរយើងសម្បូរឈើណាស់ ហេតុអ្វីបានជាយកថ្មមកធ្វើមឈូសវិញ (ដូចជាឆ្វល់) ពេលបច្ចុប្បន្ននេះ ក្តី ពេលពីអតីតក្តី ខ្មែរយើងធ្វើមឈូសតម្កល់សព គឺភាគច្រើននៅពេល យកសពទៅបូជា ឬបញ្ចុះគេយកទាំងមឈូស ទាំងសពទៅជាមួយគ្នាតែម្តង ចុះហេតុអ្វីបានជាថាយកសពបូជាផ្សេង ហើយមឈូសដែលតម្កល់សពនោះ បញ្ចុះជាមួយអដ្ឋិធាតុសពដែលបានបូជារួចទៅវិញ ។

នៅក្នុងសៀវភៅប្រវត្តិសាស្ត្រជាច្រើនទៀតបានសរសេរទុកមកថា ខ្មែរយើងសម័យដើមក្នុងការធ្វើពិធីបូជាសព ជាពិសេសសពស្តេច ឬ មន្ត្រីធំៗ គេយកឈើក្រអូបធ្វើជាមឈូសតម្កល់សព រួចហើយបូជា នូវមឈូសនោះជាមួយសពតែម្តង ។ បន្ទាប់មកគេយកផេះមឈូស ឈើក្រអូបនោះ និង អដ្ឋិធាតុស្តេច ឬ មន្ត្រីដែលអស់ពីបូជានោះ ប្រមូលដាក់កោដ្ឋទាំងអស់រួចហើយ បញ្ចុះក្នុងប្រាសាទ ។



www.elibraryofcambodia.org

ដូច្នេះការយល់ថាពាងទាំងអស់នោះជាមឈូសគឺខុសហេតុផល ឬខុសពីហេតុផលរបស់ខ្មែរ ពីសម័យដើម ក៏ដូចក្នុងបច្ចុប្បន្ននេះផងដែរ ។ ក៏ប៉ុន្តែការយល់ថាពាងនោះគឺជាឧបករណ៍សម្រាប់ដាក់ទឹក ថ្លានៅក្នុងប្រាសាទគឺវាស្របនឹងហេតុផលខ្មែរពីសម័យដើម ក៏ដូចបច្ចុប្បន្ននេះឯង ។ បច្ចុប្បន្នដូចបានសរសេរមកខ្លះៗ ហើយចេតិយភាគច្រើនគេតម្កល់ទឹកថ្លាដោយដាក់ក្នុងពាង ឬវត្ថុផ្សេងៗទៅតាមសម័យ។ បែបនេះក៏មិនមែនចេះតែធ្វើដែរ គឺវាមានជាប់បវេណីតៗគ្នាមកពីសម័យដើម ។

ចំពោះប្រភពដើមដែលនាំឱ្យមានបវេណីតម្កល់ទឹកទុកក្នុងចេតិយ ឬប្រាសាទតាំងពីសម័យដើម រហូតមកទល់បច្ចុប្បន្ននេះ គឺដឹងមិនច្បាស់ ដោយហេតុថា បវេណីនេះ វាមានតាំងពីសម័យដើមមក ដូច្នេះវាត្រូវបាត់បង់នូវច្បាប់ដើមអស់នៅតែបវេណី ។ បើតាមការ សន្និដ្ឋានបវេណីនេះ ប្រហែលជាកើតចេញពីទម្លាប់កូនចៅបម្រើមាតាបិតា ឬ អ្នកមានគុណជាច្រើនទៀតក្នុងពេលដែលមានជីវិតរស់នៅដូចជាទឹកក្តៅ ទឹកត្រជាក់ជាដើម លុះដល់ពេលគាត់ស្លាប់ទៅ នៅតែកាន់វត្តនេះជាប់ទេមិនដឹង ទើបបានជានាំគ្នាតម្កល់ទឹកត្រជាក់ក្នុងចេតិយ បញ្ចុះអដ្ឋិធាតុ អ្នកមានគុណទាំងនោះទៀត ។



www.elibraryofcambodia.org

សម័យបុរាណគេគោរពណាស់ ឪពុកម្ដាយក្នុងនោះដែរ ពេលគាត់មានជីវិតរស់នៅកូនចៅបានបម្រើគាត់ទាំងយប់ទាំងថ្ងៃ។ តែពេលយប់ គាប់ជួនកំពុងតែដេកលក់ គាត់ត្រូវការអ្វីកូនចៅមិនដឹង ឬពិបាករកជូនគាត់ ដូច្នេះក្នុងពេលនោះបុរាណលោកឱ្យត្រៀមបម្រុងនូវវត្ថុផ្សេងៗ សម្រាប់គាត់ ដូចខាងក្រោម :

ក. ពេលព្រលប់ត្រូវសិតទឹកដាក់ចុងជើង (តម្កល់) ក្រាល កន្ទេល និង រៀបចំមុងភួយខ្នល់ខ្នើយទុកសម្រាប់គាត់ឱ្យស្រេច ។

ខ. ប្រអប់ស្លា ឬប្រអប់បារី និងវត្ថុជាចាំបាច់ផ្សេងៗទៀតរៀបចំទុកដាក់ ទន្ទឹមនឹងស្មារបស់គាត់ ។

ប៉ុណ្ណេះជាដើម យើងអាចយល់បានខ្លះៗថា សម័យបុរាណគេគោរពណាស់ចំពោះលោកអ្នកដ៏មានគុណ មានមាតាបិតាជាដើម ។ យើងបកទៅពិចារណា នូវបទខាងដើមវិញម្ដងទៀត ដូចជាព្រះពុទ្ធជាម្ចាស់នៃយើងជាដើម កាលលោកគង់ព្រះជន្មនៅ ពួកភិក្ខុសង្ឃ សាវ័ក មានព្រះអានន្ទជាប្រធាន លោកតែងតែតាមបម្រើព្រះអង្គជានិច្ច ដូចជាក្រាលអាសនៈទុកសម្រាប់ព្រះអង្គគង់ជាដើម ។ លុះដល់ពេលព្រះអង្គ បរិនិព្វានទៅ បវេណីក្រាលអាសនៈ សម្រាប់ព្រះអង្គគង់ គេធ្វើតៗគ្នាជារហូតដើម្បីអធិដ្ឋានចំពោះព្រះអង្គ ហើយក្រាបថ្វាយបង្គំបូជាដោយសក្ការៈផ្សេងៗ ដូចពេលព្រះអង្គព្រះជន្មនៅដែរ ។ យូរៗក៏បែក



www.elibraryofcambodia.org

គំនិតជាប់ថ្មធ្វើជាបល្ល័ង្ក(អាសនៈ) របស់ព្រះអង្គ តែធ្វើបល្ល័ង្កទទេ មិនធ្វើរូបព្រះអង្គដាក់លើបល្ល័ង្កឡើយ ។ លុះដល់ពេលក្រោយមកទៀត ក៏បែកគំនិតនាំគ្នាធ្វើជារូបព្រះអង្គដាក់លើបល្ល័ង្កនោះ រហូតដល់ធ្វើព្រះវិហារ ឬចេតិយប្រាង្គប្រាសាទដាក់ទាំងបល្ល័ង្កទាំងរូបទាំង អស់នោះទៀតដូច យើងឃើញសព្វថ្ងៃនេះស្រាប់ ។

ដូច្នេះយើងគួរសន្និដ្ឋានបានថា ការតម្កល់ទឹកដាក់ក្នុងចេតិយ នោះប្រហែលជាប់បវេណីបម្រើមាតាបិតាឬអ្នកមានគុណផ្សេងៗទៀត ដោយទឹកក្តៅទឹកត្រជាក់ក្នុងពេលគាត់មានជីវិតរស់នៅនោះទេមិនដឹង បានជាគាត់ស្លាប់ទៅហើយ នៅតែតម្កល់ទឹកដាក់ក្នុងចេតិយបញ្ចុះគាត់នោះដែរ (នេះគ្រាន់តែជាការសន្និដ្ឋានរបស់ខ្ញុំទេ សូមបណ្ឌិតធ្វើការពិចារណាទៀតចុះ) ។ បច្ចុប្បន្នមានលេចឮដំណឹងខ្លះៗអំពីប្រភពនៃ ការតម្កល់ទឹកក្នុងចេតិយថា ដើម្បីឱ្យអ្នកមានគុណ នៅក្នុងចេតិយនោះត្រជាក់ត្រជុំ ហើយកូនបានត្រជាក់ត្រជុំដែរ ។

**មឈូស និង កោដ្ឋ**

មឈូស និងកោដ្ឋគឺជាវត្ថុដ៏ចម្បងមួយដែរ សម្រាប់តម្កល់ទុវសពឬអដ្ឋិធាតុបុគ្គលដ៏ខ្ពស់ៗ នៅក្នុងសាសនា ក៏ដូចជាសាមញ្ញជន តាមប្រទេសនានា មានស្តេចជាដើម ដើម្បីទុកធ្វើសក្ការបូជា ។ ដោយឡែកចំពោះមឈូស



www.elibraryofcambodia.org

និងកោដ្ឋទាំងពីរនេះវិញ វាមានតួនាទីផ្សេងៗគ្នា ។ មឈូសគឺជាវត្ថុសម្រាប់តម្កល់សព មុនពេលយកទៅបូជាឬកប់។ កោដ្ឋគឺជាវត្ថុ សម្រាប់ដាក់អដ្ឋិធាតុនៃសពក្នុងពេលបូជារួច ។

ដូច្នេះ សរុបសេចក្តីមកកោដ្ឋ និងមឈូសមិនខុសពីស្តូប ចេតិយ ប្រាង្គ ប្រាសាទ ប៉ុន្មានឡើយ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណា មឈូស និងកោដ្ឋទាំងពីរនេះផ្សេងពី ស្តូប ចេតិយ ប្រាង្គ ប្រាសាទ ។

**មូលហេតុនៃមឈូស និងកោដ្ឋ**

ចំពោះមូលហេតុដែលនាំឱ្យមាន ការធ្វើមឈូស និងកោដ្ឋឡើងជាដំបូងពុំមានឯកសារណាមួយមកបញ្ជាក់អំពីប្រភពដើម ឱ្យបានច្បាស់លាស់នោះទេ ។ ក្នុងគម្ពីរព្រះពុទ្ធសាសនាបានចារទុកមកថា នៅមុនសម័យពុទ្ធកាល ក៏ដូចសម័យពុទ្ធកាល និងក្រោយសម័យពុទ្ធកាលផងដែរ ការបូជាសពមានពិធីធំៗបួនបែបគឺយកទៅបណ្តែតទឹក១ បោះចោលក្នុងព្រៃស្មសាន ១ កប់ក្នុងព្រះធរណី១ និងបូជាដោយព្រះអគ្គី១។ បណ្តាពិធីទាំងបួនបែបនេះមានកត្តាដែលយើងគួរកត់សម្គាល់គឺ បោះចោលក្នុងព្រៃស្មសាន១ បូជាដោយព្រះអគ្គី១។ ការយកសពបោះចោលក្នុងព្រៃស្មសាន គេយកកំណាត់រុំពទ្ធ័ជុំវិញសព ។ យកទៅបូជាដោយព្រះអគ្គីខ្លះគេយកកំណាត់រុំសព នោះខ្លះគេ



www.elibraryofcambodia.org

មិនរុំរួចហើយគេធ្វើជាស្ពែងសែងយកទៅកន្លែងបូជា ។

ការធ្វើដូច្នេះប្រហែលជាមូលហេតុដើមនៃការធ្វើមឈូស ជាដំបូងទេដឹង។ ដោយហេតុថា ការធ្វើដូច្នោះយូរៗទៅ ក៏បែកគំនិតច្នៃប្រឌិត នាយអាយ រហូតមានរូបរាងដូចមឈូសសព្វថ្ងៃនេះ មកឬយ៉ាងណា។ នៅពេលព្រះពុទ្ធជាម្ចាស់នៃយើងលោកបរិនិព្វាន ពួកមល្លក្សត្របានធ្វើមឈូស អំពីឈើក្រអូប ហើយរុំដោយកំណាត់៥០០គូ លាបលនដោយប្រេងក្រអូបរួចហើយក៏បូជាសពព្រះអង្គ ដោយព្រះអគ្គីទៅ។ ការធ្វើបែបនេះ ព្រះលោកសម្ដែងទៅកាន់ព្រះអានន្ទក្នុងពេលទៀបបរិនិព្វានថា ម្នាលអានន្ទ ការបូជាសពព្រះពុទ្ធ ក៏ដូចជាស្ដេចចក្រពត្តិជាដើម ក៏គេធ្វើបែបនេះដែរ ។

ដោយហេតុនេះមូលហេតុនៃការធ្វើមឈូស ដាក់សព ឃើញថាមានប្រវត្តិវែងឆ្ងាយ មិនខុសពីចេតិយប៉ុន្មានឡើយ ។ ទន្ទឹមនេះ កោដ្ឋក៏មិនខុសពីមឈូសប៉ុន្មានដែរ នៅក្នុងរឿងរាមកេរ្តិ៍ ដែលជារឿងព្រេងមានតាំងពីបុរាណកាលមក យើងធ្លាប់ឮហើយត្រង់វគ្គមួយបានចែងថា "ព្រះរាមចូលកោដ្ឋ បញ្ឆោតព្រះនាងនាងសីតា" ។ តែទោះបីដូច្នេះក្ដី កោដ្ឋបើតាមការសន្និដ្ឋានប្រហែលជាកើតក្រោយមឈូស ឬកើតដំណាលគ្នានឹងមឈូស។ ព្រោះថាកាលបើគេយកមឈូស និងសពទៅបូជាដោយព្រះអគ្គី ហើយពេល



www.elibraryofcambodia.org

ខ្លះគេរើសយកអដ្ឋិធាតុទៅបោះក្នុងទន្លេ ពេលខ្លះ គេមិនរើសយកទៅបោះចោលក្នុងទន្លេទេ គឺគេយកមកខ្ចប់ទុកនឹងវត្ថុដែលអាចខ្ចប់ទុកបាន។ ត្រង់ចំណុចនេះ ហើយប្រហែលយូរៗ ទៅគេបែកគំនិតធ្វើជាកោដ្ឋឡើងរហូតទល់នឹងសព្វ ថ្ងៃ............ឬយ៉ាងណា ។

## ប្រវត្តិមឈូស និងកោដ្ឋ

ឥឡូវយើងបែរមកសិក្សាស្រាវជ្រាវនូវប្រវត្តិមឈូស និងកោដ្ឋក្នុងប្រទេសខ្មែរយើងម្តង ដើម្បីយល់កាន់តែច្បាស់អំពីប្រវត្តិវែងឆ្ងាយនៃមឈូស និងកោដ្ឋនេះ។ នៅប្រទេសខ្មែរយើង បើតាមឯកសារប្រវត្តិសាស្ត្ររបស់ចិនបានកត់ត្រាទុកមក (ប្រវត្តិសាស្ត្រ នៃព្រះរាជវង្ស លាង ពាក់កណ្តាលទី១ នៃស.ត ទី៦) មានសេចក្តីថា ក្នុងសម័យហ្វូណន ពិធីទុកដាក់សពមាន៤យ៉ាង (ដូចប្រទេសឥណ្ឌាដែរ) គឺបោះចោលក្នុងទឹក១ បូជាដោយភ្លើង១ ទុកចោលក្នុងព្រៃស្មសាន១ និងកប់ក្នុងព្រះធរណី១។ នៅសតវត្សរ៍បន្ទាប់ ប្រវត្តិសាស្ត្រនៃរាជវង្សស៊ុយ បានកត់ទុកមកដែរថា នៅប្រទេសចេនឡា បុណ្យសពគេធ្វើពិធីយ៉ាងឱឡារិកបន្ទាប់មកគេបូជាសពដោយឈើក្រអូប (មឈូសធ្វើអំពីឈើក្រអូប) ផេះ និងឆ្អឹងគេប្រមូលដាក់ កោដ្ឋមាស ឬប្រាក់ហើយយកទៅបណ្តែតតាមខ្សែទឹក ។ ចំពោះអ្នកក្រគេធ្វើកោដ្ឋអំពីដីដាក់។



www.elibraryofcambodia.org

បច្ចុប្បន្នប្រទេសខ្មែរនៅតែនិយមធ្វើកោដ្ឋដាក់អដ្ឋិធាតុ ដូចសម័យដើមដដែល ក៏ប៉ុន្តែដោយអាស្រ័យការរីកចម្រើនផ្នែកសំភារវត្ថុ ដូច្នេះការធ្វើកោដ្ឋក្នុងបច្ចុប្បន្នពួកអ្នកក្រ ឬប្រជារាស្ត្របានធ្វើអំពី ដែកខ្លះ ប្រាក់ខ្លះ ស្ពាន់ខ្លះ... ទៅតាមសមត្ថភាព តែការធ្វើអំពីដីមិនសូវមានដូចមុនឡើយ បើមានគឺគេធ្វើអំពីថ្មវិញ។ បើតាមបវេណីបច្ចុប្បន្ន កោដ្ឋដែលដាក់នូវអដ្ឋិធាតុក៏គេមិនសូវយកទៅបោះចោលក្នុងទឹកទន្លេដូចមុន ដែរគឺគេធ្វើជាចេតិយដាក់យ៉ាងត្រឹមត្រូវជាទីបំផុត ។

នៅតំបន់ខ្លះ ដោយអាស្រ័យទម្លាប់ពីមុនមកផង ឬអាស្រ័យ នូវការខ្វះខាតជាដើមផង ចំពោះអដ្ឋិធាតុ ដែលដាក់ក្នុងកោដ្ឋនេះគេ មិនបានធ្វើចេតិយដាក់ទេគឺគេធ្វើជាហ៊ឹងដាក់វិញ។ ចំពោះហ៊ឹងដែលគេ ធ្វើដាក់នោះ គឺគេធ្វើនៅលើផ្ទះ អំពីក្ដារបន្ទះ យ៉ាងសមសួនហើយយក កោដ្ឋទៅតម្កល់ទុកលើនោះ សម្រាប់ធ្វើសក្ការបូជា។ ចំពោះអ្នកខ្លះទៀត គេមានសមត្ថភាពល្មាក់ល្មម គេធ្វើជារានទេវតានៅក្បែរផ្ទះ ឬមុខផ្ទះរួចហើយក៏យកកោដ្ឋទៅតម្កល់ទុកក្នុងទីនោះ ។

ដោយឡែកចំពោះខាងមឈូសវិញ បច្ចុប្បន្នចំពោះ ប្រទេសខ្មែរយើងនៅតែនិយមធ្វើដូចសម័យដើមដដែល ក៏ប៉ុន្តែបច្ចុប្បន្ន ទោះបីស្ដេចក៏



www.elibraryofcambodia.org

ដោយ រាស្ត្រក៏ដោយគឺមិនធ្វើអំពីឈើក្រអូបដូចមុនទេ ។ ដោយហេតុថា បច្ចុប្បន្ននេះមិនងាយនឹងរក ឈើក្រអូបបានដូចមុនឡើយ ។ តែទោះបីជាយ៉ាងណា ចំពោះមឈូសស្តេច ឬមន្ត្រីធំៗវិញគេ បានជ្រើសយកប្រភេទឈើខ្លឹមដ៏ល្អមកធ្វើ ហើយថែមទាំងរចនាក្បូរក្បាច់ជាច្រើននៅតួខាងក្រៅនៃមឈូសនោះថែមទៀត មើលទៅគួរឱ្យជ្រះថ្លា ចំពោះអ្នកក្រ ឬរាស្ត្រសាមញ្ញធម្មតាវិញ គេធ្វើមឈូស អំពីឈើធម្មតា ដែលគេអាចធ្វើបាន ហើយមិនសូវរចនាក្បូរក្បាច់ផ្សេង ៗ នៅផ្នែកខាងក្រៅនៃមឈូសនោះដូចមឈូសស្តេច ឬមន្ត្រីធំៗឡើយ ។

បើមានគឺគេគូរដោយថ្នាំផ្សេងៗ ឬយកក្រដាសពណ៌ ឬក្រដាសមានផ្កាភ្ញីជាច្រើនគូរ ឬបិទនៅលើផ្នែកខាងក្រៅនៃមឈូសនោះវិញ ។

នៅក្នុងតំបន់ភាគខ្លះ នៃប្រទេសកម្ពុជា គេមានជំនឿតៗគ្នា មកថា កាលបើឪពុកម្តាយដល់វ័យចាស់ជរាហើយ កូនចៅគួរណាស់តែ ធ្វើជាមឈូសជាដើម ជូនដល់ឪពុកម្តាយឱ្យហើយ ទាន់គាត់មានជីវិតរស់នៅ ។ ដូច្នេះចំពោះកូនចៅខ្លះដែលមានសមត្ថភាពធ្វើបាន គេក៏ធ្វើមឈូសទាំងតួជូនចំពោះឪពុកម្តាយគេដោយផ្ទាល់ដៃ។ ក្នុងខណៈដែលជូនមឈូសចំពោះឪពុកម្តាយនោះ គេធ្វើពិធីសង្ឃទាន ឬក៏ជូនកាលធ្វើជាពិធីបុណ្យដ៏ធំដូចជាចម្រើន



www.elibraryofcambodia.org

ព្រះជន្ម និងបច្ច័យបួនជាដើម ដល់គាត់រួចហើយ ក៏ជូននូវមឈូសនោះ ក្នុងវេលានោះទៅ ។ គេធ្វើដូច្នេះមិនមែនដើម្បីបន់ឱ្យគាត់រហ័សស្លាប់នោះទេ គឺគេយល់ថា គឺជាផ្ទះថ្មីសម្រាប់គាត់នៅពេលដែលគាត់ស្លាប់ទៅ ។ ចំពោះ ឪពុកម្តាយវិញ ដោយជំនឿមានតៗមកជាយូរហើយ ដូច្នេះគាត់ត្រេកអរ ផុតលេខ ចំពោះមឈូសនោះ និងកូនបានជូនគាត់ផងដែរ ។

## ពិធីតម្កល់សពក្នុងមឈូស

មឈូសដូចយើងបានដឹងខ្លះៗមកហើយ ដែលមានសរសេរនៅខាងលើនេះឯង គឺវាជាផ្ទះថ្មី ឬជាផ្ទះចុងក្រោយរបស់មនុស្ស ។ បុរាណលោកពោលថា ម៉ុងឈើ (មឈូស) "បុថុជ្ជនយើងម្នាក់ៗ ចង់បានមិន ចេះចប់ទេ លុះត្រាតែដេក (ស្លាប់) ក្នុងម៉ុងឈើទើបចប់" ។ ដោយឡែកក្នុងពេលយកសពតម្កល់ក្នុងមឈូសនោះ គឺមានជាពិធី ផ្សេងៗទៅតាមការនិយមធ្វើតៗគ្នាជាហូរហែមក ។ ក្នុងទីនេះមិនបាន លើកយកមកសរសេរដោយពិស្តារទេ សូមស្រាវជ្រាវនូវពិធីនេះ ទៅតាមច្បាប់ទម្លាប់នានាបន្ថែមទៀតចុះ ។ ក៏ប៉ុន្តែសូមបញ្ជាក់ជាគោលៗថា មុនពេលគេយកសព ដាក់មឈូសនោះវិធីដែលគេខានមិនបាន គឺការចំអាសទឹកឱ្យសព (ជម្រះទឹកឱ្យសព) ដើម្បី



www.elibraryofcambodia.org

បំបាត់ក្លិនអសោចិ៍ ។ បន្ទាប់មកគេផ្លាស់សំលៀកបំពាក់ថ្មី ព្រមទាំងមាន លាបលននូវគ្រឿងក្រអូបជាដើម ទៀតផង ។

លុះចប់កិច្ចសង្ខេប១ នៅខាងលើរួចមកមឈូស ដែលតម្កល់សពនោះ ត្រូវទុកនៅលើផ្ទះសព ឬផ្ទះញាតិតាមការគួរ ដើម្បីឱ្យកូនចៅធ្វើសក្ការបូជា។ បច្ចុប្បន្នការតម្កល់សពក្នុងមឈូសនោះ គឺមានច្រើនផ្នែកទៅតាមបវេណី ដែលធ្លាប់ធ្វើត១គ្នាមក ក៏ប៉ុន្តែបើចែកដោយ សង្ខេបមាន២ យ៉ាងគឺ :

ក- បវេណីចិន(ខុងជឺ): គេតម្កល់សពទៅតាមហុងស៊ុយ ដែលមាន ចែងជាច្បាប់ទុក។ បើសិនជើងលេខហុងស៊ុយត្រូវចេញក្នុងថ្ងៃស្លាប់ ជួនកាល គេចេញក្នុងថ្ងៃស្លាប់នោះតែម្តង តែបើកូនចៅគេចូរចារដែរ គេរង់ចាំថ្ងៃល្អ ទៅមុខទៀត ហើយគេតម្កល់សពទុករហូតដល់ថ្ងៃនោះ ទោះបី ៤ ឬ ៥ ថ្ងៃ ក៏ដោយ ។

ខ- បវេណីខ្មែរ : ពុំមានលក្ខឋានច្បាស់លាស់ដូចចិនទេ ហើយរួម ទាំងច្បាប់ព្រះពុទ្ធសាសនាផង ក៏ដូចគ្នាដែរ។ តែទោះបីដូច្នេះក្តី ក៏មិនមែន ស្លាប់ភ្លាមយកទៅបូជាភ្លាមដែរ គឺគេចាត់ចែងយ៉ាងសមសួន រួចហើយតម្កល់ ទុក ក្នុងការគួររហូតដល់ពេល ដែលគេរៀបចំពិធីដង្ហែទៅបូជាបាន ។



www.elibraryofcambodia.org

កំប៉ុន្តែសព្វថ្ងៃ ចំពោះការតម្កល់សពទុកក្នុងមឈូសនេះខ្មែរ និងចិន គឺខុសត្រូវគ្នាបន្តិចបន្តួច។ សពស្តេច ឬមន្ត្រីធំៗ ឬក៏អ្នកមាន ផ្សេងៗទៀត តម្កល់យ៉ាងតិច៣ថ្ងៃ ឬ៧ថ្ងៃទើបយកទៅបញ្ចុះ ឬបូជា ជួនកាលតម្កល់ទុករហូតដល់រាប់ខែ រាប់ឆ្នាំក៏មាន ទៅតាមលទ្ធភាពដែលអាចធ្វើបានដោយសម័យបច្ចុប្បន្នមិនព្រួយស្អុយ ព្រោះមានឧបករណ៍វិទ្យាសាស្ត្រអាចការពារកុំឱ្យស្អុយបាន ។

**អត្ថន័យនៃការតម្កល់សព**

ការតម្កល់សពក្នុងមឈូសទុកនេះ វាអាស្រ័យនូវហេតុជាច្រើនណាស់ ដែលអ្នករស់នៅ( អាចារ្យ ឬកូនចៅ) បានយល់ឃើញ។ តែបែបនេះ មិនមែនទើបតែមានក្នុងបច្ចុប្បន្ននេះទេ គឺវាមានតាំងពីសម័យបុរាណកាលមកម្ល៉េះ ដូច្នេះហើយចេះតែធ្វើតៗគ្នាមកខ្លះ ហើយនិងរួមផ្សំនូវហេតុដែលយល់ឃើញរៀងៗខ្លួនខ្លះ។ បើប្រមូលរួបរួមនូវហេតុទាំង នោះឱ្យខ្លីមកមាន ៣ យ៉ាងធំៗគឺ :

ក. តម្កល់ទុកចាំរៀបចំធ្វើនូវពិធីផ្សេងៗ (បុណ្យសព) ឱ្យត្រូវតាមគន្លងបវេណីជាតិ ឬសាសនាសិន ។



www.elibraryofcambodia.org

ខ. តម្កល់ទុកចាំកូនចៅ ឬ សាច់ញាតិនៅឆ្ងាយៗដែលពុំទាន់ មកដល់ ឬ ពុំទាន់មកជុំគ្នាឱ្យបានឃើញមុខសពចុងក្រោយ ឬបានហែទៅបូជាជាមួយដែរ ។

គ. តម្កល់ទុកចាំដល់ថ្ងៃល្អ ត្រូវចេញ (ចិន) (ជើងលេខ ហុងស៊ុយ) ទើបយកទៅបូជា (កប់) តែម្តង ។

បណ្តាហេតុទាំង៣ នៅខាងលើ ហេតុទី១ និងទី២ (ក.ខ.) មានអត្ថន័យត្រូវគ្នានឹងច្បាប់ដែលមានចែងជាប្រវត្តិក្នុងព្រះពុទ្ធសាសនា ។ ក្នុងពេលព្រះពុទ្ធជាម្ចាស់នៃយើង លោកបរិនិព្វាន ពួកមល្លក្សត្របានតម្កល់ព្រះសពព្រះអង្គក្នុងមឈូសឈើក្រអូបអស់រយៈពេល៧ថ្ងៃ ហើយនាំគ្នាធ្វើនូវពិធីបុណ្យ និងធ្វើសក្ការបូជាដ៏ច្រើនក្រៃលែង មានស្តេចនៅនគរផ្សេងៗចូលរួមចំណែកក្នុងពិធីនេះផងដែរ ។ លុះដល់ថ្ងៃទី៧ ព្រះមហាកស្សបៈ ដែលជាសាវ័ករបស់ព្រះអង្គ ផ្នែកទ្រទ្រង់វិន័យមានរក្សានូវធុតង្គជាដើម លោកនាំកូនសិស្សទាំង៥០០អង្គ មកជុំអស់ហើយ ក៏នាំគ្នាបូជាព្រះសពព្រះអង្គក្នុងថ្ងៃនោះទៅ ។

ដូច្នេះមិនថាបច្ចុប្បន្ន ឬអតីតឡើយនៅពេលបុគ្គលជាអ្នកមានគុណ ឬជាញាតិមិត្តជាដើម បានធ្វើមរណកាលហើយ ទោះជាយ៉ាងណាគេមិនយក



www.elibraryofcambodia.org

សពលោកទាំងនោះទៅបូជាដោយភ្លាម១ពេកទេ គឺគេតម្កល់ទុកនូវសពនោះក្នុងមឈូសសិន ជាពិសេសក្នុងពេលបច្ចុប្បន្ននេះឯង។ ហេតុនេះ មឈូសជាវត្ថុចាំបាច់មុនចេតិយ។ល។ ទាំងអស់ជាវត្ថុ ដ៏ថ្លៃថ្នូរបំផុតសម្រាប់អ្នករស់ធ្វើចំពោះអ្នកស្លាប់ ដើម្បីស្វែងរកប្រយោជន៍ជាច្រើន ជាពិសេសបុណ្យកុសល ។

**ពិធីរើសអដ្ឋិធាតុដាក់កោដ្ឋ**

ការរើសអដ្ឋិធាតុ(ឆ្អឹង) សពដែលបានបូជាដោយព្រះអគ្គីនេះ គឺមានពិធីធ្វើច្រើនបែប ច្រើនយ៉ាងណាស់ តែពិធីដែលចាំបាច់ខានមិនបាន ត្រូវតែធ្វើក្នុងពេលរើសនូវអដ្ឋិធាតុរួចនោះ គឺពេលលាងជម្រះនូវអដ្ឋិធាតុនោះឱ្យស្អាត ដើម្បីកុំឱ្យប្រឡាក់ដី ឬផេះធ្យូងជាដើម។ នេះទុកដូច ការចំអាសទឹក (ជម្រះទឹក) លើកទី ២ សម្រាប់បុគ្គលដែល ស្លាប់ទៅនោះ ។

ទឹកដែលគេយកមកលាងជម្រះនូវអដ្ឋិធាតុនោះ គឺមានជាបែបផ្សេងទៅតាមបវេណីដែលធ្លាប់ធ្វើ ។ កន្លែងខ្លះគេយកទឹកដូងមកលាងជម្រះ និងកន្លែងខ្លះទៀតគេយកទឹកទន្លេលាងសំអាតវិញ។ ដោយឡែក កន្លែងដែលនៅឆ្ងាយពីទន្លេ និងកន្លែងពុំសូវមានផ្លែដូង គឺគេលាងជម្រះ នឹងទឹកធម្មតា។ ការលាងជម្រះដោយទឹកដូង ឬទឹកទន្លេគេយល់ ត១គ្នាមកដូចខាងក្រោម :



www.elibraryofcambodia.org

ក. ការលាងជម្រះដោយទឹកដូង ដោយហេតុថា វាមានរសផ្អែម ហើយជាទឹកនឹង មិនមានកករ ជាទឹកបរិសុទ្ធស្អាតអំពីកំណើត ។ ទឹកដូងនេះ ប្រៀបបាននឹងព្រះរាជហឫទ័យព្រះដ៏មានបុណ្យ ដែលព្រះអង្គពុំមានសេចក្ដី ក្រោធចំពោះមនុស្សឡើយ ។ ក្រៅពីទឹកដូងទៅ នៅមានសាច់ដូងនោះទៀត ដែលមានផលដ៏អស្ចារ្យដែរ គឺសាច់ដូងបើមនុស្សមានប្រាជ្ញាយកខ្ទោសកោស រុះច្របាច់យកទឹកខ្ទិះទៅច្នៃធ្វើជាអាហារភោជនផ្សេងៗក្ដី នឹងមានឱជារស ប្រសើរដូចព្រះខីណាស្រព ។ ស្ដេចគោចរបិណ្ឌបាត្រជាបុណ្យដូចបានបរិភោគ ដូងចាស់មានខ្ទិះនោះឯង ឯចិត្តពាលឃោរឃៅដូចដូងមានតែលលាដ៏ និង សំបកដូងទទេរកសាច់ពុំមានឡើយ ។

នេះគឺជាអត្ថន័យនៃការយកទឹកដូងមកលាងជម្រះនូវអដ្ឋិធាតុ គឺ ដើម្បីបង្ហាញនូវទឹកចិត្តដ៏ល្អរបស់ព្រះដ៏មានព្រះភាគជាម្ចាស់នៃយើង និងព្រះ អរហន្ត ខីណាស្រព ជាច្រើនអង្គទៀត ឱ្យសព្វសត្វកើតចិត្តជ្រះថ្លាហើយឱ្យ ខំប្រតិបត្តិល្អឱ្យលុះមគ្គផលដូចព្រះអង្គដែរ ។ មួយទៀត នៅក្នុងកន្លែងខ្លះ បានជាគេយកទឹកដូងមកលាងជម្រះអដ្ឋិធាតុនោះ គឺដើម្បីយកទឹកដូងដែល លាងរួចចែកកូនចៅផឹក ឱ្យបានត្រជាក់ត្រជុំដល់កូនចៅ ។

ខ. ការលាងជម្រះដោយទឹកទន្លេ ឬទឹកធម្មតា ដោយគេយល់ឃើញ



www.elibraryofcambodia.org

ថាទឹកទន្លេ ឬទឹកធម្មតាវាមានភាពត្រជាក់ត្រជុំ ដូច្នេះយកទឹកនោះមកលាងជម្រះ គឺដើម្បីភាពត្រជាក់ត្រជុំដល់កូនចៅដូចទឹកទន្លេ និងទឹកធម្មតានោះដែរ ។

**អត្ថន័យនៃការរើសអដ្ឋិធាតុដាក់កោដ្ឋ**

កោដ្ឋក៏ជាវត្ថុមួយចម្បង ផងដែរបន្ទាប់ពីមឈូស។ ព្រោះថា កាលណាបើគេបូជាសពរួចហើយ គេត្រូវតែរើសយកអដ្ឋិធាតុដែលនៅសល់ពីបូជានោះដាក់កោដ្ឋ។ នៅកន្លែងខ្លះ គេធ្វើនូវពិធីអភិសេកអដ្ឋិធាតុ ដែលដាក់ក្នុងកោដ្ឋនោះទៀត តែនេះមិនសូវទូទៅប៉ុន្មានទេ។ ចំពោះអត្ថន័យ ដ៏ធំធេងក្នុងការរើសនូវអដ្ឋិធាតុដាក់ក្នុងកោដ្ឋនោះមាន ចំនួនច្រើនមហិមាតែក្នុងពេលនេះ ចែកដោយសង្ខេបមាន៣ យ៉ាងគឺ:

ក. សម្រាប់យកទៅបញ្ចុះក្នុងចេតិយ ជាការងាយស្រួលមិនពិបាករាត់រាយ ។

ខ. សម្រាប់យកទៅទុកដាក់លើហ៊ឹងលើផ្ទះ ឬទូកញ្ចក់ ងាយស្រួលថែរក្សា ។

គ.សម្រាប់យកទៅបោះចូលក្នុងទឹកទន្លេ ងាយស្រួលបោះមិនឱ្យបែកខ្ចាត់ខ្ចាយ (សម័យដើម) ។



www.elibraryofcambodia.org

## ៥. ការគោរពបូជាចំពោះអដ្ឋិធាតុ

ការគោរពបូជាចំពោះអដ្ឋិធាតុនេះ យើងបានដឹងជាគោល១ មកខ្លះ១ ហើយ ដូចជាការធ្វើស្តូប ចេតិយ ប្រាង្គ ប្រាសាទ មឈូស កោដ្ឋ ។ល។ សម្រាប់បូជា។ ក្រៅពីនេះនៅមានការគោរពបូជាជាច្រើនបែបទៀត ដូចជា ការក្រាបថ្វាយបង្គំ និងការបូជាទៅដោយផ្កាកម្រងគ្រឿងក្រអូបជាដើម ។ កាលពីដំបូង គេគោរពបូជាដូច្នេះគឺ ចំពោះតែបុគ្គលខ្ពស់ៗ ដូចជាព្រះពុទ្ធ១ ព្រះបច្ចេកពុទ្ធ១ ព្រះអរហន្ត១ ស្តេចចក្រពត្តិ១។ លុះពេលជា ខាងក្រោយក៏ដូចជាបច្ចុប្បន្ននេះដែរ ក្រៅពីបុគ្គល៤ ពួកនេះ មានស្តេច មន្ត្រី គ្រូឧបជ្ឈាយាចារ្យ មាតាបិតាជាដើម ក៏គេបូជាចំពោះអដ្ឋិធាតុលោកដូច បុគ្គល៤ ពួកដែរ។ បែបនេះដោយយកលំនាំនៃការបូជាចំពោះ អដ្ឋិធាតុបុគ្គល ៤ ពួកពីខាងដើម ។

លក្ខណៈនៃការក្លាយដូចខាងលើនេះ បើយើងធ្វើការវិភាគទៅ ដូច ជាមិនខុសឆ្គងអ្វីទេ ដោយហេតុថា ទីមួយ បច្ចុប្បន្នពិបាករកនូវអដ្ឋិធាតុ បុគ្គលក្រៅពីបុគ្គលទាំង៤ ពួកនោះមកគោរពបូជាពេក ទីពីរ បុគ្គលក្រៅពី បុគ្គល៤ ពួកនោះទៅដូចជាស្តេច មន្ត្រី គ្រូឧបជ្ឈាយាចារ្យ មាតាបិតាជាដើម ក៏គួរគោរពបូជាដូចគ្នាដែរ ព្រោះលោកមានគុណជាច្រើនមកលើប្រជានុរាស្ត្រ



www.elibraryofcambodia.org

សិស្សគណកូនចៅ ។ល។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គលោកចែកនូវប្រភេទនៃបុគ្គលដែលមានគុណនេះជា ៤ពួកគឺ :

ក- ព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធបរិស័ទ ។

ខ- ព្រះរាជាជាបុព្វការីរបស់ប្រជានុរាស្ត្រ ។

គ- គ្រូជាបុព្វការីរបស់សិស្សានុសិស្ស ។

ឃ- មាតាបិតាជាបុព្វការីរបស់បុត្រ ។

ក្នុងនាមជាអ្នកជ្រកក្រោមឧបការៈដ៏បរិសុទ្ធរបស់គេ ព្រះពុទ្ធជាម្ចាស់ ទ្រង់បំភ្លឺទុកមកថា ត្រូវតែធ្វើនូវកតញ្ញូកតវេទីតាធម៌ ចំពោះគេវិញ ឱ្យបានគ្រប់ពេលជានិច្ច ។ ក្នុងន័យនេះលោកចង់បញ្ជាក់នូវអត្ថន័យពីរធំៗគឺ ត្រូវធ្វើតាំងតែពីពេលលោកមានជីវិតរស់នៅផង និងពេលលោកលាចាកលោកនេះទៅផង ។

**អង្គរបស់កតញ្ញូមាន ២យ៉ាងគឺ**

ក- កាលសម័យ : គឺពេលអ្នកមានគុណមានជីវិតរស់នៅ ត្រូវតែគោរពបូជាចំពោះលោកនូវគ្រឿងសក្ការៈផ្សេងៗដូចជាបច្ច័យទាំង៤ និងទានវត្ថុទាំង ១០ជាដើម ទំនុកបម្រុងលោកដរាបដល់អស់ជីវិត ។

ខ- អកាលសម័យ : គឺពេលអ្នកមានគុណបានលាចាកលោកទៅ



www.elibraryofcambodia.org

ហើយ ត្រូវតែគោរពបូជាលោកទៅដោយការឧទ្ទិសនូវបុណ្យកុសលផ្សេងៗ មានបុណ្យទក្ខិណានុប្បទានជាដើម ។

បុគ្គលកាលធ្វើត្រូវលើអង្គទាំងពីរខាងលើនេះហើយ លោកឱ្យឈ្មោះថា "កតញ្ញូកតវេទី" ។ ដោយឡែកបើធ្វើមិនត្រូវអង្គទាំងពីរនេះទេ ឬ ធ្វើមិនគ្រប់ទាំងពីរខ្វះមួយណា ដូច្នេះមិនទាន់បានពេញលក្ខណៈកតញ្ញូកតវេទីឡើយ។ ដោយហេតុថាគុណគឺសេចក្ដីល្អ លោកបានធ្វើមកលើនោះគឺធ្វើពីពេលដើម មិនមែនក្នុងពេលជាខាងចុងដូចជាបានធំហើយ បានចេះហើយ និងបានរស់ហើយជាដើមនោះទេ។ ជាការជាក់ស្ដែងដូចជាព្រះពុទ្ធទ្រង់ធ្វើឧបការគុណដល់មនុស្សសត្វក្នុងពេលដែលមានអវិជ្ជា ព្រះរាជាទ្រង់ធ្វើឧបការគុណដល់ប្រជារាស្ត្រក្នុងពេលស្រុកក្រ គ្រូធ្វើឧបការគុណដល់សិស្សក្នុងពេលដែលសិស្សមិនទាន់ចេះ និងមាតាបិតាគាត់ធ្វើឧបការគុណដល់កូនក្នុងពេលមិនទាន់កើត ។ល។។

**ប្រភេទនៃគុណ**

គុណមានច្រើនប្រភេទណាស់ ដោយហេតុថា បុគ្គលម្នាក់ៗដែលមានជីវិតរស់នៅលើលោកនេះគឺត្រូវពឹងគ្នាទៅវិញទៅមក ក្នុងភាសាបាលីហៅថា "សង្គហធម៌" (សង្គ្រោះ)។ បុគ្គលបើរស់នៅដោយខ្វះនូវធម៌នេះចំពោះគ្នា



www.elibraryofcambodia.org

និងគ្នាហើយ គឺការរស់នៅរបស់បុគ្គលនោះៗមិនបានសុខស្រួលឡើយ វាមិនខុសពីការរស់នៅរបស់សត្វនោះទេ ។ ព្រះពុទ្ធជាម្ចាស់លោកយល់ឃើញដូច្នេះហើយ ទើបលោកសម្តែងទុកមកថា "សង្គហធម៌" គឺធម៌ដែលត្រូវសង្គ្រោះចំពោះគ្នាទៅវិញទៅមកមាន ៤យ៉ាងគឺ :

ក- ទាន : ការឱ្យទាន

ខ- បិយវជ្ជ : ពោលពាក្យល្អ

គ- កល្យាណមិត្តតា : ភាពជាមិត្តល្អ

ឃ- សមជីវិតា : ភាពជាអ្នកមានជីវភាពស្មើ ។

ដូច្នេះបុគ្គលណាក៏ដោយ បានជួយសង្គ្រោះបុគ្គលដទៃដោយសង្គហធម៌ទាំងនេះ ដូចមាននៅខាងលើស្រាប់ហើយបុគ្គលនោះឈ្មោះថាអ្នកមានគុណមួយដែរ នៅមានធម៌ជាច្រើនទៀតដែលបុគ្គលម្នាក់ៗ បានធ្វើទៅលើអ្នកដទៃដើម្បីឱ្យកើតប្រយោជន៍ និងសេចក្តីសុខគ្រប់បែបយ៉ាងជាដើមហើយរាប់ថាជាអ្នកមានគុណដែរ ។ ក្នុងទីនេះបើនិយាយអំពីប្រភេទបុគ្គលដែល មានគុណនៅក្នុងលោកទាំងប៉ុន្មានដោយសង្ខេបខ្លីវិញ គឺមាន ៤យ៉ាង :

ក- ព្រះពុទ្ធមានគុណ៣ យ៉ាងគឺ :

១- បញ្ញាគុណ : គុណគឺប្រាជ្ញា



www.elibraryofcambodia.org

២- វិសុទ្ធិគុណ : គុណគឺសេចក្តីបរិសុទ្ធ

៣- ករុណាគុណ : គុណគឺករុណា ។

ខ- ព្រះរាជាមានគុណ ១០យ៉ាង គឺ

១- ទាន : ចេះធ្វើអំណោយ (គឺចេះចែកផ្តារស់)

២- សីល : ចេះធ្វើកាយ វាចាចិត្ត ឱ្យសុចរិតទៀងត្រង់ យុត្តិធម៌ និង វៀរបង់អំពើអាក្រក់គ្រប់យ៉ាង (មិនធ្វើអាក្រក់)

៣- ចាគ : ចេះលះបង់សេចក្តីកំណាញ់ ហើយបរិច្ចាគទ្រព្យសម្បត្តិ កសាងប្រយោជន៍សង្គមប្រយោជន៍សាធារណៈ(គឺមិនអាត្មានិយម) ។

៤- អាជ្ជវ : មានចិត្តប្រកាន់សច្ចធម៌ (គឺនិយាយបែបណាធ្វើ បែប នោះ) ។

៥- មទ្ទវៈ ចេះបន្ទន់ឥរិយាបថ និងចិត្តគំនិត (គឺប្រើសំដីពីរោះផ្អែម ល្ហែម) ។

៦- តប : ចេះព្យាយាមកម្ចាត់ ចោលនូវសេចក្តីអាក្រក់ចេញ ពីខ្លួន (ទាំងកាយ វាចា ចិត្ត) ហើយតាំងខ្លួនឱ្យនៅក្នុងអំពើល្អជានិច្ច (គឺរាំង ស្កាត់ សេចក្តីអាក្រក់) ។



www.elibraryofcambodia.org

៧- អក្កោធន : មិនសំម្តែងអាការៈច្រងេងច្រងាង ទទឹងទាស់ (គឺមិនធ្វើឱ្យគេខឹង) ។

៨- អវិហឹសា : មិនសងសឹក មិនប្រព្រឹត្តបៀតបៀនអ្នកដទៃហ៊ាន ទទួល ឬឆាប់មើលឃើញទោសកំហុសខ្លួន មិនចាប់កំហុសអ្នកដទៃខុសបែប បទ។

៩- ខន្តី : ចេះអត់ធ្មត់ អត់ធន់

១០- អវិរោធន : មិនធ្វើអ្វីឱ្យខុសឆ្គងពីគន្លងច្បាប់ (គឺគោរព ប្រតិបត្តិ តាមច្បាប់ជានិច្ច) ។

គ-គ្រូមានគុណ ៥យ៉ាង គឺ

១-សុវិនីតំវិនេន្តិ : គ្រូគប្បីទូន្មានសិស្សឱ្យបានបទល្អ ឱ្យចេះប្រើ ឥរិយាបថ ទាំង៤ គឺ ដេក ដើរ ឈរ អង្គុយ ជាដើមឱ្យមានរបៀបរៀបរយ សមរម្យល្អក្នុងទីប្រជុំជន មិនឱ្យឆ្គាំឆ្គង នឹងភ្នែកអ្នកដទៃ ។

២- សុគហិតំ គាហាបេន្តិ : ញ៉ាំងសិស្សឱ្យរៀនល្អ គឺបង្ហាត់ បង្រៀន នូវអត្ថ និងព្យញ្ជនៈ ឱ្យបានត្រឹមត្រូវចេះប្រើរបៀបសេចក្តីពាក្យល្អអធិប្បាយ ពន្យល់ហេតុផលឱ្យចូលចិត្តយល់បានពិតប្រាកដ ។



www.elibraryofcambodia.org

៣- សព្វសិប្បេសុតំ : អាចារ្យគប្បីបង្ហាត់សិល្បវិទ្យាឱ្យអស់ចំណេះដឹងមិនលាក់ទុកមកប៉ុន្មាន ក៏បង្ហាត់បង្រៀនសិស្សឱ្យអស់តាមចំណេះវិជ្ជា ចេះចាំរបស់ខ្លួនដោយមានឆន្ទៈល្អ គឺចង់ឱ្យសិស្សចេះចាំដូចខ្លួន ឬលើសទៅទៀតរឹតតែប្រសើរ ។

៤-មិត្តាមច្ចេសុបដិវេទេន្តិ : លើកតម្កើងចំពោះមិត្រអាមាត្យបើយល់ ឃើញថាសិស្សណាមួយ មានចំណេះវិជ្ជា មានចរិយាសណ្ដាប់ធ្នាប់សមរម្យល្អ គួរយកគុណសម្បត្តិនោះមកបង្ហាញសរសើរក្នុងទីចំពោះមុខមិត្រអាមាត្យជាសម្លាញ់របស់ខ្លួន ដើម្បីឱ្យមិត្ររបស់ខ្លួនមានសេចក្ដីទុកចិត្តស្និទស្នាលរាប់អាន និងការទំនុកបម្រុងជាដើមដល់សិស្ស ។

៥-ទិសាសុបរិត្តានំ ករោន្តិ : ធ្វើសេចក្ដីការពារគ្រប់ទិសទាំងឡាយបើសិស្សទៅទីណាមិនឱ្យលំបាក ដូចជាការចេញទៅរៀនទៅសូត្រ ចំណេះវិជ្ជាផ្លូវលោក ផ្លូវធមិជាដើម ចេះពន្យល់ណែនាំហេតុផល ឱ្យយល់ពីប្រយោជន៍នៃការសិក្សាទាល់តែសិស្សមានចិត្តជ្រះថ្លាព្យាយាមក្នុងការសិក្សា ហើយត្រូវជួយទំនុកបម្រុងសិស្ស គ្រឿងសិក្ខូបករណ៍តាមមាន តាមបានល្មមឱ្យសិស្សមានសេចក្ដីរីករាយស្រឡាញ់ពេញចិត្តក្នុងកិច្ចសិក្សា ។

ឃ-មាតាបិតាមានគុណ៥ យ៉ាង គឺ :



www.elibraryofcambodia.org

១- បាបានិវារេន្តិៈ ហាមឃាត់កូនមិនឱ្យធ្វើកម្មអាក្រក់ មានឃាត់មិនឱ្យសម្លាប់សត្វ និងមិនឱ្យលួចទ្រព្យគេជាដើម ។

២-កល្យាណេ និវេសេន្តិ : ឱ្យកូនតម្កល់នៅក្នុងកម្មជាកុសល មានទាន និងសីលជាដើម ។

៣-សិប្បំ សិក្ខាបេន្តិ : ឱ្យកូនសិក្សារៀនសិល្បសាស្ត្រចំណេះវិជ្ជា ដែលគួររៀនមានអក្សរ និងលេខជាដើម ។

៤-បដិរូបេន ទារេន សំយោជេន្តិ : រៀបចំឱ្យកូនមានភរិយា ឬស្វាមី តាមសមគួរដល់ជាតិ និងត្រកូល និងទ្រព្យសម្បត្តិ ។

៥-សមយេ ទាយជ្ជំ និយ្យាទេន្តិ : ឱ្យទ្រព្យសម្បត្តិដល់កូន ក្នុងពេលដែលកូនមានភរិយាស្វាមី ។

**កិច្ចនៃការសងគុណ**

គុណមានគុណានុភាពដ៏អស្ចារ្យណាស់ អាចតាក់តែងនូវបុគ្គលអ្នកដឹងគុណ នឹងអ្នកមិនដឹងគុណឱ្យចម្រើន និងវិនាសបាន។ បុគ្គលណាមួយគេបានជួយសង្គ្រោះដោយប្រការផ្សេងៗ លុះបានដល់គោលដៅហើយ បែរជាមិនធ្វើតបវិញដូច្នេះបុគ្គលនោះ នឹងត្រូវវិនាសដោយសារការមិនដឹងគុណនេះក្នុងពេលណាមួយជាមិនខាន ។ ឧទាហរណ៍ : ខ្លួនត្រូវដល់នូវអន្តរាយដោយ



www.elibraryofcambodia.org

ហេតុអ្វីមួយ អ្នកដឹងគេឃើញគេមិនជួយ ដោយគេគិតឃើញនូវបុគ្គលអ្នកគ្រោះថ្នាក់នោះថា អ្នកហ្នឹងមិនបាច់ជួយវាទេ ទុកឱ្យវាវិនាសបែបហ្នឹងចុះទើបសម ព្រោះកន្លងមកបានជួយវាដល់ត្រើយហើយ វាតែងតែសើយគួចដាក់វិញ។ តែបើមិនលុបគុណគេវិញ ដូច្នេះនឹងបានចម្រើនសព្វបែបយ៉ាងទាំងអស់ ទោះបីបុគ្គលនោះមានក្តី ក្រក្តី អ្នកដទៃគេចូលចិត្តជួយគ្រប់ៗគ្នា។ ដោយហេតុគេគិតឃើញថា អ្នកហ្នឹងកាលបើជួយទៅមិនភ្លេចគុណឡើយ ទោះបីគ្នាក្រគ្មានអ្វីឱ្យវិញក៏ដោយ តែពេលឯងមានកិច្ចការអ្វីម្តងៗ មកជួយខ្វល់ខ្វាយមិនដែលខានទេ។ ទាំងប៉ុន្មានខាងលើនេះ គឺជាសក្ខីភាពនៃការដឹងគុណ និងមិនដឹងគុណចំពោះបុគ្គល ដែលលោកមានគុណមកលើ។ ដូច្នេះដើម្បីឆ្លើយតបចំពោះគុណលោកវិញ ឱ្យក្លាយទៅជាបុគ្គលដ៏ល្អ ត្រូវតែរៀបចំគ្រប់ពេលវេលាក្នុងការសងគុណលោក។ ចំពោះភារកិច្ចនៃការសងគុណនេះមានច្រើនបែបណាស់ ដោយហេតុបុគ្គលអ្នកមានគុណមកលើនោះមានច្រើនបែបដែរ ដូចជាព្រះពុទ្ធ ព្រះរាជា គ្រូ និងមាតាបិតាជាដើម ដូចបានលើកមកខ្លះៗ ហើយនៅខាងលើ ក៏ប៉ុន្តែក្នុងទីនេះ បើពោលនូវកិច្ចខ្លីៗ ដែលត្រូវសងគុណ ចំពោះ លោកមាន ២យ៉ាងគឺ :



www.elibraryofcambodia.org

ក-គុណធម៌ : សេចក្ដីល្អដែលលោកបានធ្វើមកលើយើងឱ្យ ក្លាយជាបុគ្គលល្អ ។

ខ-គុណធាតុ : ធាតុទាំង ៤ គឺរាងកាយទាំងមូលរបស់ លោកដែលលោកខំប្រឹងបញ្ចេញនូវសកម្មភាព សេចក្ដីល្អរបស់លោកទាំងប៉ុន្មានមកលើយើង ។

**សេចក្ដីអធិប្បាយ**

ក-គុណធម៌ : គឺសំដៅយកសង្គហធម៌ទាំងប៉ុន្មានដែលលោកជួយសង្គ្រោះមកលើយើង។ ដូច្នេះក្នុងនាមយើងនៅក្រោមការសង្គ្រោះសព្វបែបយ៉ាងរបស់លោកត្រូវតែ នាំគ្នាធ្វើនូវការសង្គ្រោះទាំងប៉ុន្មាននោះចំពោះលោកវិញ។ ក្នុងការធ្វើតបចំពោះលោកវិញនេះ ក៏ប្រកបទៅដោយកាលពីរដែរគឺ :

១-កាលសម័យ : សម័យដែលលោកមានព្រះជន្មនៅ យើងត្រូវគោរពបូជាលោកទៅដោយគ្រឿងបូជា២ យ៉ាងគឺ :

ក-អាមិសបូជា : បូជាទៅដោយបច្ច័យទាំង៤ និងទានវត្ថុទាំង ១០ ជាដើមចំពោះលោកគ្រប់ពេលវេលារហូតដល់អវសានជីវិតរបស់លោក ។

ខ-បដិបត្តិបូជា : បូជាទៅដោយការប្រតិបត្តិ តាមការទូន្មានប្រៀនប្រដៅ ប្រកបទៅដោយហេតុផលត្រឹមត្រូវរបស់លោកមិនធ្វើឱ្យខុស



www.elibraryofcambodia.org

ទៅដោយប្រការណាមួយពីការទូន្មានរបស់លោក ទោះបីឋិតនៅក្នុងពេលលោកលាចាកលោកទៅហើយក៏ដោយ ។

២-និច្ចសម័យ : សម័យដែលលោកលាចាកលោកទៅ ក៏ត្រូវតែគោរពបូជាចំពោះគុណលោកជានិច្ចដែរ ដូចជាការខំរក្សានូវកេរដំណែលដ៏ប្រកបដោយហេតុផលរបស់លោក មិនឱ្យបាត់ការខំប្រតិបត្តិតាមពាក្យដ៏មានតម្លៃរបស់លោក ការខំធ្វើខ្លួនឱ្យបានស្អាតបរិសុទ្ធដូចលោក និងការរលឹកចំពោះលោកដោយការឧទ្ទិសកុសលជាដើម ។

៤-គុណធាតុ : គឺសំដៅយកសរីរៈរាងកាយរបស់លោកដែលប្រកបដោយធាតុទាំង៤ គឺដី ទឹក ភ្លើង ខ្យល់ ។ រាងកាយទាំងមូលរបស់លោកទោះបីវាប្រកបទៅដោយអនិច្ចំ ទុក្ខំ និងអនត្តា ក៏ដោយ តែវាមានប្រយោជន៍ធំធេងក្នុងពេលលោកបញ្ចេញនូវកម្លាំងកាយ វាចា ចិត្ត ប្រកបដោយសុចរិតធម៌មកលើយើង ។

ដូច្នេះយើងត្រូវគោរពបូជា តបស្នងសងគុណចំពោះទង្វើដ៏ល្អរបស់លោកបែបនេះមួយដែរ ដូចជាការបូជាទៅដោយវត្ថុផ្សេងៗ បច្ច័យទាំង៤ និងទានវត្ថុទាំង១០ ជាដើម ។ ដទៃពីនេះក្នុងកាលលោកលាចាកពីលោកនេះទៅ ត្រូវតែនាំគ្នាចាត់ចែងនូវសរីរកាយរបស់លោក ដោយសមគួរតាម



www.elibraryofcambodia.org

ប្រពៃណីជាតិ ឬសាសនា មិនយកទៅចោលរាត់រាយពេញទឹកពេញដី ដូច ខ្មោចឆ្កែ ខ្មោចឆ្មា ។ល។ អដ្ឋិធាតុរបស់លោកក៏ដូច្នេះដែរ ត្រូវតែយកទុកដាក់ ឱ្យសមគួរ មិនទុកឱ្យនៅខ្ចាត់ខ្ចាយទៅទីផ្សេងៗ ដូចឆ្អឹងគោ ឆ្អឹងក្របី គេដើរ ទៅមកត្រូវជាន់ ត្រូវទាត់ ត្រូវឈ្លូសចម្លាត ។ល។

ដើម្បីឱ្យសមគួរដល់គុណធាតុរបស់លោក គឺត្រូវនាំគ្នាធ្វើស្តូប ចេតិយ ប្រាង្គ ប្រាសាទ មឈូស កោដ្ឋ ។ល។ បញ្ចុះ ឬឧទ្ទិសចំពោះអដ្ឋិធាតុលោក ទុកគោរពបូជាទៅថ្ងៃក្រោយទៀត។ បែបនេះជាអំពើដ៏ល្អបំផុតក្នុងការសង គុណចំពោះលោកវិញ ។ តែនេះមិនមែនចាត់ទុកថាជាមង្គលភ្ញាក់ផ្អើលនោះ ទេ ដោយហេតុថាការគោរពនូវអដ្ឋិធាតុរបស់លោកនោះ គឺយកគុណលោកជា ធំ។

**វិធីគោរពមាន ៣ យ៉ាង**

ក-កាយបណាម : គោរពដោយកាយ

ខ-វិចីបណាម : គោរពដោយវាចា

គ-មនោបណាម : គោរពដោយចិត្ត ។

វិធីគោរពទាំងពាខាងលើនេះ ដូច្នេះពេលដែលចូលទៅកាន់ទីកន្លែង ដែលបញ្ចុះអដ្ឋិធាតុលោក មានចេតិយជាដើម ត្រូវតែបន្ទន់នូវកាយរបស់ខ្លួន



www.elibraryofcambodia.org

ឱ្យឱនលំទោនដូចជាការលើកដៃប្រណម ឬក្រាបថ្វាយបង្គំជាដើម ចំពោះមុខលោក ឬអដ្ឋិធាតុរបស់លោក ។ បន្ទាប់មកត្រូវបញ្ចេញវាចាដ៏ផ្អែមពីរោះទៅរក់លោក ឬអដ្ឋិធាតុលោកដូចជាការនិយាយអំពីគុណធម៌ របស់លោកជាដើម។ ក្នុងពេលនោះ ចិត្តក៏ត្រូវតែទោរទន់ត្រង់ស្មោះ មិនងាករេចេញពីលោក ឬអដ្ឋិធាតុរបស់លោកដែរ ដូចជាការធ្វើឱ្យជ្រះថ្លាចំពោះសេចក្ដីល្អដែលលោកមានមកលើខ្លួន និងអ្នកដទៃជាដើម ។

**លំដាប់ថ្នាក់នៃអដ្ឋិធាតុ**

ដូចយើងបានដឹងរួចមកហើយ ពីខាងដើមអំពីអដ្ឋិធាតុ របស់បុគ្គលមានគុណមកលើយើង ហើយគោរពបូជាសព្វពេល សព្វវេលាដោយទ្វារទាំង ៣ គឺកាយ វាចា និងចិត្ត។ តែចំពោះអដ្ឋិធាតុ អ្នកមានគុណទាំងនោះមានតាមលំដាប់ថ្នាក់គុណធម៌ របស់លោក ដូច្នេះបើចែកតាមគុណធម៌នោះមាន ២បែបគឺ :

ក-អដ្ឋិធាតុថ្នាក់ខ្ពស់ សំដៅយកអដ្ឋិធាតុព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវ័កពុទ្ធ ព្រះអរហន្ត និងស្ដេចចក្រពត្តិជាដើម ។

ខ-អដ្ឋិធាតុថ្នាក់បន្ទាប់សំដៅយកអដ្ឋិធាតុ ស្ដេច មន្ត្រី បុព្វបុរស មាតាបិតា គ្រូឧបជ្ឈាយាចារ្យ និងអ្នកមានគុណជាច្រើនទៀត ។



www.elibraryofcambodia.org

បណ្តាអដ្ឋិធាតុទាំងពីរប្រភេទនៅខាងលើនេះ ទោះបីមួយណាក៏គួរគោរពបូជាទៅដោយទ្វារទាំង ៣ ដូចខាងលើ ( កាយ វាចា ចិត្ត) ទាំងអស់ ។ ដោយហេតុថា លោកសុទ្ធតែជាបុគ្គលមានគុណធមិ គុណធាតុ លើរូបយើង ដូចគ្នា គ្រាន់តែជាផ្នែក១ ទៅតាមលំដាប់ ។ ដូច្នេះការធ្វើស្តូប ចេតិយ ប្រាង្គ ប្រាសាទ មឈូស កោដ្ឋ ។ល។ ដើម្បីបញ្ចុះនូវអដ្ឋិធាតុរបស់លោក ហើយនឹងការគោរពនូវទីស្ថានទាំងនោះផងដែរ ឈ្មោះថា ការគោរពបូជាចំពោះគុណធមិរបស់លោកផង នឹងការគោរពចំពោះគុណធាតុរបស់លោកផង ។

## អត្ថន័យនៃការគោរព

ក្នុងពេលគោរពនូវទីស្ថានទាំងនោះ យើងត្រូវមានចិត្តគិតថាលោកជាបុគ្គលគួរឱ្យគោរពបូជា ជាបុគ្គលដ៏គំរូនៅក្នុងលោកទាំងមូល ។ នៅក្នុងពិភពលោកនេះ លោកជាផ្ការបស់មនុស្សជាអ្នកបញ្ចេញនូវផ្លែផ្កា ដ៏សន្ទឹកសន្ធាប់ដល់ពួកមនុស្សទូទៅ ហើយជាអ្នកស្រឡាញ់នូវមនុស្សទូទៅ ស្មើនឹងមុខរបស់លោកផងដែរ ។ បន្ទាប់មកយើងត្រូវតាំងខ្លួនធ្វើស្នងចំពោះសេចក្តីល្អទាំងប៉ុន្មាន ដែលលោកបានធ្វើក្នុងពេលលោកមានព្រះជន្មនៅនោះ គឺលៃយ៉ាងណាឱ្យដូចសកម្មភាពរបស់លោកដោយផ្ទាល់ដែរ ។



www.elibraryofcambodia.org

## សរសេរចប់

ថ្ងៃ ៣រោជ ខែ ចេត្រ ឆ្នាំ មមែ ពុទ្ធសក្ករាជ ២៥៤៧

វត្តពាមមង្គល ឃុំរកាកោង ១ ស្រុកមុខកំពូល ខេត្តកណ្ដាល



www.elibraryofcambodia.org

## ឯកសារពិគ្រោះ

១- ដំណាលពុទ្ធចេតិយ ( ឈឹម ក្រសេម)

២- ពុទ្ធសាសនា ២៥០០ ( ពុទ្ធសាសនបណ្ឌិត្យ)

៣- មង្គលត្ថទីបនី ភាគ១ ( យិន នឿន)

៤- ពុទ្ធប្បវត្តិកថា ( ឈឹម ស៊ុមន៍)

៥- ពុទ្ធប្បវត្តិសន្តិកេនិទាន ភាគ៣ ( ទូត ទឹម)

៦- ប្រស្នាពុទ្ធប្បវត្តិ ( យូ អ៊ុន)

៧- ព្រះមាល័យទេសនា ( គង់ ឈួយ)

៨- គិហិបដិបត្តិពិស្តារ ( ឈឹម ទូច)

៩- ព្រះរាជពិធីទ្វាទសមាស ភាគ១ ( ឈឹម ក្រសេម)

១០- ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីអង្គរ ( ហ៊្សេក សីវ៉េស)

១១-វិន័យសង្ខេប ( ស៊ុន ហ៊ាន)

១២- ប្រជុំអានិសង្ស ( នាង នឿន)

១៣-អានិសង្សសាមសិប ( ចាប ពិន)

១៤- គិហិប្បតិបត្តិយរាវាសធម៌ ( នួន សំអ៊ាន)

១៥- សង្ខេបទសជាតក ( ឈឹម ស៊ុមន៍)



www.elibraryofcambodia.org

១៦- គាថាធម្មបទប្រែ ( ឃិន នឿន)

១៧- មគ្គុទ្ទេសនគរ ( ប៉ាង ខាត់)

១៨- ព្រះសមណគោតម ភាគ២ ( ឆឹង ផាន់សុផុន)

១៩- ពិធីធ្វើបុណ្យខ្មោច ( លី សុវីរ)

២០- រៀនទេសនា ដំបូង ( ឈឹម ទូច)

២១- ប្រជុំធម្មទេសនា ( ចោទ ឆ្លើយ)( ឈឹម ទូច)

២២- ប្រស្នា គិហិប្បតិបត្តិ ( ឈឹម ទូច)

២៣- ប្រជុំបុញ្ញប្រវត្តិ ( ឃិន វន់)

២៤- ចំណេះដឹងទូទៅ ( នៅ កាស៊ុ)

២៥- អារ្យធម៌ខ្មែរ ( អ្នកស្រី ត្រឹង ងា)

២៦- មហាវណ្ណកម្ម ( ប៉ាង ខាត់)



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ នួន គីហា
ខែឧសភា ឆ្នាំ២០១៧

បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "សិទ្ធិអ្នកនិពន្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ទៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org



# នានាធម្មសង្គហៈ

## ប្រស្នាពីបុរាណ

ព្រះភិក្ខុ **ជិន មាស**

១- ពេលយប់អង្គុយពុំព្រមដេក
អង្គុយធ្មេចភ្នែកប្រាំបួនខែ
លុះដល់ថ្ងៃរះក្រហមរ៉ែ
ខ្លួនប្រែដេកផ្ងារអស្ចារ្យក្រៃ ។

២- ដេកផ្ងារចំនួនបួនខែពេញ
ទើបប្រែផ្កាសវិញគួរសង្ស័យ
ពេលអរុណរះស្មើព្រឹក្សព្រៃ
ទើបប្រែក្រឡៃអង្គុយវិញ ។

៣- លុះយូរខែថ្ងៃថ្មៃរៀបខ្លួន
ចេះដើរជើងបួនមាំមួនមិញ
ពេលពេញពន្លឺត្រង់ជ្រែវិញ
ចេះដើរញាប់ស្ទេញតែជើងពីរ ។

៤- សួរសែងទន់ៗជិតព្រលប់
បែរជាត្រឡប់ផ្លាស់ស្ថានទី
ចេះដើរជើងបីញ៉ូរឥន្ទ្រីយ៍
ព្រលប់ពេញទីដេកលែងក្រោក ។

**(សូមបណ្ឌិតស្វែងយល់ដោយខ្លួនឯងចុះ)**

**ឱធេយ្យានុសាសេយ្យ ឆាបកា ច និវារយេ សតំ ហិ សោ**
**បិយោ ហោតិ អសតំ ហោតិ អប្បិយោ ៕**

អាចារ្យចេះទូន្មានហាមប្រដៅ បុគ្គលខ្លៅឱ្យលះបង់បាបបាន អាចារ្យនោះជាទីគាប់រាប់អាន
នៃសន្តានសប្បុរសទាំងអស់គ្នា។

តែពុំគាប់ចិត្តនៃអសប្បុរស ព្រោះពុតអសប្បុរសស្វែងពាលា ស្រលាញ់តែអំពើបាបវេរា
ផ្លូវសួគ៌ាជាទីស្ថានសប្បុរស។

ISBN: 99950-68-14-1

**លោកនីតិបករណ៍**

បោះពុម្ពផ្សាយ ៣.០០០ ច្បាប់
រក្សាសិទ្ធិគ្រប់បែបយ៉ាង www.elibraryofcambodia.org

9 789995 068141